បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ព្រះវិន័យ

# សង្ឃកម្មកថា

ភាគ ១

សម្រាប់សាលាធម្មវិន័យ

ថ្នាក់ឯក

INSTITUT BOUDDHIQUE

២៩១.
៩៨

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៩

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្ស៊ូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២៤១.៥៥

# ព្រះវិន័យ

# សង្ឃកម្មកថា

## ភាគ ១

សម្រាប់សាលាធម្មវិន័យ ថ្នាក់ឯក

ព្រះឃោសធម្ម **ម៉ុច - វិសេស** ( ចន្ទធម្មោ )
រៀបរៀង

**ក្រោមព្រះបរមរាជូបត្ថម្ភ**

បោះពុម្ពឡើងវិញ ចំនួន ៣.៤០០ ច្បាប់
តាមច្បាប់បោះពុម្ពគ្រាទី ២
( ក្រសួងធម្មការ )

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
២៩៣៥/សិ

**ភ្នំពេញ**
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៨ គ.ស ១៩៩៥

# សេចក្តីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅនេះ ត្រូវបានបោះពុម្ពជាថ្មីឡើងវិញ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) និងពីអង្គការ រិស្សូ កូសី-កៃ (RKK) ។

ការបោះពុម្ពឡើងវិញលើកនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្តី កំហុសក្នុងការរៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

ពុទ្ធសាសនបណ្ឌិត្យ នឹងខិតខំចាត់ការបោះពុម្ពសៀវភៅសិក្សា និងសៀវភៅអានគ្រប់បែបយ៉ាងផ្សេងទៀត ដើម្បីតម្រូវទៅតាមការចាំបាច់ប្រើប្រាស់របស់សាធារណជនផង ដើម្បីរក្សាមរតកវប្បធម៌ អក្សរសាស្ត្រ អោយគង់វង្សនិងរីកចំរើនផង ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) និងអង្គការ រិស្សូ កូសី-កៃ (RKK) ដែលបានផ្តល់ការឧបត្ថម្ភដ៏ឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ១៩៩៥

ពុទ្ធសាសនបណ្ឌិត្យ

ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន ( JSRC ) និងដោយមានការឧបត្ថម្ភពី

អង្គការ រិស្សូ កូសី-កៃ (RKK)

យើងអធិដ្ឋាន សូមអោយសៀវភៅនេះបានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee (JSRC) with the contribution from

Rissho Kosei-Kai (RKK)

We pray that this book would contribute to the friendship with Cambodian people and their religious and cultural preservation.

# ព្រះវិន័យ
# សង្ឃកម្មកថា

ភាគ ១

ព្រះឃោសធម្ម

( ម. ស. បន្ទធម្មោ )

រៀបរៀង

# ក្រោមព្រះបរមរាជូបត្ថម្ភ

សម្រាប់សាលាធម្មវិន័យថ្នាក់ឯក

*ផ្សាយចេញពីក្រសួងធម្មការ*

បោះពុម្ពគ្រាទី ១ បំនួន ៣.០០០ ច្បាប់

ព. ស. ២៤៩៧

គ. ស. ១៩៥៤

# អារម្ភបទ

វិន័យ សង្ឃកម្មកថា នេះកើតឡើងដោយ សម្ដេចព្រះមហាសុមេធាធិបតី (ជ. ណ. ជោតញ្ញាណោ) សង្ឃនាយកជាប្រធាននៃគណៈកម្មការរៀបរៀងធម្មវិន័យ បានចែកមុខការឲ្យសមាជិកនៃគណៈកម្មការនេះរៀបរៀងធម៌ខ្លះ វិន័យខ្លះ ដោយខ្លួន ៗ ពីគ្នា ដើម្បីជូនទៅក្រសួងធម្មការឲ្យបោះពុម្ពសម្រាប់ការសិក្សាធម្មវិន័យទាំង ៣ ថ្នាក់ (ត្រី-ទោ-ឯក) ។ សម្ដេចព្រះមហាសុមេធាធិបតីបានសុំឲ្យខ្ញុំរៀបរៀងវិន័យសង្ឃកម្មកថានេះ ដោយគណៈកម្មការក៏បានអនុម័តផង ។ បើតាមកម្លាំងកាយរបស់ខ្ញុំដែលពុំសូវសម្បូណ៌ ព្រោះមានរោគាពាធបៀតបៀនពេកនោះ ខ្ញុំពុំសមបើអាចហ៊ានទទួលមុខការនេះសោះ ព្រោះជាភារៈធ្ងន់ហួសកម្លាំងកាយ, ប៉ុន្តែដោយអំណាចកម្លាំងចិត្តនិងកម្លាំងព្យាយាមផង ទាំងមានសេចក្ដីគោរពចំពោះធម្មវិន័យព្រះពុទ្ធសាសនាផង ចំពោះសម្ដេចព្រះសង្ឃនាយកជាប្រធាននៃគណៈកម្មការផង ខ្ញុំពុំអាចហ៊ានប្រកែក ក៏ព្រមទទួលភារៈរៀបរៀងវិន័យនេះលុះត្រាតែចប់ ល្មមគួរដល់ការសិក្សានៃភិក្ខុជាសិក្ខាកាមកុលបុត្រ ធម្មកោសលថ្នាក់ឯក ។ ការរៀបរៀងវិន័យនេះ តាមលំអានបាលីវិនយបិដកនិងបាលីមុត្តកវិនយវិនិច្ឆ័យខ្លះ កង្ខាវិតរណីខ្លះ ខ្ញុំស្រង់យកមករួបរួមតាមលំដាប់នៃសង្ឃកម្មទាំង ៤ យ៉ាង ។ វិន័យនេះបានជាខ្ញុំឲ្យឈ្មោះថា សង្ឃកម្មកថា ព្រោះនិយាយពីសង្ឃកម្ម ៤ យ៉ាងគឺ អបលោកនកម្ម, ញត្តិកម្ម, ញត្តិទុតិយកម្ម, ញត្តិចតុត្ថកម្ម ដែលជាសង្ឃកម្មរបស់ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ។

លុះខ្ញុំរៀបរៀងរួច បានឲ្យសរសេរចម្លងស្រេចហើយ បានប្រគេនសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក, សម្ដេចក៏បានជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួលខ្លះថែមទៀត ដោយយល់ឃើញថាត្រឹមត្រូវគួរដល់ការសិក្សាធម្មវិន័យថ្នាក់ឯកហើយ ។ ប៉ុន្តែ បើទុកជាដូច្នេះក៏ដោយ ធម្មតាការធ្វើដំបូងនៃ ទោះបីខំប្រឹតប្រៀបដោយប្រយ័ត្នប្រយែងយ៉ាងណា ក៏គង់មានការខ្វាត់ខ្វះ (ដោយការសរសេរឬការបោះពុម្ពជាដើម ) បើមិនខ្វាត់ច្រើនក៏តិចតួចពុំខាន, លុះត្រាតែដល់គ្រាទី២ទី៣ឡើងទៅ, ដោយបេះតែផ្ទៀងពិនិត្យតម្រឹមតម្រង់ថែម ១ ទៀត, ទើបអាចនឹងត្រឹមត្រូវដោយសព្វគ្រប់ឡើងបាន (នេះជាធម្មតានៃកិច្ចការរបស់បុថុជ្ជនក្នុងលោក) ។

ស្រាប់តែដល់រៀបរៀងផ្ទៀងផ្ទាត់ស្រេចហើយ សម្លឹងមើលការនេះ, ខ្ញុំមានរំណរថា ខ្ញុំបានបុណ្យច្រើនណាស់ ព្រោះវិន័យសង្ឃកម្មនេះមាននៅតែក្នុងគម្ពីរជាបាលីសុទ្ធ ឥឡូវបានប្រែរៀបរៀងមកជាសម្រាយហើយ, តពីនេះទៅមុខ, ព្រះភិក្ខុសង្ឃគ្រប់វត្តក្នុងកម្ពុជរដ្ឋទាំងមូល ទោះលោកអ្នកសិក្សាធម្មវិន័យថ្នាក់ឯកក្ដី លោកក្រៅពីនោះក្ដី អាចនឹងយល់សង្ឃកម្មទាំង៤យ៉ាងបានដោយងាយ, ជាហេតុនាំឲ្យព្រះបវរពុទ្ធសាសនាក្នុងព្រះរាជអាណាចក្រកម្ពុជារុងរឿង អស់កាលជាអង្វែងតរៀងទៅ ។

សៀវភៅវិន័យសង្ឃកម្មគថានេះ បើតាមរបៀបដែលរៀបរៀង, គួរ

តែបោះពុម្ពរួមជាមួយគ្នាតែមួយសៀវភៅ, ប៉ុន្តែក្នុងសម័យនេះ នឹងបោះពុម្ពរួមដូច្នោះពុំកើត ព្រោះក្រាស់ពេក ផ្សិតដេរក្របក្រដាសទន់នាំឲ្យអ្នកសិក្សាពិបាកកាន់ ពិបាកបើកមើល, ដោយហេតុនេះ ត្រូវតែវែកជា ២ ភាគគឺ ភាគទី ១ និយាយពី អបលោកនកម្ម, ញត្តិកម្ម, ញត្តិទុតិយកម្ម; ភាគទី ២ និយាយពីញត្តិចតុត្ថកម្ម ។ បើលោកអ្នកសិក្សាពេញចិត្តនឹងដេរក្របរឹងរួមទាំងពីរភាគជា សៀវភៅតែមួយក្បាលក៏បាន តាមត្រូវការ ។

បុណ្យកុសលដែលខ្ញុំបានហើយដោយការចំប្រឹងរៀបរៀងវិន័យនេះរួចស្រេចហើយ ខ្ញុំមានអំណរដ៏ក្រៃលែងនោះ ខ្ញុំសូមថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះប្រិយមហាក្សត្រិយ៍ អគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលទ្រង់ព្រះមេត្តាប្រោសព្រះរាជទានព្រះបរមរាជានុញ្ញាតឲ្យបង្កើតការសិក្សាធម្មវិន័យ, ដោយព្រះរាជក្រឹត្យលេខ២១៤ ន.ស. ចុះថ្ងៃទី២៨សីហា ព.ស. ២៤៩៣, គ.ស. ១៩៥០, សូមទ្រង់ប្រកបដោយសិរីសុវត្ថិវឌ្ឍនសុភមង្គល តេជះជោគជ័យ ទីឃាជន្មាយុ សុខគ្រប់ប្រការ ក្នុងព្រះសិរីរាជសម្បត្តិជានិច្ចនិរន្តរ៍ អស់កាលយូរអង្វែងរៀងទៅ !

មួយចំណែកទៀត ខ្ញុំសូមឧទ្ទិសកុសលនេះ ប្រគេន-ជូនចំពោះទៅមាតាបិតាឧបជ្ឈាយាចារ្យ និងបុព្វបុរសទាំងឡាយរបស់ខ្ញុំ សូមឲ្យអនុមោទនាទទួល ហើយសូមឲ្យបានសម្រេចឥដ្ឋមនុញ្ញផលវិបុលសុខ

តាមគន្លងផលសេចក្តីប្រាថ្នា! បំណែកខាងខ្លួនខ្ញុំក៏សូមឲ្យបានជួបប្រទះ តែនឹងសេចក្តីសុខនិទុក្ខនិភ័យ ទាំងក្នុងបច្ចុប្បន្នទាំងក្នុងបរលោកនាយ !

សូមឲ្យព្រះធម៌វិន័យពុទ្ធសាសនារីកផ្សាយ ដោយរួសរាន់ទៅក្នុងសាកលលោក! ហើយសូមឲ្យប្រតិស្ឋានទៅអស់កាលយូរអង្វែង !

សូមឲ្យការសិក្សាព្រះធម៌វិន័យក្នុងកម្ពុជរដ្ឋ រុងរឿងចំរើនជានិច្ចនិរន្តរ៍តអង្វែងទៅ !

សព្វរោគវិនិមុត្តា សព្វសន្តាបវជ្ជិតា

សព្វវេរមតិក្កន្តា សុខិតា ហោន្តុ បាណិនោ!

ថ្ងៃទី ២០ មិថុនា ព. ស. ២៤៩៧ គ. ស. ១៩៥៤

ព្រះឃោសធម្ម (ម. ស. បន្ទធម្មោ)

ចៅអធិការវត្តមហាមន្ត្រី ក្រុងភ្នំពេញ

អនុប្រធានទី ២

នៃគណៈកម្មការរៀបរៀងធម្មវិន័យ

## មាតិកានុក្រម

### អបលោកនកម្ម

ទំព័រ


អបលោកនកម្ម មានឋាន៥ . . . . . . . . . . . ៣

និស្សារណា ការបណ្តេញ . . . . . . . . . . ៤

ឱសារណា ការហៅចូលមក . . . . . . . . . . ៦

កណ្ឌុកម្ម ការកោរសក់ . . . . . . . . . . ៨

ព្រហ្មទណ្ឌ អាជ្ញាធំប្រសើរ . . . . . . . . . . ១១

កម្មលក្ខណា កម្មជាលក្ខណៈរបស់អបលោកនកម្ម . . . . . ១៥


### ញត្តិកម្ម


ញត្តិកម្មមានឋាន៩ . . . . . . . . . . . . . . ១៩

ឱសារណា . . . . . . . . . . . . . . ២០

និស្សារណា . . . . . . . . . . . . . . "

ឧបោសថ . . . . . . . . . . . . . . ២១

បវារណា . . . . . . . . . . . . . . ២២

សម្មតិ ការសន្មតិខ្លួនឯងនឹងអ្នកដទៃ . . . . . . . "

ទាន ការឲ្យនូវបរិក្ខារមានចីវរជាដើម . . . . . . . ២៤

បដិគ្គហ ការទទួលអាបត្តិ . . . . . . . . . ២៥

បច្ចុក្កឌ្ឍនា ការលើកទាញបវារណាយកទៅដាក់ថ្ងៃខាងមុខ . . . . ២៦

កម្មលក្ខណា . . . . . . . . . . . . . . ២៧


### ញត្តិទុតិយកម្ម


ញត្តិទុតិយកម្ម មានឋាន ៧ . . . . . . . . . ៣០

និស្សារណា . . . . . . . . . . . . . . ៣១

ទំព័រ

ឧសារណា . . . . . . . . . . . . . . . . ៣៦

សម្មុតិ . . . . . . . . . . . . . . . . ៣៧

សីមាសម្មុតិ ការសន្មតិនូវសីមា . . . . . . . . . ៣៨

តិចីវរាវិប្បវាសសម្មុតិ ការសន្មតិមិនឲ្យមានអាបត្តិព្រោះនៅប្រាសចាកត្រៃចីវរ ៤១

សន្ថតសម្មុតិ ការសន្មតិនូវសំពត់សន្ថត . . . . . . . ៤៦

ភត្តុទ្ទេសកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកសំដែងឡើងនូវភត្ត ៦០

សេនាសនគ្គាហាបកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់សេនាសនៈ ៦៣

ចីវរប្បដិគ្គាហកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកទទួលចីវរ ៦៨

ភណ្ឌាគារិកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាឆាយឃ្លាំង . . . ៧៣

ចីវរភាជកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកចីវរ . . . ៧៨

យាគុភាជកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកបបរ . . . ៨០

ខជ្ជកភាជកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកចំណី (បង្អែម) ៨១

អប្បមត្តកវិស្សជ្ជកសម្មុតិ ការសន្មតិភិក្ខុឲ្យជាអ្នកលះបង់បរិក្ខារបន្តិចបន្តួច ៨២

សាដិយគ្គាហាបកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់សំពត់ ៨៤

បត្តគ្គាហាបកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់បាត្រ ៨៥

អារាមិកបេសកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រើនូវញោមវត្ត ៩០

សាមណេរបេសកសម្មុតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រើនូវសាមណេរ ៩១

ទាន ការឲ្យកឋិនចីវរ . . . . . . . . . . . . . ៩៣

ឧទ្ធារ ការដកកឋិន . . . . . . . . . . . . ៩៧

ទេសនា ការសំដែងទីដីសង់កុដិនិងវិហារ . . . . . . . ៩៩

កម្មលក្ខណ . . . . . . . . . . . . . . . ១១៣

# វិន័យ

## សង្ឃកម្មកថា

ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណហើយ ទ្រង់ទទួលអារាធនានៃមហាព្រហ្មទាំងឡាយមានសហម្បតីព្រហ្មជាប្រធាន ដើម្បីទេសនាប្រោសសត្តនិករ ទ្រង់សំដែងព្រះធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុទាំង ៥ អង្គ ជាដំបូង ព្រះអង្គចេះតែសំដែងជាលំដាប់តៗមក រហូតដល់ប្រោសសុភទ្ទបរិព្វាជកឲ្យតាំងនៅក្នុងមគ្គផល បានបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា ព្រះអង្គចូលកាន់អមតមហានិព្វានជាឋានបរមសុខ ក្នុងចន្លោះនៃដើមសាលព្រឹក្ស (ដើមត្រចៀកប្រើស) ទាំងគូ ក្នុងសួនឧទ្យាននៃក្សត្រិយ៍មល្លៈទាំងឡាយជិតក្រុងកុសិនារាក្នុងមល្លជនបទ, ធម៌ទេសនារបស់ព្រះអង្គនោះហៅថាធម្មវិន័យ ។ ចំណែកធម៌មិនបានយកមកនិយាយក្នុងទីនេះទេ យកតែវិន័យមកនិយាយ, ចំណែកវិន័យនោះទៀតក៏មិនបាននិយាយសព្វគ្រប់ទេ យកតែសង្ឃកម្មដែលទ្រង់បញ្ញត្ត ទ្រង់អនុញ្ញាត ដល់ភិក្ខុសង្ឃមកនិយាយ ។

ភិក្ខុតាំងពី៤រូបឡើងទៅហៅថា សង្ឃ, អំពើឬការងាររបស់សង្ឃនោះហៅថា សង្ឃកម្ម, សង្ឃកម្មនោះមាន ៤ យ៉ាងគឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ។

កម្មដែលភិក្ខុសូត្រប្រកាសប្រាប់វត្ថុនោះ ១ អស់វារៈ ៣ ដងហើយធ្វើដោយអនុមតិ(១)របស់សង្ឃដែលព្រមព្រៀងគ្នាហៅថា អបលោក-នកម្ម ។ នេះមិនមានវិធីតាំងញត្តិដូចកម្មទាំង ៣ ខាងចុងទេ ។ កម្មដែលសង្ឃធ្វើដោយត្រឹមតែញត្តិមួយ ដោយអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នា ហៅថា ញត្តិកម្ម ។ កម្មដែលសង្ឃធ្វើដោយញត្តិមួយនឹងអនុស្សាវនាមួយ ដោយអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នា ហៅថា ញត្តិទុតិយកម្ម (កម្មមានញត្តិជាគំរប់ពីរ) ។ កម្មដែលសង្ឃធ្វើដោយញត្តិមួយនឹងអនុស្សាវនាបី ដោយអនុមតិរបស់សង្ឃដែលព្រម-ព្រៀងគ្នា ហៅថា ញត្តិចតុត្ថកម្ម (កម្មមានញត្តិជាគំរប់បួន(២)) ។

បណ្ដាកម្ម ៤ យ៉ាងនោះ អបលោកនកម្ម ត្រូវធ្វើដោយត្រឹមតែសូត្រប្រកាសប្រាប់តាមបែបបទអបលោកនៈប៉ុណ្ណោះ នឹងធ្វើតាមបែបបទញត្តិកម្ម, ញត្តិទុតិយកម្ម នឹងញត្តិចតុត្ថកម្មពុំបានឡើយ ។ ញត្តិកម្មត្រូវធ្វើដោយតាំងញត្តិមួយ មិនត្រូវធ្វើតាមទំនងអបលោកនកម្ម, ញត្តិទុតិយកម្ម នឹងញត្តិចតុត្ថកម្មឡើយ ។ ញត្តិទុតិយកម្ម ធ្វើតាមទំនងអបលោកនកម្មបានខ្លះ មិនបានខ្លះ, កម្មទាំងប្រាំមួយដែលធ្ងន់ ។ (៣)

---

១ អនុមតិ ប្រែថា ត្រេកអរ, ពេញចិត្ត, យល់ស្រប, យល់តាម, យល់ព្រម ។ ២ សង្ឃកម្មទាំង ៤ យ៉ាងនេះ មុននឹងធ្វើមានវិធីជំរះសង្ឃដែលឋិតនៅក្នុងសីមាជាមួយគ្នា នឹងការនាំឆន្ទៈរបស់ភិក្ខុដែលគួរឱ្យឆន្ទៈហើយទើបធ្វើបាន ដូចគ្នាទាំងអស់ ។ ៣ គម្ពីរកង្ខាវិតរណីថា កម្មទាំង ៧ ដែលធ្ងន់លោកបន្ថែមចីវរទានៈ (ការឲ្យចីវរ) ១ ចូលមកទៀត ។

គឺ សីមាសម្មតិ ការសន្មតសីមា ១ សីមាសមូហន ការដកសីមា១ កឋិនទាន ការឲ្យសំពត់កឋិន ១ កឋិនុទ្ធារ ការដកកឋិន ១ កុដិវត្ថុទេសនា ការសំដែងទីដីសង់កុដិ ១ វិហារវត្ថុទេសនា ការសំដែងទីដីសង់វិហារ ១; ទាំង ៦ នេះនឹងធ្វើតាមទំនងបែបបទអបលោកនកម្មពុំបានឡើយ ត្រូវធ្វើដោយសូត្រញត្តិទុតិយកម្មវាចាដោយដាច់ខាត, កម្មទាំងឡាយដ៏សេស គឺសម្មតិទាំង ១៣ ក្តី(១) សម្មតិឯទៀត ។ មានសេនាសនគ្គាហកសម្មតិនឹងមតកចីវរទានសម្មតិជាដើមក្តី ជាកម្មស្រាល ។ នឹងធ្វើតាមទំនងបែបបទអបលោកនកម្មក៏បាន ធ្វើដោយសូត្រញត្តិទុតិយកម្មវាចាក៏បាន; បំណែកញត្តិចតុត្ថកម្មត្រូវធ្វើតាមលក្ខណៈនៃញត្តិចតុត្ថកម្ម មិនត្រូវធ្វើតាមលក្ខណៈនៃកម្មទាំង ៣ ខាងដើមឡើយ ។

## អបលោកនកម្ម

អបលោកនកម្មមានប៉ាន ៥ គឺ ឱសារណា ១ និស្សារណា ១ ភណ្ឌុកម្ម១ ព្រហ្មទណ្ឌ១ កម្មលក្ខណ ១ ។

ឱសារណា ប្រែថាការហៅចូលមក; និស្សារណា ប្រែថាការ

---

១ សម្មតិទាំង ១៣ គឺ ចីវរាវិប្បវាសសម្មតិ ១ សន្ថតសម្មតិ ១ ភត្តុទ្ទេសកសម្មតិ ១ ភណ្ឌាគារិកសម្មតិ ១ ចីវរប្បដិគ្គាហកសម្មតិ ១ ចីវរភាជកសម្មតិ ១ យាគុភាជកសម្មតិ ១ ខជ្ជកភាជកសម្មតិ ១ អប្បមត្តកវិស្សជ្ជកសម្មតិ ១ សាដិយគ្គាហាបកសម្មតិ ១ បត្តគ្គាហាបកសម្មតិ ១ អារាមិកបេសកសម្មតិ ១ សាមណេរបេសកសម្មតិ ១ ។

បណ្តេញចេញ; ភណ្ឌុកម្ម ប្រែថា ការកោរសក់ ឬធ្វើនូវមនុស្ស ដែលមានសក់វែងឲ្យទៅជាមនុស្សត្រងោល; ព្រហ្មទណ្ឌ ប្រែថាអាជ្ញាដ៏ប្រសើរ; កម្មលក្ខណ ប្រែថា អបលោកនកម្មមានកម្មជាគ្រឿងកំណត់គត់សំគាល់ គឺថាកម្មមានអវន្ទិយកម្មជាដើមជាលក្ខណៈ ឬជាហេតុនាំឲ្យកើតអបលោកនកម្ម ។

ឱសារណានិងនិស្សារណាទាំង ២ បទនេះ លោករៀងទុកដូច្នេះដើម្បីជាការស្រួលហៅ ប៉ុន្តែលោកអធិប្បាយនិស្សារណាមុន ទើបអធិប្បាយឱសារណាជាខាងក្រោយវិញ ។ ការធ្វើទណ្ឌកម្មនិងនាសនៈដល់កណ្តកសាមណេរដែលប្រកបដោយមិច្ឆាទិដ្ឋិយល់ខុសចាកសភាវធម៌ ហៅថានិស្សារណា ( ការបណ្តេញ ) ។ ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ ទោះបីសាមណេរណា ដែលពោលទោសត្មះតិះដៀលព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី សំដែងនូវរបស់ជាអកប្បិយថាជាកប្បិយវិញ ប្រកបដោយមិច្ឆាទិដ្ឋិ ប្រកបដោយអន្តគ្គាហិកទិដ្ឋិ (១) សាមណេរនោះសង្ឃត្រូវហាមឃាត់កំណត់បីដង កុំឲ្យយល់ កុំឲ្យពោលដូច្នោះទៀត ឲ្យលះបង់លទ្ធិនោះចេញ បើមិនលះបង់ទេ ត្រូវប្រជុំសង្ឃហើយនិយាយដាស់តឿនក្រើនរំលឹកឲ្យលះបង់ចេញ បើនៅតែមិនលះទេ, ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវធ្វើអបលោកនកម្ម បណ្តេញ

---

១ ការយល់ខុសប្រកាន់មាំនូវកោដ្ឋាសៈដ៏លាមកអាក្រក់ថោកទាប ។

*ចេញ (និស្សារណា) ។ ឯវិធីដែលធ្វើអបលោកនកម្មនោះដូច្នេះ*

សង្ឃម្ភន្តេ បុច្ឆាមិ អយំ (ឥត្ថន្នាមោ)[១] សាមណេរោ ពុទ្ធស្ស ធម្មស្ស សង្ឃស្ស អវណ្ណភាសី មិច្ឆាទិដ្ឋិកោ យំ អញ្ញេ សាមណេរា លភន្តិ ទិរត្តតិរត្តំ ភិក្ខូហិ សទ្ធឹ សហសេយ្យំ តស្សា អលាភាយ និស្សារណា រុច្ចតិ សង្ឃស្សាតិ; ទុតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ អយំ (ឥត្ថន្នាមោ) សាមណេរោ ។បេ។ រុច្ចតិ សង្ឃស្សាតិ; តតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ អយំ (ឥត្ថន្នាមោ) សាមណេ-រោ ។បេ។ រុច្ចតិ សង្ឃស្សាតិ បរ បិរេ វិធស្សាតិ

*បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃថា សាមណេរ (ឈ្មោះនេះ(២)) នេះពោលនូវទោស គឺតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រកបដោយមិច្ឆាទិដ្ឋិ យល់ខុសចាកសភាវធម៌, សាមណេរ*

---

១ សាមណេរក៏ត្រូវមាននាមជាភាសាបាលីដូចជាភិក្ខុដែរ ទើបអាចដាក់បញ្ចូលតាមត្រង់ពាក្យថា ឥត្ថន្នាមោ នេះបាន ។ ព្រោះហេតុនោះ កុលបុត្រដែលមាននាមមិនមែនជាភាសាបាលី កាលបើបួសជាសាមណេរហើយ ឧបជ្ឈាយ៍ឬអាចារ្យត្រូវឲ្យនាមបញ្ញត្តិជាភាសាបាលីដូចជានាមថា ពុទ្ធរក្ខិត ធម្មរក្ខិត ជាដើម ទើបសមគួរតាមវិន័យ ។ ២ ត្រូវចេញឈ្មោះសាមណេរជាភាសាបាលី ដូចជាឈ្មោះ ឥន្ទោ, ខេមកោ, ចន្ទោ, នន្ទោ, បុណ្ណោ, សុភទ្ទោ ជាដើម ។

តាំងឡាយដទៃ តែងបានទទួលការដេកជាមួយគ្នាណា មួយអន្លើដោយពួកភិក្ខុ អស់រាត្រីពីរនឹងរាត្រីបី, ការបណ្ដេញដើម្បីមិនឲ្យបានទទួលការដេកជាមួយគ្នានោះគាប់ចិត្តដល់សង្ឃឬទេ? បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរសង្ឃជាគំរប់ពីរដងទៀតថា សាមណេរ (ឈ្មោះនេះ) នេះ ។បេ។ គាប់ចិត្តដល់សង្ឃឬទេ? បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរសង្ឃជាគំរប់បីដងទៀតថា សាមណេរ (ឈ្មោះនេះ) នេះ ។បេ។ គាប់ចិត្តដល់សង្ឃឬទេ ? នែសាមណេរចៅក្រែងចោលបង់សៀត ! ឯងចូរចៀសចេញទៅ ! ចូរលាញទៅ !

លុះសម័យជាខាងក្រោយមក បើសាមណេរនោះដឹងថាខ្លួនខុសហើយ លែងធ្វើអំពើខុសដូចមុនទៀតហើយ ត្រូវការសូមខមាទោសនឹងសង្ឃ ត្រូវសូត្រសូមដូច្នេះ (សូត្រ ៣ ដង) ថា អហម្ភន្តេ ពាលតាយ អញ្ញាណតាយ អលក្ខិកតាយ ឯវំ អកាសឹ ស្វាហំ សង្ឃំ ខមាបេមិ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានធ្វើអំពើយ៉ាងនេះ ដោយសេចក្ដីល្ងង់ ដោយសេចក្ដីមិនដឹង ដោយសភាពនៃខ្លួនជាអ្នកឥតបុណ្យឥតសិរី, ខ្ញុំព្រះករុណា សូមឲ្យព្រះសង្ឃអត់ទោស ។ ត្រូវសង្ឃហៅចូលមក (ឱសារណា) ដោយអបលោកនកម្ម, ឯវិធីហៅចូលមកនោះដូច្នេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវសូត្រប្រកាសកណ្ដាលជំនុំសង្ឃ ដោយអនុម័តរបស់សង្ឃថា

សង្ឃម្ភន្តេ បុច្ឆាមិ អយំ (ឥត្ថន្នាមោ) សាមណេរោ ពុទ្ធស្ស ធម្មស្ស សង្ឃស្ស អវណ្ណភាសី មិច្ឆាទិដ្ឋិកោ យំ អញ្ញេ សាមណេរា លភន្តិ ទិវត្តិរត្តិំ ភិក្ខូហិ សទ្ធិំ សហ-សេយ្យំ តស្ស អលាភាយ និស្សារិតោ ស្វាយំ ឥទានិ សោរតោ វិរតោ និវាតវុត្តិ លជ្ជិធម្មំ ឱក្កន្តោ ហិរោត្តប្បេ បតិដ្ឋិតោ កតទណ្ឌកម្មោ អច្ចយំ ទេសេតិ, ឥមស្ស សាមណេរស្ស យថាបុរេ កាយសម្ភោគសាមគ្គីទានំ រុច្ចតិ សង្ឃស្សាតិ; ទុតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ អយំ (ឥត្ថន្នាមោ) សាមណេរោ ។បេ។ រុច្ចតិ សង្ឃស្សាតិ; តតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ អយំ (ឥត្ថន្នាមោ) សាមណេរោ ។បេ។ រុច្ចតិ សង្ឃស្សាតិ *បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃថា សាមណេរ (ឈ្មោះនេះ) នេះពោលទូរទោស គឺតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រកបដោយមិច្ឆាទិដ្ឋិ យល់ខុសចាកសភាវធម៌, សាមណេរទាំងឡាយដទៃ តែងបាននូវការដេកជាមួយគ្នាណា មួយអន្លើដោយភិក្ខុទាំងឡាយអស់ត្រីពីរបី សង្ឃបានបណ្ដេញចេញហើយ (និស្សារណា) ដើម្បីមិនឲ្យបាននូវការដេកជាមួយគ្នានោះ, ឥឡូវនេះសាមណេរនោះ ត្រឡប់ជាស្លូតបូត វៀរ*

អំពើខុសនោះចេញហើយប្រព្រឹត្តទន់លំទោនបុះបិត្តក្នុងលជ្ជីធម៌ គឺធម៌របស់បុគ្គលដែលមានសេចក្ដីអៀនខ្មាស តាំងនៅក្នុងហិរិនិងឱត្តប្បៈ សង្ឃបានធ្វើទណ្ឌកម្មរួចហើយ ឥឡូវសុំដែងនូវទោសខ្លួន; ការឲ្យកាយសម្ភោគ[១]និងកាយសាមគ្គី[២] ដូចជាក្នុងកាលមុន ដល់សាមណេរនេះគាប់ចិត្តដល់សង្ឃឬទេ ? បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃជាគំរប់ពីរដងទៀតថា សាមណេរ (ឈ្មោះនេះ) នេះ ។បេ។ គាប់ចិត្តដល់សង្ឃឬទេ? បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃជាគំរប់បីដងទៀតថា សាមណេរ (ឈ្មោះនេះ) នេះ។បេ។គាប់ចិត្តដល់សង្ឃឬទេ?

អបលោកនកម្មប្រកបដោយឋានពីរគឺ ឱសារណា១ និស្សារណា ១ យ៉ាងនេះឯង ។

ចប់ឱសារណានិងនិស្សារណា

កណ្ដកកម្ម គឺការកោរសក់ទារកដែលត្រូវការចូលកាន់បព្វជ្ជាមានវិធីធ្វើអបលោកនកម្ម គឺសូត្រប្រកាសប្រាប់ភិក្ខុសង្ឃដែលនៅក្នុងអាវាសជាមុនសិន ទើបកោរសក់ជាខាងក្រោយ; មានរឿងក្នុងមហាខន្ធកៈថា:

សម័យនោះឯងមានទារកម្នាក់មានក្បាលត្រងោល ជាកូនជាងមាសឈ្មោះប្រកែកទទឹងមាតាបិតាហើយទៅកាន់អារាម ហើយបួសក្នុងសំណាក់នៃភិក្ខុទាំងឡាយ ។ ឯមាតានិងបិតារបស់ទារកនោះ កាលដែលដើរតាមរកទារកនោះ ក៏បានទៅដល់អារាម សួរភិក្ខុ

១ កាយសម្ភោគ គឺការប្រើប្រាស់ដោយកាយ ។ ២ សេចក្ដីព្រមព្រៀងដោយកាយ ។

ទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកលោកបានប្រទះឃើញទារកមានសភាពយ៉ាងនេះដែរឬ ។ ពួកភិក្ខុដែលមិនដឹងក៏ប្រាប់ថាមិនដឹង, ពួកភិក្ខុដែលមិនឃើញក៏ប្រាប់ថាមិនឃើញ ។ ឯមាតានិងបិតារបស់ទារកនោះ ដើរគយគន់មើលទៅក៏ឃើញទារកនោះបួសក្នុងសំណាក់នៃភិក្ខុទាំងឡាយ, ក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍ទាំងនេះជាបុគ្គលឥតអៀនខ្មាស ទ្រុស្តសីល និយាយពាក្យកុហក បានដឹងដែរតែនិយាយថាមិនដឹង បានឃើញដែរតែនិយាយថាមិនបានឃើញ, ទារកនេះបួសក្នុងសំណាក់ភិក្ខុទាំងឡាយហើយតើ ។

ភិក្ខុទាំងឡាយបានឮសំដីមាតានិងបិតារបស់ទារកនោះ ពោលទោសតិះដៀលបន្តុះបង្អាប់ដូច្នោះហើយ ក៏ក្រាបទូលសេចក្តីនោះបំពោះព្រះមានបុណ្យ ។ ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ សង្ឃំ អបលោកេតុំ ភណ្ឌុកម្មាយ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការប្រកាសប្រាប់សង្ឃដើម្បីភណ្ឌុកម្ម (ការកោរសក់ គឺជាប្រកាសប្រាប់សង្ឃមុន ទើបកោរសក់ជាខាងក្រោយ) ។ ឯវិធីប្រាប់ភណ្ឌុកម្មនោះដូច្នេះ ត្រូវប្រជុំពួកភិក្ខុដែលនៅក្នុងសីមាឬអាវាសជាមួយគ្នា នាំបព្វជ្ជាបេក្ខៈទៅក្នុងទីប្រជុំនោះប្រាប់ថា សង្ឃម្ភន្តេ ឥមស្ស ទារកស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមប្រាប់នូវភណ្ឌុកម្មរបស់ទារកនេះ បំពោះព្រះសង្ឃ ។

ប្រាប់ដូច្នេះបីដងឬពីរដងឬតែម្តងក៏បាន ៗ ប្រាប់ថា ឥមស្ស ទារ-
កស្ស ភណ្ឌុកម្មំ អាបុច្ឆាម "យើងសូមប្រាប់នូវកណ្ឌុកម្មរបស់
ទារកនេះ" ដូច្នេះក៏បាន ៗ ប្រាប់ថា ឥមស្ស សមណករណំ
អាបុច្ឆាម "យើងសូមប្រាប់នូវការធ្វើទារកនេះឲ្យជាសមណៈ" ដូច្នេះ
ក៏បាន ៗ ប្រាប់ថា ឥមស្ស បព្វាជនំ អាបុច្ឆាម "យើង
សូមប្រាប់នូវការបំបួសទារកនេះ" ដូច្នេះក៏បាន ៗ ប្រាប់ថា អយំ
សមណោ ហោតុកាមោ "ទារកនេះមានប្រាថ្នាដើម្បីជាសមណៈ"
ដូច្នេះក៏បាន ៗ ប្រាប់ថា អយំ បព្វជិតុកាមោ "ទារកនេះចង់បួស"
ដូច្នេះក៏គួរ ៗ បើទីនោះជាទីកន្លែងរបស់សភាគភិក្ខុមានកំណត់ភិក្ខុចំនួន
១០ រូបក្តី ២០ រូបក្តី ៣០ រូបក្តី អ្នកប្រាប់ត្រូវទៅកាន់កន្លែងឈរឬ
កន្លែងអង្គុយរបស់ភិក្ខុទាំងនោះក៏គួរ, លើកលែងតែបព្វជ្ជាបេក្ខៈនោះចេញ
ទោះបីប្រើភិក្ខុកំឡោះក៏ដោយ សាមណេរក៏ដោយ ឲ្យទៅប្រាប់ថា
ឯកោ ភន្តេ បព្វជ្ជាបេក្ខោ អត្ថិ តស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ
"បពិត្រលោកដ៏ចំរើន មានបព្វជ្ជាបេក្ខៈ ១ រូប ខ្ញុំសូមប្រាប់នូវភណ្ឌុកម្ម
របស់បព្វជ្ជាបេក្ខៈនោះ" ដូច្នេះក៏គួរ ៗ ប្រសិនបើពួកភិក្ខុខ្លះចូលទៅ
កាន់សេនាសនៈ ហើយសិងលក់ទៅក្តី ឬចូលទៅកាន់ទីមានគុម្ពឈើជា
ដើមសិងលក់ទៅក្តីឬធ្វើសមណធម៌ក្តី អ្នកប្រាប់ដើររកពុំឃើញ ត្រូវតាំង

បិតុថា "បានប្រាប់សព្វគ្រប់ហើយ" ដូច្នេះក៏បាន ។ បព្វជ្ជាកម្មជាកម្មស្រាល ព្រោះហេតុនោះកុលបុត្រដែលបានបួសរួចហើយ ឈ្មោះជាបួសហើយដោយប្រពៃ ឥតមានអាបត្តិអ្វីដល់ភិក្ខុអ្នកបំបួសឡើយ ។ បើវត្តដែលធំទូលាយមានភិក្ខុកុះករនៅច្រើន លំបាកនឹងប្រជុំគ្នាឲ្យសព្វគ្រប់ ការដើរប្រាប់តាមលំដាប់កុដិនឹងទីកន្លែងក៏រឹតតែលំបាកទៅទៀត ព្រោះហេតុនោះត្រូវនាំបព្វជ្ជាបេក្ខៈទៅបំបួសក្នុងខណ្ឌសីមា ឬទៅបំបួសក្នុងនទីសីមានឹងសមុទ្ទសីមាជាដើមក៏បាន ។ បព្វជ្ជាបេក្ខៈណាដែលទើបកោរសក់ថ្មីៗ ឬទើបនឹងសឹកចេញថ្មីៗ ឬជាពួកអ្នកបួសដទៃមាននិគ្រណ្ឋជាដើម ដែលមានសក់ខ្លីជាងពីរធ្នាប់ឬប្រវែងពីរធ្នាប់ មិនបាច់កោរសក់បព្វជ្ជាបេក្ខៈនោះទៀតឡើយ, ព្រោះហេតុនោះ បើមិនបានប្រាប់ភណ្ឌុកម្មហើយបំបួសទៅក៏គួរ; បើបព្វជ្ជាបេក្ខៈដែលមានសក់វែងជាងពីរធ្នាប់ ត្រូវប្រាប់ភណ្ឌុកម្មហើយសឹមបំបួស(១) ។

ព្រហ្មទណ្ឌ ព្រះមានព្រះភាគទ្រង់បញ្ញត្តចំពោះឆន្នត្ថេរក៏ពិតមែន ប៉ុន្តែមិនត្រឹមតែឆន្នត្ថេរប៉ុណ្ណោះទេ ទោះបីភិក្ខុដទៃ ដែលមានមាត់អាក្រក់ជេរត្មះតិះដៀលបន្តុះបង្អាប់ដោយពាក្យមិនគប្បី ចំពោះភិក្ខុផងគ្នា សង្ឃក៏ត្រូវឲ្យព្រហ្មទណ្ឌដល់ភិក្ខុនោះដែរ ។ ឯវិធីឲ្យព្រហ្មទណ្ឌនោះដូច្នេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវសូត្រប្រកាសកណ្តាលជំនុំសង្ឃ ដោយបេ

---

១ បើកុលបុត្រដែលមាតាបិតាឬជនអ្នកគ្រប់គ្រងបានអនុញ្ញាតឲ្យបួសហើយ, បានកោរសក់រួចស្រេចមកហើយ មិនចាំបាច់ប្រាប់ដោយវិធីភណ្ឌុកម្មឡើយ ។

*អនុមតិរបស់សង្ឃថា* ភន្តេ (ឥត្ថន្នាមោ) ភិក្ខុ មុខរោ ភិក្ខូ ទុរុត្តវចនេហិ ឃដេន្តោ វិហរតិ សោ ភិក្ខុ យំ ឥច្ឆេយ្យ តំ វទេយ្យ ភិក្ខូហិ (ឥត្ថន្នាមោ) ភិក្ខុ នេវ វត្តព្វោ ន ឱវទិតព្វោ ន អនុសាសិតព្វោ; សង្ឃម្ភន្តេ បុច្ឆាមិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ព្រហ្មទណ្ឌស្ស ទានំ រុច្ចតិ សង្ឃស្សាតិ; ទុតិយម្បិ បុច្ឆាមិ (ឥត្ថន្នាមស្ស) ភន្តេ ភិក្ខុនោ ព្រហ្មទណ្ឌស្ស ទានំ រុច្ចតិ សង្ឃស្សាតិ; តតិយម្បិ បុច្ឆាមិ (ឥត្ថន្នាមស្ស) ភន្តេ ភិក្ខុនោ ព្រហ្មទណ្ឌស្ស ទានំ រុច្ចតិ សង្ឃស្សាតិ

*បពិត្រព្រះសង្ឃដ៏ចំរើន ភិក្ខុ (ឈ្មោះនេះ) មានមាត់រឹង មាត់អាក្រក់ ដេរភិក្ខុផងគ្នាដោយពាក្យមិនគប្បី ភិក្ខុនោះចង់និយាយនូវពាក្យណា គប្បីនិយាយនូវពាក្យនោះចុះ ភិក្ខុទាំងឡាយមិនត្រូវដាស់តឿនក្រើនរំលឹក មិនត្រូវទូន្មាន មិនត្រូវប្រៀនប្រដៅ ភិក្ខុ (ឈ្មោះនេះ) ទេ; បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃថា ការឲ្យនូវព្រហ្មទណ្ឌដល់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់សង្ឃឬទេ? ខ្ញុំសូមសួរជាគំរប់ពីរដងទៀតថា បពិត្រព្រះសង្ឃដ៏ចំរើន ការឲ្យនូវព្រហ្មទណ្ឌដល់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់សង្ឃឬទេ? ខ្ញុំសូមសួរជាគំរប់បីដងទៀតថា បពិត្រព្រះសង្ឃដ៏ចំរើន ការឲ្យនូវព្រហ្មទណ្ឌដល់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់សង្ឃឬទេ?*

លុះសម័យជាខាងក្រោយមកទៀត កាលបើភិក្ខុនោះប្រព្រឹត្តត្រឹមត្រូវហើយ លះបង់អំពើមិនគប្បីនោះចេញហើយ បានសូមខមាទោសនឹងសង្ឃ ។ ត្រូវរម្ងាប់ព្រហ្មទណ្ឌនោះចេញ ដោយអបលោកនកម្ម ។ ឯវិធីរម្ងាប់ព្រហ្មទណ្ឌនោះដូច្នេះ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវសូត្រប្រកាសកណ្ដាលជំនុំសង្ឃថា ភន្តេ ភិក្ខុសង្ឃោ អសុកស្ស ភិក្ខុនោ ព្រហ្មទណ្ឌំ អទាសិ សោ ភិក្ខុ សោរតោ វិរតោ និវាតវុត្តិ លជ្ជិធម្មំ ឱក្កន្តោ ហិរោត្តប្បេ បតិដ្ឋិតោ បដិសង្ខា អាយតឹ សំវរេ តិដ្ឋតិ; សង្ឃម្ភន្តេ បុច្ឆាមិ តស្ស ភិក្ខុនោ ព្រហ្មទណ្ឌស្ស បដិប្បស្សទ្ធិ រុច្ចតិ សង្ឃស្សាតិ; ទុតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ តស្ស ភិក្ខុនោ ព្រហ្មទណ្ឌស្ស បដិប្បស្សទ្ធិ រុច្ចតិ សង្ឃស្សាតិ; តតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ តស្ស ភិក្ខុនោ ព្រហ្មទណ្ឌស្ស បដិប្បសទ្ធិ រុច្ចតិ សង្ឃស្សាតិ បើត្រព្រះសង្ឃដំចំរើន ភិក្ខុសង្ឃបានឲ្យព្រហ្មទណ្ឌដល់ភិក្ខុឯណោះ (១) ភិក្ខុនោះត្រឡប់ជាសូត្របួត វៀរអំពើមិន

---

១ បានជាប្រែសេចក្ដីនាមថា ឯណោះ ដូច្នេះ ព្រោះភិក្ខុដែលជាប់ព្រហ្មទណ្ឌមិនត្រូវមកកាន់ជំនុំសង្ឃទេ ដ្បិត អសម្មុខាករណីយំ កម្មដែលត្រូវធ្វើក្នុងទីកំបាំងមុខ មាន ៨ យ៉ាង គឺ

១– ទូតេន ឧបសម្បទា ឧបសម្បទាកម្មដែលទ្រង់អនុញ្ញាតដោយបញ្ជូនទូតទៅចំពោះនាងអឌ្ឍកាសីគណិកាជាហេតុ (ភិក្ខុនីខន្ធក វ.១១ប.២៥៩៩.៣៣២) ។

(តទៅទំព័រ ១៤)

គប្បីនោះចេញហើយ ប្រព្រឹត្តទន់រំពោន បុះបិត្តក្នុងលដ្ឋិធម៌ តាំងនៅក្នុងហិរិនិងឱត្តប្បៈ បានពិចារណាសព្វគ្រប់ហើយ តាំងនៅក្នុងសេចក្តីសង្រួមតទៅ; បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃថា ការរម្ងាប់នូវព្រហ្មទណ្ឌដល់ភិក្ខុនោះ គាប់ចិត្តដល់សង្ឃឬទេ ? បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃជាគំរប់ពីរដងទៀតថា ការរម្ងាប់នូវព្រហ្មទណ្ឌដល់ភិក្ខុនោះ គាប់ចិត្តដល់សង្ឃឬទេ? បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមសួរព្រះសង្ឃជាគំរប់បីដងទៀតថា ការរម្ងាប់នូវព្រហ្ម-ទណ្ឌដល់ភិក្ខុនោះ គាប់ចិត្តដល់សង្ឃឬទេ?

សង្ឃត្រូវរម្ងាប់នូវព្រហ្មទណ្ឌដោយអបលោកនកម្មយ៉ាងនេះឯង ។

---

២- បត្តនិក្កុជ្ជនា ការផ្កាប់បាត្រដែលសង្ឃត្រូវធ្វើដល់គ្រហស្ថដែលប្រព្រឹត្តខុសទាស់នឹងភិក្ខុសង្ឃ ។

៣ - បត្តុក្កុជ្ជនា ការផ្ងារបាត្រដែលត្រូវធ្វើដល់គ្រហស្ថដែលបានត្រឡប់ប្រព្រឹត្តត្រឹមត្រូវចំពោះសង្ឃហើយ ។

៤- ឧម្មត្តកស្ស ភិក្ខុនោ ឧម្មត្តកសម្មតិ ការសន្មតិឲ្យច្បាស់ជាជាបុគ្គលឆ្កួត ដល់ភិក្ខុដែលឆ្កួត ។

៥- សេក្ខានំ កុលានំ សេក្ខសម្មតិ ការសន្មតិឲ្យច្បាស់ជាជាសេក្ខបុគ្គល ដល់សេក្ខ-ត្រកូល ។

៦- ឆន្នស្ស ភិក្ខុនោ ព្រហ្មទណ្ឌោ ព្រហ្មទណ្ឌដែលសង្ឃត្រូវឲ្យដល់ឆន្នភិក្ខុ ។

៧- ទេវទត្តស្ស បកាសនីយកម្មំ បកាសនីយកម្មដែលសង្ឃត្រូវធ្វើដល់ទេវទត្ត (សង្ឃភេទក្ខន្ធក ភ. ១១. ប. ២៦ ទ. ២៨) ។

៨- អប្បាសាទិកំ ទស្សេន្តស្ស ភិក្ខុនោ ភិក្ខុនីសង្ឃេន កាតព្វំ អវន្ទិយកម្មំ អវន្ទិយ-កម្មដែលភិក្ខុនីសង្ឃត្រូវធ្វើដល់ភិក្ខុដែលបង្ហាញនូវអាវយវៈដែលមិនគួរឲ្យកើតសេចក្តីជ្រះថ្លា ។

កម្មលក្ខណា មានក្នុងភិក្ខុនីខន្ធកៈថា សម័យនោះឯងពួកឆព្វគ្គិយភិក្ខុយកកក់ទឹកទៅបាចសាចលើភិក្ខុនីទាំងឡាយ ដោយបំណងចង់ឲ្យភិក្ខុនីត្រេកអរស្រឡាញ់ខ្លួន ហើយក៏បើកកាយបង្ហាញភិក្ខុនី បើកភ្លៅបង្ហាញភិក្ខុនី បើកអង្គជាតបង្ហាញភិក្ខុនី និយាយចែចង់ភិក្ខុនី ចេះតែមានការទាក់ទងនឹងភិក្ខុនី ដោយបំណងចង់ឲ្យភិក្ខុនីត្រេកអរស្រឡាញ់ខ្លួន ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តនូវអាបត្តិទុក្កដ ព្រោះរឿងហេតុនោះ ហើយទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ តស្ស ភិក្ខុនោ ទណ្ឌកម្មំ កាតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការធ្វើទណ្ឌកម្មដល់ភិក្ខុនោះ ។ ទើបកើតសេចក្ដីសង្ស័យឡើងថា ទណ្ឌកម្មត្រូវធ្វើដូចម្ដេចហ្ន៎ ? ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតអវន្ទិយកម្មថា អវន្ទិយោ សោ ភិក្ខវេ ភិក្ខុ ភិក្ខុនីសង្ឃេន កាតព្វោ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ភិក្ខុនីសង្ឃត្រូវធ្វើឲ្យជាបុគ្គលដែលភិក្ខុនីមិនគួរសំពះ ។ អវន្ទិយកម្មនោះហៅថា កម្មលក្ខណៈ ព្រោះថាអវន្ទិយកម្មនោះឯង ជាលក្ខណៈរបស់អបលោកនកម្មនោះ, ឯកម្មទាំងឡាយមានឱសារណាជាដើម មិនមែនជាលក្ខណៈរបស់អបលោកនកម្មនោះទេ ។

វិធីធ្វើនូវអវន្ទិយកម្ម មួយទៀតដោយការរម្ងាប់នូវអវន្ទិយកម្មនោះ មានសេចក្ដីពិស្ដារដូចតទៅនេះ ភិក្ខុនីអ្នកឈ្លាសប្រតិពល ត្រូវសូត្រប្រកាសដោយអនុមតិរបស់ភិក្ខុនីសង្ឃ ដែលប្រជុំគ្នាក្នុងលំនៅនៃភិក្ខុនីថា

អយ្យេ អសុកោ នាម អយ្យោ ភិក្ខុនីនំ អប្បាសាទិកំ ទស្សេតិ; ឯតស្ស អយ្យស្ស អវន្ទិយករណំ រុច្ចតីតិ ភិក្ខុនីសង្ឃំ បុច្ឆាមិ; អយ្យេ អសុកោ នាម អយ្យោ ភិក្ខុនីនំ អប្បាសាទិកំ ទស្សេតិ; ឯតស្ស អយ្យស្ស អវន្ទិយករណំ រុច្ចតីតិ ទុតិយម្បិ ភិក្ខុនីសង្ឃំ បុច្ឆាមិ; អយ្យេ អសុកោ នាម អយ្យោ ភិក្ខុនីនំ អប្បាសាទិកំ ទស្សេតិ; ឯតស្ស អយ្យស្ស អវន្ទិយករណំ រុច្ចតីតិ តតិយម្បិ ភិក្ខុនីសង្ឃំ បុច្ឆាមិ ខ្ញុំសូមសួរភិក្ខុនីសង្ឃថា បពិត្រនាងជាម្ចាស់ លោកម្ចាស់ឈ្មោះឯណោះបង្ហាញនូវអវយវៈមិនគួរឲ្យកើតសេចក្ដីជ្រះថ្លាដល់ភិក្ខុនីទាំងឡាយ, ការធ្វើនូវលោកម្ចាស់នុ៎ះឲ្យជាបុគ្គលដែលភិក្ខុនីមិនគួរសំពះ គាប់ចិត្តឬទេ ? ខ្ញុំសូមសួរភិក្ខុនីសង្ឃជាគំរប់ពីរដងទៀតថា បពិត្រនាងជាម្ចាស់ ។ ល ។ គាប់ចិត្តឬទេ ? ខ្ញុំសូមសួរភិក្ខុនីសង្ឃជាគំរប់បីដងទៀតថា បពិត្រនាងជាម្ចាស់ ។ល។ គាប់ចិត្តឬទេ ?

ភិក្ខុនីសង្ឃត្រូវធ្វើអវន្ទិយកម្មដោយអបលោកនកម្មយ៉ាងនេះឯង ។

ចាប់ដើមតាំងពីកាលនោះមក ភិក្ខុនីទាំងឡាយមិនត្រូវសំពះភិក្ខុនោះឡើយ, ភិក្ខុនោះ កាលបើភិក្ខុនីលែងសំពះ ក៏កើតហិរិឱត្តប្បៈឡើង ប្រព្រឹត្តវត្តត្រឹមត្រូវ ហើយសូមខមាទោសនឹងភិក្ខុនី; កាលដែលសូម

ខមាទោសនោះ មិនត្រូវទៅកាន់លំនៅភិក្ខុនីឡើយ ត្រូវចូលទៅរកសង្ឃ ឬភិក្ខុមួយរូប ក្នុងវត្តដែលខ្លួននៅ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង សូមខមាទោសថា អហម្ភន្តេ បដិសង្ខា អាយតឹ សំវរេ តិដ្ឋាមិ ន បុន អប្បាសាទិកំ ទស្សេស្សាមិ ភិក្ខុនីសង្ឃេ មយ្ហំ ខមតុ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា បានពិចារណាសព្វគ្រប់ ហើយ តាំងនៅក្នុងសេចក្តីសង្រួមតទៅ ឈប់លែងសំដែងនូវអវយវៈ មិនគួរឲ្យគេឥតសេចក្តីជ្រះថ្លាតទៅទៀត, សូមភិក្ខុនីសង្ឃអត់ទោសដល់ខ្ញុំព្រះករុណា ។ សង្ឃនោះក្តី គណៈនោះក្តី ត្រូវប្រើភិក្ខុមួយរូបឲ្យទៅនិយាយនឹងភិក្ខុនី ឬភិក្ខុមួយរូបនោះទៅនិយាយនឹងភិក្ខុនីខ្លួនឯងថា អយ្យំ ភិក្ខុ បដិសង្ខា អាយតឹ សំវរេ ឋិតោ ឥមិនា អប្បយំ ទស្សេត្វា ភិក្ខុនីសង្ឃេ ខមាបិតោ ភិក្ខុនីសង្ឃោ ឥមំ វន្ទិយំ ករោតុ ភិក្ខុនេះ បានពិចារណាសព្វគ្រប់ហើយ តាំងនៅក្នុងសេចក្តីសង្រួមតទៅ ភិក្ខុនេះសំដែងនូវទោស ហើយសូមខមាទោសនឹងភិក្ខុនីសង្ឃ សូមភិក្ខុនីសង្ឃធ្វើនូវភិក្ខុនេះឲ្យជាបុគ្គលដែលភិក្ខុនីគួរសំពះ ។ ភិក្ខុនោះភិក្ខុនីសង្ឃគួរធ្វើឲ្យជាបុគ្គលដែលភិក្ខុនីគួរសំពះ ត្រូវធ្វើដូចតទៅនេះ ភិក្ខុនីអ្នកឈ្លាសប្រតិពល ត្រូវសូត្រប្រកាសដោយអនុមតិរបស់ភិក្ខុនីសង្ឃថា អយ្យេ អសុកោ នាម អយ្យោ ភិក្ខុនីនំ អប្បាសាទិកំ ទស្សេតិ

ភិក្ខុនីសង្ឃេន អវន្ទិយោ កតោ សោ លទ្ធិធម្មំ ឱក្កមិត្វា បដិសង្ខា អាយតិំ សំវរេ ឋិតោ អច្ចយំ ទេសេត្វា ភិក្ខុនីសង្ឃំ ខមាបេសិ តស្ស អយ្យស្ស វន្ទិយករណំ វុច្ចតីតិ ភិក្ខុនីសង្ឃំ បុច្ឆាមិ ខ្ញុំសូមសួរភិក្ខុនីសង្ឃថា បពិត្រនាងជាម្ចាស់ លោកម្ចាស់ឈ្មោះឯណោះបង្ហាញនូវអវយវៈ មិនគួរឲ្យកើតសេចក្ដីជ្រះថ្លាដល់ពួកភិក្ខុនី លោកម្ចាស់នោះ ភិក្ខុនីសង្ឃបានធ្វើឲ្យជាបុគ្គលដែលភិក្ខុនីមិនគួរសំពះ បានឈានចុះកាន់លទ្ធិធម៌ បានពិចារណាសព្វគ្រប់ តាំងនៅក្នុងសេចក្ដីសង្រួមតទៅ សំដែងនូវទោសហើយ សូមខមាទោសនឹងភិក្ខុនីសង្ឃ ការធ្វើនូវលោកម្ចាស់នោះ ឲ្យជាបុគ្គលដែលភិក្ខុនីគួរសំពះវិញ គាប់ចិត្តឬទេ ? ( សូត្រ ៣ដង ) ។

ភិក្ខុនីសង្ឃត្រូវធ្វើភិក្ខុឲ្យជាបុគ្គលដែលភិក្ខុនីគួរសំពះ ដោយអបលោកនកម្មយ៉ាងនេះឯង ។ អវន្ទិយកម្មនេះ ហៅថាកម្មលក្ខណមានភិក្ខុនីសង្ឃជាមូល ព្រោះមានព្រះភាគទ្រង់បញ្ញត្តហើយ តែជាសាធារណៈទាក់ទងដល់ភិក្ខុសង្ឃផង ព្រោះថាភិក្ខុសង្ឃធ្វើអបលោកនកម្មណា ក្នុងរោងស្លាកក្ដី ក្នុងរោងបបរក្ដី ក្នុងរោងភត្តក្ដី ក្នុងរោងឧបោសថក្ដី អបលោកនកម្មនុះ ហៅថាកម្មលក្ខណៈដែរ ព្រោះថាភិក្ខុអ្នកឈ្លាសប្រតិពល បានប្រជុំសង្ឃស្សូត្រប្រកាសបីដងធ្វើអបលោកនកម្ម ឲ្យចីវរដល់ភិក្ខុដែលមានចីវរត្រូវចោរដណ្ដើមយកទៅក្ដី ដែលមានចីវរចាស់គ្រាំគ្រាក្ដី ដែលមានចីវរវិនាសទៅក្ដី ក៏គួរ ។

មួយវិញទៀត អប្បមត្តកវិស្សជ្ជកភិក្ខុ គឺភិក្ខុជាអ្នកលះបង់នូវវត្ថុបន្តិចបន្តួចដែលបានសម្មតិអំពីសង្ឃហើយ ត្រូវឲ្យវត្ថុបន្តិចបន្តួចមានម្ជុលជាដើម ដល់ភិក្ខុកំពុងធ្វើចីវរ ដោយមិនបាច់ធ្វើអបលោកនកម្ម ព្រោះជាអប្បមត្តកវិស្សជ្ជកភិក្ខុនោះជាធំក្នុងការឲ្យ នូវវត្ថុមានម្ជុល(១)ជាដើមនោះ បើវត្ថុដែលច្រើនជាងនោះ ត្រូវតែធ្វើអបលោកនកម្មទើបឲ្យបាន ព្រោះជា សង្ឃជាធំក្នុងការឲ្យនូវវត្ថុដែលច្រើនៗ ។

ចំណែកគិលានភេសជ្ជ(២)បន្តិចបន្តួច ក៏ត្រូវឲ្យដោយខ្លួនឯងបាន បើច្រើនជាងនោះ ត្រូវធ្វើអបលោកនកម្មទើបឲ្យបាន បច្ច័យឯទៀតៗ ក៏មានទំនងដូចគ្នាដែរ ។

ចប់អបលោកនកម្ម

## ញត្តិកម្ម

### ញត្តិកម្មមានឋាន៩ គឺ ឱសារណា ១ និស្សារណា ១

១ របស់បន្តិចបន្តួច ដែលត្រូវឲ្យដោយមិនបាច់ធ្វើអបលោកនកម្មនោះគឺ សូចិ ម្ជុល, សត្ថកំ កាំបិតតូច, ឧបាហនា ស្បែកជើង, បរិស្សាវនំ សំពត់តម្រងទឹក, ធម្មករកោ ធម្មក្រក, កុសិ សំពត់ខ្នងវែង, អឌ្ឍកុសិ សំពត់ខ្នងខ្លី, មណ្ឌលំ សំពត់មណ្ឌលធំ, អឌ្ឍមណ្ឌលំ សំពត់មណ្ឌលតូច, អនុវាតោ អនុវាតខ្នង ឬ អនុវាតបណ្ដោយ, បរិភណ្ឌំ អនុវាតពោះ ឬ អនុវាតទទឹង (សេនាសនក្ខន្ធកៈ) ។ ២ ចំណែកភេសជ្ជៈគឺ សប្បិ ទឹកដោះរាវ, តេលំ ប្រេង ឬ ខ្លាញ់, មធុ ទឹកឃ្មុំ, ផាណិតំ ស្ករអំពៅ និងស្ករជាអនុលោម ។ ភេសជ្ជៈទាំងនេះ ឲ្យតែម្ដងក៏បាន ឲ្យញយ ៗ ក៏បាន មិនបាច់ធ្វើអបលោកនកម្ម (សេនាសនក្ខន្ធកៈ) ។

ឱបោសថ ១ បវារណា ១ សម្មតិ ១ ទាន ១ បដិគ្គហ ១ បច្ចុក្កឌ្ឍនា ១ កម្មលក្ខណា ១ ។

ឱសារណា ប្រែថា ការហៅចូលមក គឺហៅចូលដោយវិធីតាំងញត្តិថា សុណាតុ មេ ភន្តេ សង្ឃោ (ឥត្ថន្នាមោ) (ឥត្ថន្នាមស្ស) អាយស្មតោ ឧបសម្បទាបេក្ខោ អនុសិដ្ឋោ សោ មយា យទិ សង្ឃស្ស បត្តកល្លំ (ឥត្ថន្នាមោ) អាគច្ឆេយ្យ អាគច្ឆាហីតិ វត្តព្វោ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (បុគ្គលឈ្មោះនេះ) ជាឧបសម្បទាបេក្ខៈ របស់លោកអ្នកមានអាយុ (ឈ្មោះនេះ); ឧបសម្បទាបេក្ខៈនោះ ខ្ញុំបានប្រៀនប្រដៅហើយ, បើឧបសម្បទាកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ, (បុគ្គលឈ្មោះនេះ) ដែលខ្ញុំត្រូវហៅថា អ្នកត្រូវចូលមកដូច្នេះ គប្បីចូលមក ។ ការហៅនូវឧបសម្បទាបេក្ខៈឲ្យចូលមកយ៉ាងនេះហៅថា ឱសារណា ។

និស្សារណា ប្រែថា ការបណ្ដេញ មានវិធីតាំងញត្តិដូច្នេះ សុណាន្តុ មេ អាយស្មន្តា អយំ (ឥត្ថន្នាមោ) ភិក្ខុ ធម្មកថិកោ ឥមស្ស នេវ សុត្តំ អាគច្ឆតិ នោ សុត្តវិភង្គោ សោ អត្ថំ អសល្លក្ខេត្វា ព្យញ្ជនច្ឆាយាយ អត្ថំ បដិពាហតិ

យទាយស្មន្តានំ បត្តកល្លំ (ឥត្ថន្នាមំ) ភិក្ខុំ វិញ្ញាបេត្វា អវសេសា ឥមំ អធិករណំ វូបសមេយ្យាម សូមលោកអ្នកមានអាយុទាំងឡាយស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះជាធម្មកថិក មាតិកាមិនបានស្ទាត់ដល់ភិក្ខុនេះ ទាំងការចែកមាតិកាក៏មិនស្ទាត់ដែរ ភិក្ខុនោះមិនស្គាល់អត្ថ ឃាត់បង់នូវអត្ថ តាមស្រមោលព្យញ្ជនៈ បើវិញ្ញាបនកម្មមានកាលដ៏សមគួរដល់លោកអ្នកមានអាយុទាំងឡាយហើយ យើងទាំងឡាយដ៏សេស គប្បីញុំាងភិក្ខុ (ឈ្មោះនេះ) ឲ្យក្រោកចេញ ហើយរម្ងាប់នូវអធិករណ៍នេះ ។ ការបណ្តេញនូវភិក្ខុជាធម្មកថិក ក្នុងឧព្វាហិកវិនិច្ឆ័យ(១)យ៉ាងនេះហៅថា និស្សារណា ។

ឧបោសថ មានវិធីតាំងញត្តិដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេយ្យ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ថ្ងៃនេះ ជាថ្ងៃឧបោសថទី ១៥ បើឧបោសថកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើនូវឧបោសថ ។ ញត្តិដែលភិក្ខុបានតាំងឡើង តាមទំនងឧបោសថកម្មយ៉ាងនេះ ហៅថា ឧបោសថ ។

---

១ ការវិនិច្ឆ័យនូវអធិករណ៍ដោយសូត្រប្រកាសប្រាប់ឲ្យសម្ងាត់មាត់ គឺមិនឲ្យនិយាយគ្នាក្នុងពេលវេលាជំនុំជំរះអធិករណ៍ ។

បវារណា មានវិធីតាំងញត្តិដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជ បវារណា បណ្ណរសី យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ថ្ងៃនេះ ជាថ្ងៃបវារណាទី ១៥ បើបវារណាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីបវារណា ។ ញត្តិដែលភិក្ខុតាំងឡើងតាមទំនងបវារណាកម្មយ៉ាងនេះហៅថា បវារណា ។

សម្មុតិ ការសន្មតិ មាន២យ៉ាងគឺ ខ្លួនឯងសន្មតខ្លួនឯង១ ខ្លួនឯងសន្មតអ្នកដទៃ១, ឯវិធីសន្មតនោះដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ (ឥត្ថន្នាមោ(១)) (ឥត្ថន្នាមស្ស(២)) អាយស្មតោ ឧបសម្បទាបេក្ខោ យទិ សង្ឃស្ស បត្តកល្លំ អហំ (ឥត្ថន្នាមំ) អនុសាសេយ្យំ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បុគ្គល (ឈ្មោះនេះ) ជាឧបសម្បទាបេក្ខៈ របស់លោកអ្នកមានអាយុ (ឈ្មោះនេះ) បើឧសម្បទាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំគប្បីប្រៀនប្រដៅនូវបុគ្គល (ឈ្មោះនេះ) ។ យ៉ាងនេះហៅថាខ្លួនឯងសន្មតខ្លួនឯង; . . . យទិ សង្ឃស្ស បត្តកល្លំ (ឥត្ថន្នាមោ)

---

១ - ២ ត្រង់ ឥត្ថន្នាមោ ឥត្ថន្នាមស្ស នេះត្រូវបញ្ចូលនាមឧបសម្បទាបេក្ខទាំងនាមឧបជ្ឈាយ៍ជាភាសាបាលី ដូចជា នាគោ តិស្សស្ស ឬ ពុទ្ធរក្ខិតោ ធម្មរក្ខិតស្ស, បន្ទោសុរិយស្ស ជាដើម ។

(ឥត្ថន្នាមំ) អនុសាសេយ្យំ បើឧបសម្បទាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ភិក្ខុ (ឈ្មោះនេះ) គប្បីប្រៀនប្រដៅនូវបុគ្គល (ឈ្មោះនេះ) ។ យ៉ាងនេះ ហៅថាខ្លួនឯងសន្មតអ្នកដទៃ; . . . យទិ សង្ឃស្ស បត្តកល្លំ អហំ (ឥត្ថន្នាមំ) អន្តរាយិកេ ធម្មេ បុច្ឆេយ្យំ បើឧបសម្បទាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវអន្តរាយិកធម៌ទាំងឡាយ ចំពោះបុគ្គល (ឈ្មោះនេះ) ។ យ៉ាងនេះ ហៅថា ខ្លួនឯងសន្មតខ្លួនឯងដែរ; ... យទិ សង្ឃស្ស បត្តកល្លំ (ឥត្ថន្នាមោ) (ឥត្ថន្នាមំ) អន្តរាយិកេ ធម្មេ បុច្ឆេយ្យ បើឧបសម្បទាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ភិក្ខុ (ឈ្មោះនេះ) គប្បីសួរនូវអន្តរាយិកធម៌ទាំងឡាយ ចំពោះបុគ្គល (ឈ្មោះនេះ) ។ យ៉ាងនេះហៅថា ខ្លួនឯងសន្មតអ្នកដទៃដែរ; . . . យទិ សង្ឃស្ស បត្តកល្លំ អហំ (ឥត្ថន្នាមំ) វិនយំ បុច្ឆេយ្យំ បើសង្គីតិកម្ម(១)មានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវវិន័យចំពោះភិក្ខុ (ឈ្មោះនេះ) ។ យ៉ាងនេះក៏ហៅថា ខ្លួនឯងសន្មតខ្លួនឯងដែរ; . . . យទិ សង្ឃស្ស បត្តកល្លំ (ឥត្ថន្នាមោ) (ឥត្ថន្នាមំ) វិនយំ បុច្ឆេយ្យ បើសង្គីតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ភិក្ខុ (ឈ្មោះនេះ) គប្បីសួរនូវវិន័យចំពោះភិក្ខុ (ឈ្មោះនេះ) ។ យ៉ាងនេះក៏ហៅថា ខ្លួនឯងសន្មតអ្នកដទៃដែរ; . . .

---

១ ត្រូវប្រែចេញឈ្មោះកម្មដែលសង្ឃធ្វើ ។

យទិ សង្ឃស្ស បត្តល្លំ អហំ (ឥត្ថន្នាមេន) វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំត្រូវភិក្ខុ (ឈ្មោះនេះ) សួរនូវវិន័យ គប្បីដោះស្រាយតទៅ ។ យ៉ាងនេះក៏ហៅថា ខ្លួនឯងសន្មតខ្លួនឯងដែរ; . . . យទិ សង្ឃស្ស បត្តកល្លំ (ឥត្ថន្នាមោ) (ឥត្ថន្នាមេន) វិនយំ បុដ្ឋោ វិស្សជ្ជេយ្យ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ភិក្ខុ (ឈ្មោះនេះ) ត្រូវភិក្ខុ (ឈ្មោះនេះ) សួរនូវវិន័យ គប្បីដោះស្រាយតទៅ ។ យ៉ាងនេះក៏ហៅថា ខ្លួនឯងសន្មតអ្នកដទៃដែរ ។ ញត្តិដែលភិក្ខុតាំងឡើង ដើម្បីសន្មតនូវខ្លួនឯងឬអ្នកដទៃ យ៉ាងនេះហៅថា សម្មតិ ។

ទានៈ ការឲ្យនូវបរិក្ខារ មានចីវរនឹងបាត្រជាដើម ដែលភិក្ខុលះបង់ដល់សង្ឃឬគណៈ ដោយវិធីតាំងញត្តិដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ ចីវរំ (ឥត្ថន្នាមស្ស) ភិក្ខុនោ និស្សគ្គិយំ សង្ឃស្ស និស្សដ្ឋំ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ ចីវរំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទទេយ្យ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ចីវរនេះរបស់ភិក្ខុ (ឈ្មោះនេះ) ជានិស្សគ្គិយៈ បានលះបង់ដល់សង្ឃហើយ បើវិនយកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវចីវរនេះដល់ភិក្ខុ (ឈ្មោះនេះ) វិញ ។ នេះជាវិធីលះដល់សង្ឃ ១ ត្រូវធ្វើញត្តិប្រគល់ឲ្យវិញថា

សុណាតុ មេ អាយស្មន្តា ឥមំ ចីវរំ (ឥត្ថន្នាមស្ស) ភិក្ខុនោ និស្សគ្គិយំ អាយស្មន្តានំ និស្សដ្ឋំ យទាយស្មន្តានំ បត្តកល្លំ អាយស្មន្តា ឥមំ ចីវរំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទទេយ្យុំ

*សូមលោកអ្នកមានអាយុទាំងឡាយ ស្តាប់ពាក្យខ្ញុំ ចីវរនេះរបស់ភិក្ខុ (ឈ្មោះនេះ) ជានិស្សគ្គិយៈ បានលះបង់ហើយដល់លោកអ្នកមានអាយុទាំងឡាយ បើវិនយកម្មមានកាលដ៏សមគួរដល់លោកអ្នកមានអាយុទាំងឡាយហើយ លោកអ្នកមានអាយុទាំងឡាយ គប្បីឲ្យនូវចីវរនេះដល់ភិក្ខុ (ឈ្មោះនេះ) វិញ ។ នេះជាវិធីលះបង់ដល់គណៈ គឺភិក្ខុ ៣ រូប, គណៈធ្វើញត្តិប្រគល់ឲ្យវិញ ។ ការឲ្យនូវបរិក្ខារមានចីវរនិងបាត្រជាដើម ដែលភិក្ខុលះបង់ដល់សង្ឃឬគណៈ យ៉ាងនេះហៅថា ទានៈ ។*

*បដិគ្គហា ការទទួលនូវអាបត្តិរបស់ភិក្ខុដែលសំដែងអាបត្តិដូច្នេះ*

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ អាបត្តឹ សរតិ វិវរតិ ឧត្តានីករោតិ ទេសេតិ យទិ សង្ឃស្ស បត្តកល្លំ អហំ (ឥត្ថន្នាមស្ស) ភិក្ខុនោ អាបត្តឹ បដិគ្គណ្ហេយ្យំ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ រលឹកនូវអាបត្តិ បើកនូវអាបត្តិ ធ្វើអាបត្តិឲ្យងាយ គឺជាសំដែងអាបត្តិ បើវិនយកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំ*

គប្បីទទួលនូវអាបត្តិរបស់ភិក្ខុ (ឈ្មោះនេះ) ។ នេះជាវិធីសំដែងអាបត្តិចំពោះសង្ឃ, សង្ឃត្រូវចាត់ភិក្ខុមួយរូបអ្នកឈ្លាសប្រតិពលឲ្យទទួលអាបត្តិដោយតាំងញត្តិថា សុណាតុ មេ អាយស្មន្តា អយំ (ឥត្ថន្នាមោ) ភិក្ខុ អាបត្តឹ សរតិ វិវរតិ ឧត្តានីករោតិ ទេសេតិ យទាយស្មន្តានំ បត្តកល្លំ អហំ (ឥត្ថន្នាមស្ស) ភិក្ខុនោ អាបត្តឹ បដិគ្គណ្ហេយ្យំ សូមលោកអ្នកមានអាយុទាំងឡាយស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ រលឹកនូវអាបត្តិ បើកនូវអាបត្តិ ធ្វើអាបត្តិឲ្យងាយ គឺជាសំដែងអាបត្តិ បើវិនយកម្មមានកាលដ៏សមគួរដល់លោកអ្នកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីទទួលនូវអាបត្តិរបស់ភិក្ខុ (ឈ្មោះនេះ) ។ នេះជាវិធីសំដែងអាបត្តិចំពោះគណៈ គឺភិក្ខុបីរូប[1]ភិក្ខុ ១ រូបអ្នកឈ្លាសវៃទទួលអាបត្តិដោយវិធីតាំងញត្តិ; ភិក្ខុអ្នកទទួលអាបត្តិត្រូវសួរថា បស្សសិ លោកឃើញឬ? ភិក្ខុអ្នកសំដែងគប្បីប្រាប់ថា អាម បស្សាមិ ករុណា! ខ្ញុំឃើញ ។ ភិក្ខុអ្នកទទួលអាបត្តិគប្បីដាស់តឿនថា អាយតឹ សំវរេយ្យាសិ លោកគប្បីសង្រួមតទៅណា:! ការទទួលអាបត្តិយ៉ាងនេះហៅថា បដិគ្គហ ។

បច្ចុក្កឌ្ឍនា ការលើកទាញបវារណាយកទៅដាក់ថ្ងៃខាងមុខដោយវិធីតាំងញត្តិថា សុណាតុ មេ អាយស្មន្តា អាវាសិកា

---

១ គណៈ គឺភិក្ខុ ២ រូបមិនមានវិធីតាំងញត្តិទេ ។

យទាយស្មន្តានំ បត្តកល្លំ ឥទានិ ឧបោសថំ ករេយ្យាម បាតិមោក្ខំ ឧទ្ទិសេយ្យាម អាគមេ កាលេ បវារេយ្យាម

សូមអាវុសោភិក្ខុ(១)ទាំងឡាយអ្នកមានអាយុស្តាប់ពាក្យខ្ញុំ បើបត្តកល្លនាកម្មមានកាលដ៏សមគួរ ដល់លោកអ្នកមានអាយុទាំងឡាយហើយ ឥឡូវនេះយើងទាំងឡាយគប្បីធ្វើនូវឧបោសថ គប្បីសំដែងនូវបាតិមោក្ខ គប្បីបវារណាក្នុងកាលជាខាងមុខ (ឯណោះ) ។ សេចក្តីនេះព្រះមានព្រះភាគទ្រង់ត្រាស់ថា បើមានភិក្ខុកើតវិវាទទាស់ទែងគ្នា ដល់ថ្ងៃបវារណា ត្រូវឈប់បវារណា ទាញយកទៅដាក់ថ្ងៃខាងមុខវិញ ថ្ងៃបវារណានោះ ត្រូវធ្វើឧបោសថកម្មសំដែងបាតិមោក្ខ ត្រូវតាំងញត្តិទាញបវារណាយកទៅដាក់ឯថ្ងៃខាងមុខដូចបានពោលមកហើយ ។ ការលើកទាញនូវបវារណាដែលសង្ឃបានធ្វើហើយយ៉ាងនេះហៅថា បច្ចុក្កឌ្ឍនា ។

កម្មលក្ខណា មានវិធីធ្វើដោយតាំងញត្តិដូចតទៅនេះ ភិក្ខុទាំងឡាយដែលកើតវិវាទទាស់ទែងគ្នានោះបានប្រជុំគ្នាលើកបវារណាយកទៅដាក់ថ្ងៃខាងមុខហើយ ភិក្ខុទាំងអស់នោះត្រូវប្រជុំគ្នាតែក្នុងកន្លែងមួយ លុះប្រជុំគ្នារួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវតាំងញត្តិផ្ទៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ

---

១ ភិក្ខុដែលនៅក្នុងអាវាសជាប្រក្រតី ។

ភាសិតបរិកន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេយ្យាម(១) សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ ភេទាយ សំវត្តេយ្យ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ អធិករណំ តិណវត្ថារកេន វូបសមេយ្យ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ យើងទាំងឡាយមានការបង្កហេតុ បង្កើតជម្លោះ ដល់នូវវិវាទទាស់ទែងគ្នា បានប្រព្រឹត្តនូវអំពើមិនមែនជារបស់សមណៈជាច្រើន បាននិយាយដោយវាចា បានព្យាយាមធ្វើដោយកាយ បើយើងទាំងឡាយគប្បីធ្វើនូវគ្នានឹងគ្នា ដោយអាបត្តិទាំងឡាយនេះ អធិករណ៍នោះក៏នឹងចេះតែមានទៅដដែល អធិករណ៍នោះថែមទាំងគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីសេចក្តីសាហាវ ដើម្បីបែកគ្នា បើរូបសមនកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់នូវអធិករណ៍នេះ ដោយតិណវត្ថារកសមថ(២) លើកលែងតែទោសដែលធ្ងន់(៣) លើកលែងតែ*

---

១ បាលីខ្លះថា ការេយ្យាម ខ្លះថា ការេស្សាម បំណែកសេចក្តីប្រហែលគ្នាទេ ។
២ វិធីរម្ងាប់អធិករណ៍ឲ្យស្ងប់ដូចគេយកកម្រាលស្មៅទៅគ្របលាមកកុំឲ្យស្អុយពេក ។ ៣ សំដៅយកអាបត្តិបារាជិកនិងសង្ឃាទិសេស ។

ទោសដែលទាក់ទងដោយគ្រហស្ថ[១] ។ សព្វសង្គាហិកញត្តិ[២]ញត្តិដែលរួបរួមទាំងអស់មុនគេបង្អស់ ដែលសង្ឃបានធ្វើដោយតិណវត្ថារកសមថៈយ៉ាងនេះហៅថា កម្មលក្ខណា ។ តពីនេះទៅទៀត តាំងញត្តិផ្សេងគ្នា គឺពួក១ តាំងញត្តិ១ ពួកមួយទៀតតាំងញត្តិមួយដែរ ត្រូវជាញត្តិពីរ ឯញត្តិទាំងពីរនោះដូចគ្នាទាំងអស់ មិនប្លែកគ្នាទេ, តាំងញត្តិថា

សុណាតុ មេ អាយស្មន្តា អម្ហាកំ ភណ្ឌនជាតានំ កលហជា-
តានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ
ភាសិតបរិកន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ
ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡត្តាយ
ភេទាយ សំវត្តេយ្យ យទាយស្មន្តានំ បត្តកល្លំ អហំ យា ចេវ
អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ អាយស្មន្តានញ្ចេវ
អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេ-
យ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ សូមលោកអ្នកមានអាយុទាំងឡាយស្តាប់ពាក្យខ្ញុំ យើងទាំងឡាយមានការបង្កហេតុ

---

១ អាបត្តិដែលភិក្ខុត្រូវ ព្រោះតិះដៀលបន្តុះបង្អាប់គ្រហស្ថដោយពាក្យដ៏ថោកទាបនឹងធម្មិកប្បដិស្សវៈគឺពាក្យប្តេជ្ញាប្រកបដោយធម៌ ។ ២ សព្វសង្គាហិកញត្តិនេះកើតឡើងព្រោះពួកភិក្ខុទាស់ទែងគ្នាបំរុគនឹងបែកគ្នាជា ២ ពួក ទើបភិក្ខុទាំង ២ ពួកប្រជុំគ្នាធ្វើសព្វសង្គាហិកញត្តិ " រួបរួមគ្នាទាំងពីរពួកតាំងញត្តិយ៉ាងនេះដើម្បីរម្ងាប់អធិករណ៍ដោយតិណវត្ថារកៈ ។

បង្កើតជម្លោះ ដល់នូវវិវាទទាស់ទែងគ្នា ប្រព្រឹត្តនូវអំពើមិនមែនជារបស់សមណៈជាច្រើន បានពោលដោយវាចា បានព្យាយាមធ្វើដោយកាយ បើយើងទាំងឡាយញ៉ាំងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ អធិ-ករណ៍នោះក៏នឹងបេះតែនៅមានដដែល អធិករណ៍នោះ ថែមទាំងគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្ដីរឹងរូស ដើម្បីសេចក្ដីសាហាវ ដើម្បីបែកគ្នា បើទេសនាកម្មមានកាលដ៏សមគួរដល់លោកអ្នកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីសំដែងនូវអាបត្តិរបស់លោកអ្នកមានអាយុទាំងឡាយផង នូវអាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្ដាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ លើកលែងតែទោសដែលថ្លោស លើកលែងតែទោសដែលទាក់ទងដោយគ្រហស្ថ ។ ភិក្ខុពួកមួយពួកទៀត ក៏តាំងញត្តិមួយដូចគ្នានឹងញត្តិនេះដែរ ត្រូវជាញត្តិពីរ ។ ឯអានិសង្សនៃញត្តិទាំងឡាយនេះ នឹងមាននិយាយខាងមុខ ក្នុងញត្តិទុតិយកម្មកថា ។

ចប់ញត្តិកម្ម

## ញត្តិទុតិយកម្ម

ញត្តិទុតិយកម្ម ប្រែថា កម្មមានញត្តិជាគំរប់ពីរ, កម្មនោះមានឋាន ៧ គឺ ឱសារណា ១ និស្សារណា ១ សម្មតិ ១ ទាន ១ ឧទ្ធារ ១ ទេសនា ១ កម្មលក្ខណា ១ ។

និស្សារណា មានក្នុងខុទ្ទកវត្ថុក្ខន្ធកៈថា ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យសង្ឃផ្កាប់បាត្រ(១)ចំពោះគ្រហស្ថម្នាក់ឈ្មោះវឌ្ឍលិច្ឆវី ។ ឱសារណា ព្រះអង្គទ្រង់អនុញ្ញាតឲ្យសង្ឃផ្ងារបាត្រ (២) ឡើងចំពោះវឌ្ឍលិច្ឆវីនោះឯង, ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកដែលប្រកបដោយអង្គ ៨ គឺ ឧបាសកព្យាយាមដើម្បីឲ្យភិក្ខុខានបានលាភ ១ ព្យាយាមដើម្បីឲ្យភិក្ខុខានបានប្រយោជន៍ ១ ព្យាយាមដើម្បីឲ្យភិក្ខុខានបានអាវាស ១ ជេរគំរាមភិក្ខុ ១ ញុំាងភិក្ខុឲ្យបែកបាក់ភិក្ខុផងគ្នា ១ ពោលនូវទោសនៃព្រះពុទ្ធ ១ ពោលនូវទោសនៃព្រះធម៌ ១ ពោលនូវទោសនៃព្រះសង្ឃ ១ សង្ឃត្រូវផ្កាប់បាត្រ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការផ្កាប់បាត្រដល់ឧបាសកដែលប្រកបដោយអង្គ ៨ នេះ; ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្កាប់បាត្រយ៉ាងនេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ វឌ្ឍោ លិច្ឆវី អាយស្មន្តំ ទព្វំ មល្លបុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ និក្កុជ្ជេយ្យ. អសម្ភោគំ សង្ឃេន ករេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ វឌ្ឍោ លិច្ឆវី អាយស្មន្តំ ទព្វំ មល្ល-បុត្តំ អមូលិកាយ សីលវិបត្តិយា អនុទ្ធំសេតិ សង្ឃោ វឌ្ឍស្ស

---

១ បត្តនិក្កុជ្ជនា ។ ២ បត្តុក្កុជ្ជនា ។

លិច្ឆវិស្ស បត្តំ និក្កុជ្ជតិ អសម្ភោគំ សង្ឃេន ករោតិ យស្សាយស្មតោ ខមតិ វឌ្ឍស្ស លិច្ឆវិស្ស បត្តស្ស និក្កុជ្ជនា អសម្ភោគំ សង្ឃេន ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ និក្កុជ្ជិតោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ អសម្ភោគំ សង្ឃេន ករណំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ វឌ្ឍលិច្ឆវីហោទនូវព្រះទព្វមល្លបុត្រអ្នកមានអាយុ ដោយសីលវិបត្តិ(១)មិនមានមូល បើបត្តនិក្កុជនាកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី គប្បីធ្វើនូវវឌ្ឍលិច្ឆវីឲ្យជាបុគ្គលមិនមានការប្រើប្រាស់ ជាមួយនឹងសង្ឃ(២) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ វឌ្ឍលិច្ឆវីហោទនូវព្រះទព្វមល្លបុត្រអ្នកមានអាយុ ដោយសីលវិបត្តិមិនមានមូល ( ឥឡូវ ) សង្ឃផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី ធ្វើវឌ្ឍលិច្ឆវីឲ្យជាបុគ្គលមិនមានការប្រើប្រាស់ ជាមួយនឹងសង្ឃ ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី ការធ្វើនូវវឌ្ឍលិច្ឆវីឲ្យជាបុគ្គលមិនមានការប្រើប្រាស់ជាមួយនឹងសង្ឃ គាប់ចិត្តដល់លោកអ្នក*

---

១ ចោទដោយអាបត្តិបារាជិក និងសង្ឃាទិសេស ហៅថាចោទដោយសីលវិបត្តិ ។

២ សម្ភោគ ការប្រើប្រាស់មានពីរយ៉ាង គឺ អាមិសសម្ភោគ ការប្រើប្រាស់ដោយអាមិសៈ គឺបច្ច័យ ៤ មួយ, ធម្មសម្ភោគ ការប្រើប្រាស់ដោយធម៌ ១ គ្រហស្ថដែលមិនបានប្រគេនបច្ច័យដល់សង្ឃ ទាំងមិនបានស្ដាប់ធម៌ក្នុងសំណាក់នៃភិក្ខុសង្ឃ ហៅថា មិនបានការប្រើប្រាស់ជាមួយនឹងសង្ឃ ។

មានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម បើមិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ បាត្រសង្ឃបានផ្កាប់ដល់វត្ថុលិច្ឆវីហើយ ទាំងការធ្វើនូវវត្ថុលិច្ឆវីឲ្យជាបុគ្គលមិនមានការប្រើប្រាស់ជាមួយនឹងសង្ឃ ការផ្កាប់-បាត្រនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំ-ទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ការបណ្ដេញនូវវត្ថុលិច្ឆវីដោយវិធីផ្កាប់បាត្រ ដោយសូត្រញត្តិ-ទុតិយកម្មវាចាយ៉ាងនេះហៅថា និស្សារណា ។

ព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យសង្ឃធ្វើញត្តិទុតិយកម្មផ្ងារបាត្រឡើងវិញ បំពោះគ្រហស្ថដែលប្រព្រឹត្តខុសពាស់ហើយ ត្រឡប់ប្រព្រឹត្តត្រឹមត្រូវឡើងវិញ, រឿងរ៉ាវទាក់ទងដោយវត្ថុលិច្ឆវីនោះឯង, ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្ងារបាត្រដល់ឧបាសកដែលប្រកបដោយអង្គ ៨ គឺ ឧបាសកមិនព្យាយាមដើម្បីឲ្យភិក្ខុខានបានលាភ១ មិនព្យាយាមដើម្បីឲ្យភិក្ខុខានបានប្រយោជន៍ ១ ។ ល ។ មិនពោលនូវទោសនៃព្រះសង្ឃ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការផ្ងារបាត្រ ដល់ឧបាសកដែលប្រកបដោយអង្គ ៨ នេះឯង; ម្នាលភិក្ខុទាំងឡាយ ត្រូវផ្ងារបាត្រយ៉ាងនេះ វត្ថុលិច្ឆវីនោះ ត្រូវចូលមករកសង្ឃ ធ្វើសំពត់ដណ្ដប់ឆៀងស្មាម្ខាងថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលថា សង្ឃេន មេ ភន្តេ

បត្តោ និក្កុជ្ជិតោ អសម្ភោគោម្ហិ សង្ឃេន សោហំ ភន្តេ សម្មា វត្តាមិ លោមំ បាតេមិ នេត្ថារំ វត្តាមិ សង្ឃំ បត្តុក្កុជ្ជនំ យាចាមិ *បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃបាន ផ្កាប់បាត្រដល់ខ្ញុំព្រះករុណាហើយ ខ្ញុំព្រះករុណាជាបុគ្គលមិនមានការប្រើប្រាស់ជាមួយនឹងសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណានោះ ប្រព្រឹត្តត្រឹមត្រូវឡើងវិញ សម្របរោម ប្រព្រឹត្តនូវអំពើគួរដល់ការរលាស់ចេញចាកទោស ខ្ញុំព្រះករុណាសូមនូវការផ្ងារបាត្រចំពោះសង្ឃ (សូត្រ ៣ ដង) ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា*

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ និក្កុជ្ជិតោ អសម្ភោគោ សង្ឃេន សោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ សង្ឃ បត្តុក្កុជ្ជនំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ ឧក្កុជ្ជេយ្យ សម្ភោគំ សង្ឃេន ករេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ និក្កុជ្ជិតោ អសម្ភោគោ សង្ឃេន សោ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ សង្ឃំ បត្តុក្កុជ្ជនំ យាចតិ សង្ឃោ វឌ្ឍស្ស លិច្ឆវិស្ស បត្តំ ឧក្កុជ្ជតិ សម្ភោគំ

សង្ឃេន ករោតិ យស្សាយស្មតោ ខមតិ វឌ្ឍស្ស លិច្ឆវិស្ស បត្តស្ស ឧក្កុជ្ជនា សម្ភោគំ សង្ឃេន ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧក្កុជ្ជិតោ សង្ឃេន វឌ្ឍស្ស លិច្ឆវិស្ស បត្តោ សម្ភោគំ សង្ឃេន ករណំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

*បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សង្ឃបានផ្កាប់បាត្រដល់វឌ្ឍលិច្ឆវីហើយ វឌ្ឍលិច្ឆវីនោះមិនមានការប្រើប្រាស់ជាមួយនឹងសង្ឃទេ (ឥឡូវ) ប្រព្រឹត្តត្រឹមត្រូវ សមុបពេម ប្រព្រឹត្តនូវអំពើគួរដល់ការរលាស់ចេញចាកទោស សូមនូវការផ្ងារបាត្រចំពោះសង្ឃ បើឧក្កុជ្ជនាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីផ្ងារបាត្រដល់វឌ្ឍលិច្ឆវីវិញ គប្បីធ្វើវឌ្ឍលិច្ឆវីឲ្យជាបុគ្គលមានការប្រើប្រាស់ជា-មួយនឹងសង្ឃវិញ នេះហៅថា ញត្តិ ។*

*បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សង្ឃបានផ្កាប់បាត្រដល់វឌ្ឍលិច្ឆវីហើយ វឌ្ឍលិច្ឆវីនោះមិនមានការប្រើប្រាស់ជា-មួយនឹងសង្ឃទេ (ឥឡូវ) ប្រព្រឹត្តត្រឹមត្រូវ សមុបពេម ប្រព្រឹត្តនូវអំពើគួរដល់ការរលាស់ចេញចាកទោស សូមនូវការផ្ងារបាត្រចំពោះសង្ឃ សង្ឃផ្ងារបាត្រដល់វឌ្ឍលិច្ឆវី ធ្វើវឌ្ឍលិច្ឆវីឲ្យជាបុគ្គលមានការប្រើប្រាស់ជាមួយនឹងសង្ឃ ការផ្ងារបាត្រដល់វឌ្ឍលិច្ឆវី តាំងធ្វើវឌ្ឍលិច្ឆវីឲ្យជា*

បុគ្គលមានការប្រើប្រាស់ជាមួយនឹងសង្ឃវិញ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះគប្បីស្ងៀម បើមិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះគប្បីនិយាយឡើង ។ សង្ឃបានផ្ងារបាត្រដល់វត្ថុលិច្ឆវីហើយ តាំងការធ្វើនូវវត្ថុលិច្ឆវីឲ្យជាបុគ្គលមានការប្រើប្រាស់ជាមួយនឹងសង្ឃវិញ ការផ្ងារបាត្រនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ ការហៅចូលមកតាមទំនងផ្ងារបាត្រយ៉ាងនេះហៅថា ឱសារណា ។

បណ្ដាអង្គទាំង ៨ ដូចបាននិយាយមកហើយនោះ គ្រហស្ថដែលប្រកបដោយអង្គសូម្បីតែមួយ សង្ឃក៏គួរធ្វើកម្មផ្កាប់បាត្របានដែរ ការដែលធ្វើកម្មផ្កាប់បាត្រនោះគួរធ្វើក្នុងសីមាឬចេញទៅក្រៅសីមា ទៅធ្វើក្នុងទីទាំង-ឡាយមានស្ទឹងនិងសមុទ្ទជាដើមក៏បាន ។ កាលបើសង្ឃបានផ្កាប់បាត្រយ៉ាងនេះ ទេយ្យធម៌សូម្បីបន្តិចបន្តួចក្នុងផ្ទះរបស់គ្រហស្ថនោះភិក្ខុសង្ឃមិនត្រូវទទួលយកឡើយ សង្ឃត្រូវផ្សាយដំណឹងទៅវត្តដទៃៗ កុំឲ្យភិក្ខុសង្ឃដទៃទទួលយកចង្ហាន់ក្នុងផ្ទះរបស់គ្រហស្ថនោះ ; កាលដែលធ្វើកម្មផ្ងារបាត្រត្រូវឲ្យគ្រហស្ថនោះសូត្រសូម៣ដង កុំឲ្យលះបង់ហត្ថបាសឡើយ ត្រូវឲ្យអង្គុយជាប់ហត្ថបាសជាមួយនឹងសង្ឃហើយសឹមសូត្រសូម ;(១) សង្ឃត្រូវធ្វើកម្មផ្ងារបាត្រដោយវិធីសូត្រញត្តិទុតិយកម្មវាចា ដូចបានពោលមកហើយ ។

---

១ សូត្រសូមរួចហើយ ត្រូវចេញទៅក្រៅជំនុំសង្ឃ ។

សម្មតិ  សង្ឃត្រូវធ្វើតាមចំនួនបែបបទនៃសម្មតិទាំងឡាយដូចមានតទៅនេះគឺ  សីមាសម្មតិ  ការសន្មតិសីមា ១ តិចីវរាវិប្បវាសសម្មតិ  ការសន្មតិមិនឲ្យមានអាបត្តិព្រោះនៅប្រាសចាកត្រៃចីវរ១ សន្ថតសម្មតិ  ការសន្មតិនូវសំពត់សន្ថត១  ភត្តុទ្ទេសកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកសំដែងនូវភត្ត ១ សេនាសនគ្គាហាបកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់នូវសេនាសនៈ១  ចីវរប្បដិគ្គាហកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកទទួលចីវរ ១  ភណ្ឌាគារិ(១)យសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជានាយឃ្លាំងជាអ្នករក្សាឃ្លាំង ១ ចីវរភាជកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកចីវរ ១  យាគុភាជកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកបបរ ១  ខជ្ជកភាជកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកចំណី(បង្អែម)១ អប្បមត្តកវិស្សជ្ជកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកលះបង់បរិក្ខារបន្តិចបន្តួចតូចតាច ១  សាដិយគ្គាហាបកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់នូវសំពត់ ១  បត្តគ្គាហាបកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់បាត្រ ១  អារាមិកបេសកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រើញោមវត្ត ១  សាមណេរបេសកសម្មតិ  ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រើសាមណេរ១; សម្មតិទាំងឡាយ

---

១ បាលីក្នុងទីនេះថា ភណ្ឌាគារិក ។

មានដូច្នេះជាដើម សង្ឃត្រូវធ្វើដោយញត្តិទុតិយកម្មវាចា ។

សីមាសម្មតិ មានរឿងក្នុងឧបោសថក្ខន្ធកថា ពួកឆព្វគ្គិយភិក្ខុសំដែងបាតិមោក្ខ តាមបរិស័ទរបស់ខ្លួន, ព្រះមានព្រះភាគទ្រង់បញ្ញត្តថា ភិក្ខុមិនត្រូវសំដែងបាតិមោក្ខតាមបរិស័ទរបស់ខ្លួនទេ ភិក្ខុណាសំដែង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ហើយទ្រង់អនុញ្ញាតនូវឧបោសថកម្មដល់ពួកភិក្ខុដែលព្រមព្រៀងគ្នា ។ ទើបភិក្ខុទាំងឡាយមានសេចក្ដីសង្ស័យថា ព្រះអង្គអនុញ្ញាតនូវឧបោសថកម្មដល់ពួកភិក្ខុដែលព្រមព្រៀងគ្នា ព្រមព្រៀងនោះតើមិនដឹងជាព្រមព្រៀងត្រឹមណា ព្រមព្រៀងតែក្នុងអាវាសមួយ ឬក៏ព្រមព្រៀងលើផែនដីទាំងអស់ ? ទើបព្រះអង្គទ្រង់អនុញ្ញាតថា ការព្រមព្រៀងនោះ ព្រមព្រៀងចំពោះតែក្នុងអាវាសមួយ ៗ ប៉ុណ្ណោះទេ ។ ទើបពួកភិក្ខុកើតមានសេចក្ដីសង្ស័យទៀតថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតថា ព្រមព្រៀងគ្នាតែក្នុងអាវាសមួយប៉ុណ្ណោះទេ អាវាសមួយនោះទៀតសោតក៏មិនដឹងជាកំណត់ត្រឹមណា ? ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យសន្មតសីមា ដើម្បីឲ្យមានទីកំណត់សម្រាប់ធ្វើសង្ឃកម្មមានឧបោសថកម្មជាដើម ដោយសេចក្ដីព្រមព្រៀងយកសីមានោះជាទីកំណត់ ការកំណត់សីមានោះត្រូវសួរនិមិត្តជាមុន ឯនិមិត្តនោះមាន ៨ យ៉ាងគឺ បព្វតនិមិត្ត យកភ្នំជានិមិត្ត១ បាសាណនិមិត្ត យកថ្មជានិមិត្ត១ វននិមិត្ត យកព្រៃជានិមិត្ត ១ រុក្ខនិមិត្ត យកឈើជានិមិត្ត ១

មគ្គនិមិត្ត យកផ្លូវជានិមិត្ត ១ វម្មិកានិមិត្ត យកដំបូកជានិមិត្ត ១
នទីនិមិត្ត យកនទីជានិមិត្ត១ ឧទកានិមិត្ត យកទឹកជានិមិត្ត១ ។
កាលបើសួរនិមិត្តរួចស្រេចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃ
ថា សុណាតុ មេ ភន្តេ សង្ឃោ យាវតា សមន្តា និមិត្តា កិត្តិតា
យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឯតេហិ និមិត្តេហិ សីមំ
សម្មន្នេយ្យ សមានសំវាសំ ឯកុបោសថំ ឯសា ញត្តិ ។
សុណាតុ មេ ភន្តេ សង្ឃោ យាវតា សមន្តា និមិត្តា កិត្តិតា
សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នតិ សមានសំវាសំ
ឯកុបោសថំ យស្សាយស្មតោ ខមតិ ឯតេហិ និមិត្តេហិ
សីមាយ សម្មតិ សមានសំវាសាយ ឯកុបោសថាយ សោ
តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា
សីមា[1] សង្ឃេន ឯតេហិ និមិត្តេហិ សមានសំវាសា
ឯកុបោសថា ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ
បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ និមិត្តទាំងឡាយ
ជុំវិញទាំងប៉ុន្មាន ដែលសង្ឃបានកំណត់ហើយ គឺថាបានសួរបញ្ជាក់
រួចហើយ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បី

---

១ តាមទម្លាប់ខ្លះថា សម្មតា សា សីមា ប៉ុន្តែក្នុងវិន័យបិដកមិនមាន សា ទេ ។

សន្មតនូវសីមាឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនុ៎ះ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ និមិត្តទាំងឡាយជុំវិញទាំងប៉ុន្មាន ដែលសង្ឃបានកំណត់ហើយ គឺថាបានសួរបញ្ជាក់រួចហើយ ( ឥឡូវ ) សង្ឃសន្មតនូវសីមាឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនុ៎ះ ការសន្មតិនូវសីមាឲ្យមានសំវាសស្មើគ្នា មានឧបោសថជា-មួយគ្នាដោយនិមិត្តទាំងឡាយនុ៎ះ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សីមាសង្ឃបានសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជា-មួយគ្នា ដោយនិមិត្តទាំងឡាយនុ៎ះ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

សីមាដែលសង្ឃសន្មតយ៉ាងនេះហៅថា សមានសំវាសសីមា សម្រាប់ធ្វើសង្ឃកម្ម មានឧបោសថកម្មជាដើម ដោយព្រមព្រៀងគ្នា; បើក្នុងសីមាមួយធ្វើសង្ឃកម្ម មានភិក្ខុខ្លះមិនចូលមកកាន់ហត្ថបាសជាមួយគ្នាទេ កម្មនោះជា អធម្មកម្ម មិនកើតជាសង្ឃកម្មឡើយ, បើមានភិក្ខុខ្លះមិនបានចូលមកកាន់ហត្ថបាសទេ ប៉ុន្តែបាននាំឆន្ទៈនឹងបារិសុទ្ធិមកដល់ជុំនុំសង្ឃ កម្មនោះក៏សម្រេចត្រឹមត្រូវតាមធម៌ ។

តពីនោះមកទៀត ពួកឆព្វគ្គិយភិក្ខុបានដឹងថា ព្រះមានព្រះភាគទ្រង់បានអនុញ្ញាតសីមាសម្មតិរួចហើយ ក៏នាំគ្នាសន្មតសីមាធំពេកចំនួន ៤ យោជន៍ខ្លះ ៥ យោជន៍ខ្លះ ពួកភិក្ខុដែលនាំគ្នាមកធ្វើឧបោសថកម្មខ្លះមកដល់គេកំពុងសំដែងបាតិមោក្ខ ខ្លះគេសំដែងបាតិមោក្ខរួចទៅហើយទើបមកដល់ ។ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តថា មិនត្រូវសន្មតសីមាឲ្យធំពេកទេ បើសន្មតត្រូវអាបត្តិទុក្កដ ។ ទើបទ្រង់អនុញ្ញាតឲ្យសន្មតសីមាយ៉ាងធំបំផុតត្រឹម ៣ យោជន៍ ។

សម័យជាខាងក្រោយមកទៀត ព្រះមហាកស្សបនិមន្តអំពីស្រុកឈ្មោះអន្ធកវិន្ទមកកាន់ក្រុងរាជគ្រឹះ ដើម្បីធ្វើឧបោសថកម្ម, ឆ្លងស្ទឹងពាក់កណ្តាលផ្លូវត្រូវខ្សែទឹកគួចទៅបន្តិចក៏ទទឹកចីវរលោកអស់ ។ ពួកភិក្ខុឃើញហើយសួរថា ហេតុអ្វីបានជាទទឹកចីវរអស់ដូច្នេះ ? ព្រះមហា-កស្សបក៏ប្រាប់តាមដំណើរ ដោយសព្វគ្រប់ ។ ពួកភិក្ខុក្រាបទូលរឿងនោះចំពោះព្រះមានព្រះភាគ, ព្រះអង្គទ្រង់ត្រាស់ថា សីមាណាដែលសង្ឃបានសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ សង្ឃចូរសន្មតនូវសីមានោះឲ្យជា តិចីវរាវិប្បវាសសីមា ថែមទៀតចុះ ត្រូវសន្មតយ៉ាងនេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា យទិ សង្ឃស្ស

បត្តកល្លំ សង្ឃោ តំ សីមំ តិចីវរេនអវិប្បវាសំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា សង្ឃោ តំ សីមំ តិចីវរេនអវិប្បវាសំ សម្មន្នតិ យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ តិចីវរេនអវិប្បវាសាយ សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា សា សីមា សង្ឃេន តិចីវរេនអវិប្បវាសា ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សីមាណាដែលសង្ឃសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវសន្មតនូវសីមានោះឲ្យជា តិចីវរាវិប្បវាសសីមា[1] ថែមទៀត នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សីមាណាដែលសង្ឃសន្មតហើយឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ ( ឥឡូវ ) សង្ឃសន្មតនូវសីមានោះឲ្យជា តិចីវរាវិប្បវាសសីមា ថែមទៀត ការសន្មតិនូវសីមានេះឲ្យជា តិចីវរាវិប្បវាសសីមា គាប់–

---

១ សីមាដែលមានសិទ្ធិឲ្យភិក្ខុនៅប្រាសចាកត្រៃចីវរ គឺឲ្យនៅឃ្លាតឆ្ងាយពីចីវរទាំង៣ផ្ទាំង ចីវរណាមួយឲ្យកន្លងរាត្រីបាន ។

ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សីមានោះសង្ឃបានសន្មតឲ្យជាតិចីវរាវិប្បវាសសីមា ហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

សីមានេះសម្រាប់ទុកចីវរ ភិក្ខុអាចនៅប្រាសចាកចីវរបាន, ដូចជាសីមាមួយមានអាកាសពីរគឺអាកាសឈ្មោះ ខេមវ័ន១ អាកាសឈ្មោះសុខវ័ន ១ ភិក្ខុទុកចីវរក្នុងអាកាសខេមវ័នទៅសឹងនៅក្នុងអាកាសសុខវ័នឲ្យអរុណរះឡើងក្នុងអាកាសសុខវ័ន ចីវរក៏មិនជានិស្សគ្គិយ ភិក្ខុក៏មិនត្រូវអាបត្តិបាចិត្តិយទេ ព្រោះបានព្រុទ្ធានុញ្ញាតដោយអវិប្បវាសសីមារួចហើយ បើទុកជាមិនមែនអាកាសសោះក៏ដោយឲ្យតែសីមាជាមួយគ្នាក៏អាចទុកដាក់ត្រៃចីវរបាន នៅប្រាសចាកត្រៃចីវរណាមួយបាន ។

លុះសម័យជាខាងក្រោយមកទៀត ពួកភិក្ខុដឹងថាព្រះមានព្រះភាគទ្រង់អនុញ្ញាត តិចីវរាវិប្បវាសសម្មតិ រួចហើយ ក៏នាំគ្នាទុកចីវរក្នុងផ្ទះរបស់គេ, ចីវរទាំងនោះបាត់ទៅខ្លះ ភ្លើងឆេះខ្លះ កណ្ដុរកាត់ខ្លះ, ភិក្ខុទាំងនោះមានចីវរអាក្រក់សៅហ្មងពុំសមគួរដល់សមណៈ, ព្រះមានព្រះភាគទ្រង់ជ្រាបហើយ ក៏ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

សីមាណាដែលសង្ឃបានសន្មតហើយឲ្យមានសំវាសស្មើគ្នា មានឧបោ-សថជាមួយគ្នានោះ សង្ឃប្ដូរសន្មតនូវសីមានោះ ឲ្យជា តិចីវរាវិប្ប-វាសសីមា (ផងទៀត) ចុះ វៀរលែងតែស្រុកនិងឧបចាររបស់ស្រុកចេញ គឺជាកន្លែងដែលហៅថាស្រុកនិងឧបចាររបស់ស្រុកមិនមែនជាអវិប្បវាសសីមាឡើយ, កន្លែងផុតអំពីស្រុកនិងឧបចាររបស់ស្រុកទើបជាអវិប្បវាសសីមា ។ ត្រូវសន្មតយ៉ាងនេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ដៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ សីមំ តិចីវរេន-អវិប្បវាសំ សម្មន្នេយ្យ ឋបេត្វា គាមញ្ច គាមូបចារញ្ច ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា សង្ឃោ តំ សីមំ តិចីវរេនអវិប្បវាសំ សម្មន្នតិ ឋបេត្វា គាមញ្ច គា-មូបចារញ្ច យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ តិចីវរេនអវិប្បវាសាយ សម្មតិ ឋបេត្វា គាមញ្ច គាមូបចារញ្ច សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា

សា សីមា សង្ឃេន តិចីវរេនអវិប្បវាសា ឋបេត្វា គាមញ្ច គាមូបចារញ្ច ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សីមាណាដែលសង្ឃបានសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវសីមានោះឲ្យជា តិចីវរាវិប្បវាសសីមា វៀរលែងតែស្រុកនឹងឧបចាររបស់ស្រុកចេញ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សីមាណាដែលសង្ឃបានសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ ( ឥឡូវ ) សង្ឃសន្មតនូវសីមានោះឲ្យជា តិចីវរាវិប្បវាសសីមា វៀរលែងតែស្រុកនឹងឧបចាររបស់ស្រុកចេញ ការសន្មតិនូវសីមាឲ្យជា តិចីវរាវិប្បវាសសីមា វៀរលែងតែស្រុកនឹងឧបចាររបស់ស្រុកចេញ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម ( បើ ) មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សីមានោះសង្ឃបានសន្មតហើយ ឲ្យជា តិចីវរាវិប្បវាសសីមា វៀរលែងតែស្រុកនឹងឧបចាររបស់ស្រុកចេញ ការសន្មតិនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

សីមានេះសម្រាប់ទុកចីវរ នៅប្រាសចាកចីវរបានដូចមុន លើកលែងតែស្រុកនឹងឧបចាររបស់ស្រុកចេញ ដែលជាប្រទេសមិនមែនជាកន្លែងទុកចីវរនៅប្រាសចាកចីវរពុំបានឡើយ ដូចជាសីមាមួយមានទំហំ ៣យោជន៍ សង្ឃបានសន្មត សមានសំវាសសីមា រួចហើយ បានសន្មតអវិប្បវាសសីមាថែមទៀត, ក្នុងសីមានោះ ត្រង់ណាដែលជាស្រុកនឹងឧបចាររបស់ស្រុក ត្រង់នោះមិនមែនជា អវិប្បវាសសីមា ទេ ភិក្ខុទុកចីវរនៅប្រាសចាកចីវរពុំបានឡើយ ទុកបាន នៅប្រាសបាន តែទីកន្លែងដែលមិនមែនជាស្រុក មិនមែនឧបចាររបស់ស្រុក ។

អ្នកប្រាជ្ញអំពីបុរាណ លោកមានសេចក្តីរង្កៀសថា ព្រះពុទ្ធានុញ្ញាតថា ឲ្យភិក្ខុសង្ឃចងអវិប្បវាសសីមា វៀរលែងតែស្រុក នឹងឧបចាររបស់ស្រុកចេញ, ចុះដូចជាប្រទេសខ្មែរសព្វថ្ងៃនេះ វត្តទីមួយ ៗ តាំងនៅកណ្តាលស្រុកមានផ្ទះអ្នកស្រុកជុំវិញវត្ត ក្បែរ ៗ វត្តក៏មាន សង្ឃសន្មតអវិប្បវាសសីមា ដូចម្តេចកើត បើព្រះពុទ្ធានុញ្ញាតថាលើកលែងទៅហើយ ? ចំណែកខាងសមានសំវាសសីមា មិនមានខុសទាស់ទេ ចុះខាងអវិប្បវាសសីមា ដូចជាទាស់នឹងពុទ្ធានុញ្ញាត ក្រែងមិនកើតជាសីមា ក្រែងសង្ឃប្រើការពុំកើតទេដឹង? ដោយហេតុនេះ បានជាអ្នក-ប្រាជ្ញអំពីបុរាណ គេឧបាយយកអំណាចព្រះមហាក្សត្រិយ៍ជាម្ចាស់ផែន-ដីមកដោះស្រាយបញ្ហានេះ គឺមុនកវត្ត ត្រូវតែសូមព្រះរាជានុញ្ញាត

សូមព្រះរាជទានព្រះហស្តលេខានៃព្រះមហាក្សត្រិយ៍ជាម្ចាស់ផែនដីសិន ដោយផ្ដាច់ការថា ទីដីវត្តឈ្មោះនោះ មិនមែនជាស្រុកមិនមែនឧបចាររបស់ស្រុកទេ យើងជាមហាក្សត្រិយ៍បានប្រគេនដល់សង្ឃផ្ដាច់ការពេញអំណាចហើយ សូមឲ្យសង្ឃកំណត់ថាជាដីវត្តរបស់សង្ឃចុះ ឲ្យសន្មតសីមាតាមមតិរបស់សង្ឃចុះ ។ ការបានព្រះរាជានុញ្ញាតប៉ុណ្ណេះទុកថាជាស្រេច ពុំគួរមានសេចក្ដីរង្កៀសអ្វីតទៅទៀតឡើយ, ប៉ុន្តែ បើទុកជាដូច្នេះ ក៏គង់នៅមានការសូមព្រះរាជានុញ្ញាតសន្មតសីមា ដែលហៅថាសូមព្រះរាជានុញ្ញាតបញ្ចុះសីមានោះថែមម្ដងទៀត ដើម្បីឲ្យជ្រះស្រឡះចិត្ត ទាំងដើម្បីឲ្យបានថ្វាយព្រះរាជកុសល ចំពោះព្រះមហាក្សត្រិយ៍ជាម្ចាស់ផែនដីផង ដោយទ្រង់បានព្រះរាជទានទីដីជា វិសុំគាម គឺជាទីដីផ្សេងពីស្រុកនិងឧបចារនៃស្រុក ឲ្យដាច់ស្រឡះមកជាទីដីរបស់សង្ឃក្នុងព្រះពុទ្ធសាសនា ពុំឲ្យមានជាប់ពន្ធដារសួយសារអាករអ្វីឡើយ(១) ។ មួយទៀត ក្នុងសម័យយើងសព្វថ្ងៃនេះ សង្ឃពេញចិត្តតែការសន្មតិខណ្ឌសីមា គឺសីមាតូច (២) មិនបានការទាក់ទងដល់ស្រុកនិងឧបចារនៃស្រុកទេ ជាការណ៍ផុតស្រឡះពីសេចក្ដីរង្កៀសហើយ ។

---

១ ការសូមព្រះរាជានុញ្ញាតបញ្ចុះសីមានេះ បើព្រះមហាក្សត្រិយ៍ទ្រង់ប្រោសព្រះរាជទានអនុញ្ញាតឲ្យលើកលែងហើយ ពុំចាំបាច់សូមទៀតទេ ។ ២ ខណ្ឌសីមា ដែលតូចបំផុត កុំឲ្យតែភិក្ខុ ២១ រូបអង្គុយមិនចុះ ដើម្បីកុំឲ្យធ្វើអព្ភានកម្មមិនកើត ព្បិតអព្ភានកម្មនោះត្រូវមានភិក្ខុសង្ឃជាគណបូរកៈយ៉ាងតិចត្រឹម ២០ រូប ជា ២១ រូបទាំងភិក្ខុដែលសង្ឃត្រូវឲ្យអព្ភានកម្មនោះផង ។

មួយវិញទៀត ការសន្មតិសីមានោះត្រូវសន្មត សមានសំវាសសីមា ជាមុន ទើបសន្មត តិចីវរាវិប្បវាសសីមា ជាខាងក្រោយ វេលាដែលដកវិញត្រូវដកតិចីវរាវិប្បវាសសីមាជាមុន ទើបដកសមានសំវាសសីមាជាខាងក្រោយ, ឯវិធីដកនោះដូច្នេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ យោ សោ សង្ឃេន តិចីវរេនអវិប្បវាសោ សម្មតោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ តិចីវរេនអវិប្បវាសំ សមូហនេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ យោ សោ សង្ឃេន តិចីវរេនអវិប្បវាសោ សម្មតោ សង្ឃោ តំ តិចីវរេនអវិប្បវាសំ សមូហនតិ យស្សាយស្មតោ ខមតិ ឯតស្ស តិចីវរេនអវិប្បវាសស្ស សមុគ្ឃាតោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សមូហតោ សោ សង្ឃេន តិចីវរេនអវិប្បវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ តិចីវរាវិប្បវាសសីមាណា ដែលសង្ឃបានសន្មតហើយនោះ បើសមូហនកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវដកនូវតិចីវរាវិប្បវាសសីមានោះចេញ នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ តិចីវរាវិប្បវាសសីមាណា ដែលសង្ឃបានសន្មតហើយនោះ (ឥឡូវ) សង្ឃដកនូវតិចីវរាវិប្បវាសសីមានោះ ការដកនូវតិចីវរាវិប្បវាសសីមានេះ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ តិចីវរាវិប្បវាសសីមានោះសង្ឃបានដកហើយ ការដកនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

វិធីដកតិចីវរាវិប្បវាសសីមាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ សីមំ សមូហនេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា សង្ឃោ តំ សីមំ សមូហនតិ យស្សាយស្មតោ ខមតិ ឯតិស្សា សីមាយ សមានសំវាសាយ ឯកុបោសថាយ សមុគ្ឃាតោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ។ សមូហតា សា សីមា សង្ឃេន សមានសំវាសា ឯកុ-

ឃោសហិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សីមាណាដែលសង្ឃបានសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ បើសមូហនកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវដកសីមានោះចេញ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សីមាណាដែលសង្ឃបានសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ (ឥឡូវ) សង្ឃដកនូវសីមានោះចេញ. ការដកនូវសីមាដែលមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានេះ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ សង្ឃបានដកហើយ ការដកនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

នេះជាវិធីដកសមានសំវាសសីមា ។ ឯវិធីដកសីមាទាំងពីរយ៉ាងនេះមិនត្រូវតាមទំនងបែបបទញត្តិទុតិយកម្មដែលកំពុងនិយាយអំពីសម្មតិនេះទេ ប៉ុន្តែបានជានាំមកនិយាយក្នុងទីនេះផង ដ្បិតវិធីដកសីមានឹងវិធីសម្មតិសីមាជាប់ទាក់ទងគ្នា ព្រោះហេតុនោះ សូមបញ្ជាក់ម្តងទៀតថា វិធីធ្វើសីមាឲ្យគ្រប់លក្ខណៈនោះ ត្រូវដកអវិប្បវាសសីមាជាមុនហើយដក

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

សមានសំវាសសីមាជាបន្ទាប់គ្នា ហើយសួរនិមិត្តជុំវិញឲ្យតាមសព្វគ្រប់(១) ហើយសន្មតសមានសំវាសសីមាជាមុន ទើបសន្មតតិចីវរាវិប្បវាសសីមាជាខាងក្រោយ ។ ចប់ការសន្មតិសីមាត្រឹមនេះ ។ ការសន្មតិសីមាទាំងពីរយ៉ាងដូចបាននិយាយមកហើយនេះ ហៅថា សីមាសម្មតិ ក្នុងញត្តិទុតិយកម្មកថានេះ ។

តិចីវរាវិប្បវាសសម្មតិ ការសន្មតិមិនឲ្យមានអាបត្តិព្រោះការនៅប្រាសចាកត្រៃចីវរ មិនមែនដូចគ្នានឹងតិចីវរាវិប្បវាសសីមាទេ ដូចគ្នាតែព្យញ្ជនៈ ឯសេចក្តីមិនដូចគ្នាទេ; មានរឿងហេតុខាងដើមក្នុងឧទ្ទោសិតសិក្ខាបទថា ពួកភិក្ខុយកចីវររបស់ខ្លួនទៅផ្ញើនឹងភិក្ខុផងគ្នាហើយយកតែស្បង់១ នឹងចីពរ១ ដើរចេញទៅកាន់ជនបទចារិកផ្សេង ៗ ចីវរទាំងនោះយូរៗទៅ ក៏កើតមានសៅហ្មងប្រឡាក់ប្រឡូសដោយធូលីជាដើម ជាំដាមទៅខ្លះក៏មាន; ព្រះអានន្ទនិមន្តទៅ បានឃើញពួកភិក្ខុកំពុងហាលចីវរទាំងនោះ, លុះឃើញក៏សួរភិក្ខុទាំងនោះសព្វគ្រប់, ពួកភិក្ខុក៏បានទូលព្រះអានន្ទដោយសព្វគ្រប់, ព្រះអានន្ទយករឿងហេតុនោះទៅក្រាបទូលព្រះមានព្រះភាគ, ព្រះអង្គក៏បញ្ញត្តឧទ្ទោសិតសិក្ខាបទ ( ទុតិយកឋិន ) សេចក្តីក្នុងសិក្ខាបទនោះថា " ចីវររបស់ភិក្ខុសម្រេចហើយកឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែ១រាត្រី ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ" ។ បានជាព្រះអង្គបញ្ញត្តសិក្ខា-

---

១ គឺផ្តើមសួរនិមិត្តតាំងពីទិសបូព៌ាវៀងតាមលំដាប់ទិសទៅដល់ទិសឦសានហើយសួរនិមិត្តទិសបូព៌ាថែមម្តងទៀត ។

បទនេះ ដើម្បីមិនឲ្យមានភិក្ខុយកចីវរទៅផ្ញើទុកនឹងគេហើយដើរបោលចីវរផ្តេសផ្តាសជាការឥតសណ្តាប់ធ្នាប់ នាំឲ្យចីវរខូចវិនាសក៏សឹងមាន ។

សម័យជាខាងក្រោយមកទៀត មានភិក្ខុ ១ រូបមានជម្ងឺនៅក្នុងក្រុងកោសម្ពី, ពួកញាតិរបស់ភិក្ខុនោះ ក៏ចាត់បំរើឲ្យទៅនិមន្តភិក្ខុនោះមកដើម្បីជួយថែទាំរក្សាជម្ងឺ, ភិក្ខុនោះមិនព្រមទៅតាមសេចក្តីនិមន្តក៏និយាយតបទៅនឹងអ្នកបំរើនោះថា អាត្មាទៅមិនបានទេ ព្រោះព្រះអង្គបញ្ញត្តសិក្ខាបទរួចហើយថា មិនឲ្យភិក្ខុណាមួយនៅប្រាសចាកត្រៃចីវរទេ ឥឡូវអាត្មាមានជម្ងឺ នឹងនាំយកចីវរទាំងអស់ជាប់ទៅជាមួយផងមិនកើត ព្រោះហេតុនោះអាត្មាមិនទៅទេ ។ រឿងហេតុនោះជ្រួតជ្រាបដល់ព្រះមានព្រះភាគ ទើបទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ តិចីវរេនអវិប្បវាសសម្មុតឹ ទាតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការឲ្យនូវ តិចីវរាវិប្បវាសសម្មតិ ដល់ភិក្ខុដែលមានជម្ងឺ, ម្នាលភិក្ខុទាំងឡាយ ត្រូវឲ្យយ៉ាងនេះ ភិក្ខុដែលមានជម្ងឺនោះត្រូវចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គឆៀងស្មាម្ខាងថ្វាយបង្គំបាទានៃភិក្ខុចាស់ ៗ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង សូត្រសូមថា អហំ ភន្តេ គិលានោ ន សក្កោមិ តិចីវរមាទាយ បក្កមិតុំ សោហំ ភន្តេ សង្ឃំ តិចីវរេនអវិប្បវាសសម្មុតឹ(១) យាចាមិ បពិត្រព្រះសង្ឃដ៏ចំរើន

---

១ ជា សម្មុតឹ ក៏មាន ។

ខ្ញុំព្រះករុណាជាបុគ្គលមានជម្ងឺ មិនអាចដើម្បីនាំយកត្រៃចីវរចេញទៅបាន
ទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ សូមតិចីវរាវិប្បវាសសម្មតិ
ចំពោះសង្ឃ (សូម៣ដង) ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ
គិលានោ ន សក្កោតិ តិចីវរមាទាយ បក្កមិតុំ សោ សង្ឃំ
តិចីវរេនអវិប្បវាសសម្មតឹ យាចតិ យទិ សង្ឃស្ស បត្តកល្លំ
សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តិចីវរេនអវិប្បវាសសម្មតឹ ទទេយ្យ
ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ)
ភិក្ខុ គិលានោ ន សក្កោតិ តិចីវរមាទាយ បក្កមិតុំ សោ សង្ឃំ
តិចីវរេនអវិប្បវាសសម្មតឹ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស)
ភិក្ខុនោ តិចីវរេនអវិប្បវាសសម្មតឹ ទេតិ យស្សាយស្មតោ
ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ តិចីវរេនអវិប្បវាសសម្មតិយា
ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។
ទិន្នា សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ តិចីវរេនអវិប្ប-
វាសសម្មតិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ
មានជម្ងឺ មិនអាចដើម្បីនាំយកត្រៃចីវរចេញទៅបាន ភិក្ខុនោះសូមនូវតិចី-

វរាវិប្បវាសសម្មតិចំពោះសង្ឃ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃ ហើយ សង្ឃត្រូវឲ្យនូវតិចីវរាវិប្បវាសសម្មតិដល់ភិក្ខុ (ឈ្មោះនេះ) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះមានជម្ងឺ មិនអាចដើម្បីនាំយកត្រៃចីវរចេញទៅបាន ភិក្ខុនោះសូមនូវតិចីវរាវិប្បវាសសម្មតិចំពោះសង្ឃ (ឥឡូវ) សង្ឃឲ្យនូវតិចីវរាវិប្បវាសសម្មតិដល់ភិក្ខុ (ឈ្មោះនេះ) ការឲ្យនូវតិចីវរាវិប្បវាស-សម្មតិដល់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ តិចីវរាវិប្បវាសសម្មតិ សង្ឃបានឲ្យដល់ភិក្ខុ (ឈ្មោះនេះ) ហើយ ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

នេះហៅថា តិចីវរាវិប្បវាសសម្មតិ គឺការសន្មតិមិនឲ្យកើតអាបត្តិដល់ភិក្ខុមានជម្ងឺ ព្រោះការនៅប្រាសចាកត្រៃចីវរ ។ ទើបព្រះមាន-ព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថែមទៀតថា និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ ឯករត្តម្បិ ចេ ភិក្ខុ តិចីវរេន វិប្បវសេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ចីវររបស់ភិក្ខុសម្រេចហើយកឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បី

តែ ១ រាត្រី ចីវរជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ឯភិក្ខុសម្មតិនេះប្រែថា ការសន្មតិនូវភិក្ខុមានជម្ងឺឲ្យរួចចាកអាបត្តិ ព្រោះការនៅប្រាសចាកត្រៃចីវរ ។

សួរថា អវិប្បវាសសម្មតិនោះ មានអានិសង្សដូចម្តេច? ឆ្លើយថា ភិក្ខុនៅប្រាសចាកចីវរណា ចីវរនោះមិនត្រូវនិស្សគ្គិយ ភិក្ខុក៏មិនត្រូវអាបត្តិ ។ សួរថា អវិប្បវាសសម្មតិនោះ មានកាលកំណត់ប៉ុន្មានថ្ងៃ-ខែ-ឆ្នាំ ? ឆ្លើយថា ថេរដីកានៃព្រះមហាសុមត្ថេរថា ស្រេចហើយតែត្រឹមរោគ បើរោគនៅមិនទាន់ជាត្រឹមណា អវិប្បវាសសម្មតិ ក៏មានកំណត់ត្រឹមនោះដែរ កាលបើជារោគហើយត្រូវត្រឡប់មកកាន់ទីនៃចីវរវិញឲ្យឆាប់ ៗ ។ ថេរដីកានៃព្រះមហាបទុមត្ថេរថា បើភិក្ខុត្រឡប់មកឆាប់ៗពេក ក្រែងរោគនោះនឹងត្រឡប់កើតឡើងវិញ ព្រោះហេតុនោះ ត្រូវពិលកមើលតាមការណ៍គួរបន្តិចៗទៅសិន ព្រោះថាភិក្ខុកំពុងស្វែងរកគ្គីគ្គា ដើម្បីត្រឡប់មកវិញក្តី កំពុងតាំងចិត្តថានឹងត្រឡប់មកវិញក្តី ក៏នៅមិនទាន់ជាអ្វីទេ តែបើភិក្ខុដាក់ធុរៈថា មិនត្រឡប់មកវិញទេ ហើយដកអធិដ្ឋានចីវរចេញ ចីវរនោះមុខជានឹងតាំងនៅក្នុងទីនៃអតិរេកចីវរ ។ សួរថា ចុះបើរោគនោះត្រឡប់កើតឡើងវិញ តើត្រូវធ្វើដូចម្តេច ? ឆ្លើយថា ថេរដីកានៃព្រះបុស្សទេវត្ថេរថា បើរោគនោះត្រឡប់កើតឡើងវិញដដែល ការសន្មតិនោះក៏នៅជាសន្មតិដដែល មិនបាច់ឲ្យសន្មតជាថ្មីទៀតទេ តែបើរោគដទៃបណ្តាលឡើងទៀត ត្រូវឲ្យសន្មតិជាថ្មីទៀត ។ ថេរដីកានៃ

ព្រះឧបតិស្សត្ថេរថា កេគដដែលនោះក៏ដោយ កេគដទៃទៀតក៏ដោយ មិនបាច់ឲ្យសន្មតិជាថ្មីទៀតទេ ។ សម្មតិដែលបាននិយាយមកនេះ ហៅថា តិចីវរាវិប្បវាស សម្មតិ ក្នុងញត្តិទុតិយកម្មកថានេះ ។

សន្ថតសម្មតិ ការសន្មតិនូវសន្ថតថ្មីមិនឲ្យមានអាបត្តិដល់ភិក្ខុមានជម្ងឺហើយធ្វើ ព្រោះខ្លួនមានសន្ថតចាស់ប្រើប្រាស់មិនទាន់គ្រប់ ៦ ឆ្នាំ ។ មានរឿងហេតុក្នុងឆព្វស្សសិក្ខាបទថា ពួកភិក្ខុឲ្យគេធ្វើសន្ថតរាល់ ៗ ឆ្នាំ ភិក្ខុទាំងនោះដើររៃដើរសូមរោមចៀមរបស់គេជាច្រើន ។ មនុស្សទាំងឡាយគេពោលទោសតិះដៀលបន្តុះបង្អាប់ ព្រោះអំពើនោះជាហេតុ ថាយើងទាំងអស់គ្នាធ្វើសន្ថតតែម្តងប្រើប្រាស់បាន ៥ ឆ្នាំក៏មាន ៦ ឆ្នាំក៏មាន ហើយថែមទាំងកូនជុះដាក់ក៏មាន នោមដាក់ក៏មាន កណ្តុរកាត់ក៏មាន គង់ប្រើប្រាស់បានយូរ ចុះពួកសមណៈហេតុអ្វីក៏ធ្វើសន្ថតរាល់ឆ្នាំម៉្លេះ? ព្រះមានព្រះភាគទ្រង់ជ្រាបហើយទ្រង់បញ្ញត្តសិក្ខាបទថា "ភិក្ខុឲ្យគេធ្វើសន្ថតថ្មីហើយត្រូវប្រើប្រាស់ឲ្យបានគ្រប់ ៦ ឆ្នាំ បើមិនទាន់គ្រប់ ៦ ឆ្នាំទេ លះបង់នូវសន្ថតនោះក្តី មិនលះបង់ក្តី ឲ្យគេធ្វើសន្ថតថ្មីដទៃទៀត សន្ថតថ្មីនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ" ។

សម័យជាខាងក្រោយមកទៀត មានភិក្ខុ ១ រូបមានជម្ងឺនៅក្នុងក្រុងកោសម្ពី ពួកញាតិរបស់ភិក្ខុនោះ ចាត់បំរើឲ្យទៅនិមន្តភិក្ខុនោះមកដើម្បីជួយទំនុកបំរុងថែទាំរក្សាជម្ងឺ ថែមទាំងភិក្ខុផងគ្នាក៏ផ្តាំឲ្យនិមន្តមកដើម្បីជួយថែទាំរក្សាជម្ងឺដែរ ភិក្ខុនោះក៏មិនបានទទួលនិមន្តមក និយាយតប

ទៅនឹងអ្នកបំរើនោះថា ព្រះអង្គបញ្ញត្តសិក្ខាបទរួចហើយថា សន្ថតនីមួយៗ ត្រូវប្រើប្រាស់ឲ្យគ្រប់ ៦ ឆ្នាំ, ឥឡូវអាត្មាជាបុគ្គលមានជម្ងឺ មិនអាចនឹងនាំយកសន្ថតទៅបានទេ មួយទៀតបើមិនមានសន្ថតក៏មិនបានសេចក្តីសប្បាយ ហេតុនេះអាត្មាមិនបានទៅទេ ។

ព្រះមានព្រះភាគទ្រង់ជ្រាបរឿងនោះហើយ ទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ សន្ថតសម្មុតឹ ទាតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការឲ្យនូវសន្ថតសម្មតិដល់ភិក្ខុមានជម្ងឺ, ត្រូវឲ្យយ៉ាងនេះ ភិក្ខុដែលមានជម្ងឺនោះ ត្រូវចូលទៅរកសង្ឃ ដណ្តប់ចីវរឆៀងស្មាម្ខាងថ្វាយបង្គំបាទានៃភិក្ខុចាស់ៗ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងសូត្រសូមថា អហំ ភន្តេ គិលានោ ន សក្កោមិ សន្ថតំ អាទាយ បក្កមិតុំ សោហំ ភន្តេ សង្ឃំ សន្ថតសម្មុតឹ យាចាមិ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាជាបុគ្គលមានជម្ងឺ មិនអាចដើម្បីនាំយកនូវសន្ថតចេញទៅបាន បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណានោះ សូមសន្ថតសម្មតិចំពោះសង្ឃ (សូត្រ៣ដង) ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ គិលានោ ន សក្កោតិ សន្ថតំ អាទាយ បក្កមិតុំ សោ សង្ឃំ សន្ថតសម្មុតឹ យាចតិ

យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ( ឥត្ថន្នាមស្ស ) ភិក្ខុនោ សន្ថតសម្មតឹ ទទេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ គិលានោ ន សក្កោតិ សន្ថតំ អាទាយ បក្កមិតុំ សោ សង្ឃំ សន្ថតសម្មតឹ យាចតិ សង្ឃោ ( ឥត្ថន្នាមស្ស ) ភិក្ខុនោ សន្ថតសម្មតឹ ទេតិ យស្សាយស្មតោ ខមតិ ( ឥត្ថន្នាមស្ស ) ភិក្ខុនោ សន្ថតសម្មតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន (ឥត្ថន្នាមស្ស ) ភិក្ខុនោ សន្ថតសម្មតិ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ មានជម្ងឺ មិនអាចដើម្បីនាំយកនូវសន្ថតចេញទៅបាន ភិក្ខុនោះ សូមសន្ថតសម្មតិចំពោះសង្ឃ បើសម្មតកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវសន្ថតសម្មតិដល់ភិក្ខុ (ឈ្មោះនេះ) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះមានជម្ងឺ មិនអាចដើម្បីនាំយកនូវសន្ថតចេញទៅបាន ភិក្ខុនោះសូមសន្ថតសម្មតិចំពោះសង្ឃ (ឥឡូវ) សង្ឃឲ្យនូវសន្ថតសម្មតិដល់ភិក្ខុ (ឈ្មោះនេះ) ការឲ្យនូវសន្ថតសម្មតិដល់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គ*

ណា លោកអ្នកមានអាយុអគ្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអគ្គណា លោកអ្នកមានអាយុអគ្គនោះត្រូវនិយាយឡើង ។ សន្ថតសម្មតិសង្ឃបានឲ្យដល់ភិក្ខុ (ឈ្មោះនេះ) ហើយ ការឲ្យនោះគាប់-ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ ។

ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះម្តងទៀតថា នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វំ ឱរេន ចេ ឆន្នំ វស្សានំ តំ សន្ថតំ វិស្សជ្ជេត្វា វា អវិស្សជ្ជេត្វា វា អញ្ញំ នវំ សន្ថតំ ការាបេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ភិក្ខុឲ្យគេធ្វើសន្ថតថ្មីហើយត្រូវប្រើប្រាស់ឲ្យគ្រប់ ៦ ឆ្នាំ បើមិនទាន់គ្រប់ ៦ ឆ្នាំទេ លះបង់នូវសន្ថតនោះក្តីមិនលះបង់ក្តី ឲ្យគេធ្វើសន្ថតថ្មីដទៃទៀត សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ឯភិក្ខុសម្មតិនេះប្រែថា ការសន្មតិនូវភិក្ខុមានជម្ងឺមិនឲ្យត្រូវអាបត្តិព្រោះធ្វើសន្ថតថ្មី ដោយហេតុភិក្ខុនោះមានសន្ថតចាស់ប្រើប្រាស់មិនទាន់គ្រប់ ៦ ឆ្នាំ ។ សន្ថតនោះជាបរិក្ខារមួយយ៉ាង (កួយ) គេយករោមចៀមមកស្លាប់ធ្វើ គេមិនត្បាញដូចសំពត់ធម្មតាទេ ។

ភិក្ខុមានជម្ងឺដែលបានសម្មតិអំពីសង្ឃយ៉ាងនេះហើយ បើមិនទាន់ជារោគកំណត់ត្រឹមណា ដើរទៅកាន់ទីណា ៗ អាចធ្វើសន្ថតថ្មីបានក្នុង

ទីនោះៗ កំណត់ត្រឹមនោះ, នេះជាអានិសង្សនៃសន្មតសម្មតិ ។ ថេរដីកានៃព្រះបុស្សទេវត្ថេរថា បើភិក្ខុនោះបានជារោគហើយត្រឡប់ឈឺវិញ ដោយរោគដូចពីមុននោះទៀត បរិហារនោះក៏នៅជាបរិហារដដែលមិនបាច់ធ្វើសម្មតិដទៃទៀតទេ ។ ប៉ុន្តែថេរដីកានៃព្រះឧបតិស្សត្ថេរថា រោគដដែលនោះកំរើករើឡើងវិញក៏ដោយ រោគដទៃបណ្ដាលឡើងជាថ្មីក៏ដោយ ភិក្ខុបាននាមថាជាបុគ្គលមានដម្បីតែម្ដងក៏ទុកជាបានស្រេចហើយ មិនបាច់ធ្វើសម្មតិថ្មីទៀតទេ ។ សម្មតិដូចបាននិយាយមកនេះឈ្មោះថា សន្មតសម្មតិ ក្នុងញត្តិទុតិយកម្មកថានេះ ។

ភត្តុទ្ទេសកសម្មតិ ការសន្មតនូវភិក្ខុឲ្យជាអ្នកសំដែងនូវភត្ត គឺជាអ្នកចាត់ភត្ត ។ មានរឿងក្នុងសេនាសនក្ខន្ធកថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថាននាក្រុងរាជគ្រឹះ ។ សម័យនោះឯងទីក្រុងរាជគ្រឹះកើតទុរ្ភិក្ស (អត់បាយ) មនុស្សទាំងឡាយមិនអាចដើម្បីធ្វើនូវសង្ឃភត្ត ចង់ធ្វើនូវឧទ្ទេសភត្ត, និមន្តនភត្ត, សលាកភត្ត, បក្ខិកភត្ត, ឧបោសថិកភត្ត និងបាដិបទិកភត្ត ក៏ក្រាបទូលសេចក្ដីនោះចំពោះព្រះបរមសាស្ដា. ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតនូវសង្ឃភត្ត[១],

---

១ សង្ឃភត្តំ នាម សកលស្ស សង្ឃស្ស ទាតព្វំ ភត្តំ ភត្តដែលគេត្រូវឲ្យដល់សង្ឃទាំងអស់ ហៅថា សង្ឃភត្ត, ដូចជាវត្ត១ មានភិក្ខុ ៥០ អង្គ គេត្រូវការយកភត្តមកប្រគេនគ្រប់អង្គក្នុងវត្តមិនសល់ ១ ឬគេប្រគេនក្រៅវត្តក៏បាន តែត្រូវនិមន្តមហាថេរ ឬភត្តុទ្ទេសកភិក្ខុ ។

ឧទ្ទេសភត្ត[១], និមន្តនភត្ត[២], សលាកភត្ត[៣], បក្ខិកភត្ត[៤], ឧបោ-សថិកភត្ត[៥] និងបាដិបទិកភត្ត[៦] ។

សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ជ្រើសយកនូវភត្តដ៏ថ្លៃថ្លាដើម្បីខ្លួន ឲ្យនូវភត្តដ៏ថោកទាបដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ. ទ្រង់ត្រាស់ថា អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ភត្តុទ្ទេសកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ ឧទ្ទិដ្ឋានុទ្ទិដ្ឋញ្ច ជានេយ្យ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការសន្មតិនូវភិក្ខុដែលប្រកប

---

១ ភត្តដែលគេត្រូវឲ្យដោយឧទ្ទិសយកភិក្ខុ ១ អង្គក្តី ២ អង្គក្តី ។បេ។ ១០ អង្គក្តី អំពីសង្ឃ ដោយមានភត្តុទ្ទេសកភិក្ខុចាត់ឲ្យ ហៅថា ឧទ្ទេសភត្ត ។ ២ ភត្តដែលគេត្រូវឲ្យដោយនិមន្ត ។ និមន្តនំ បុគ្គលិកញ្ចេ សយមេវ ឥស្សរោ ការនិមន្តនោះគឺនិមន្តចំពោះរូបបុគ្គល អ្នកនិមន្តជាឥស្សរខ្លួនឯង ចង់បានប៉ុន្មានអង្គក៏និមន្តប៉ុណ្ណោះទៅ ពេញចិត្តអង្គណា ក៏និមន្តអង្គនោះទៅ ហៅថា និមន្តនភត្ត ។ ៣ សលាកភត្ត ភត្តដែលគេត្រូវឲ្យដោយស្លាក ស្លាកនោះគេធ្វើដោយបន្ទះឈើក៏បាន បន្ទះឫស្សីឬស្លឹកត្នោតជាដើមក៏បាន ភត្តុទ្ទេសកភិក្ខុប្រកបដោយអង្គ ៥ ត្រូវសរសេរអក្សរដាក់នាស្លាកនោះថា សលាកភត្ត របស់ឧបាសកឈ្មោះឯណោះ (ធម្មិកឧបាសក) ហើយយកទៅដាក់ក្នុងកញ្ជើឬបង្វិចសំពត់ហើយគ្រលុកឲ្យច្រឡំគ្នាទាំងអស់ បើមាននាយបញ្ជី ត្រូវចែកតាំងពីនាយបញ្ជីទៅ បើគ្មាននាយបញ្ជីទេ ត្រូវចែកតាំងពីអាសនៈនៃព្រះថេរៈទៅ ។ ៤ បក្ខិកភត្ត ភត្តដែលគេត្រូវឲ្យក្នុងសុក្កបក្ខ (ខ្នើត) ឬកាឡបក្ខ (រនោច) ។ ៥ ឧបោសថិកភត្ត ភត្តដែលគេត្រូវឲ្យក្នុងថ្ងៃឧបោសថ ។ ៦ បាដិបទិកភត្ត ភត្តដែលគេត្រូវឲ្យក្នុងថ្ងៃ ១ កើត ឬ ១ រោច ។

ដោយអង្គ ៤ ឲ្យជាភត្តុទ្ទេសក ជាអ្នកសំដែងនូវភត្ត គឺភិក្ខុណាមិនដល់នូវឆន្ទាគតិ១ មិនដល់នូវទោសាគតិ១ មិនដល់នូវមោហាគតិ១ មិនដល់នូវភយាគតិ ១ ដឹងនូវភត្តដែលខ្លួនបានសំដែងហើយ នឹងភត្តដែលខ្លួនពុំទាន់បានសំដែង ១ ។ ត្រូវសន្មតយ៉ាងនេះ សង្ឃត្រូវសូមឬអង្វរនូវភិក្ខុនោះជាមុន លុះអង្វររួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភត្តុទ្ទេសកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភត្តុទ្ទេសកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភត្តុទ្ទេសកស្ស សម្មតិ សោ តុណ្ហាស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ភត្តុទ្ទេសកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាភត្តុទ្ទេសក នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាភត្តុទ្ទេសក ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាភត្តុទ្ទេសក គាប់ចិត្ត

ដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតហើយ ឲ្យជាភត្តុទ្ទេសក ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបាន-ជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ពួកភត្តុទ្ទេសកភិក្ខុកើតសេចក្តីសង្ស័យឡើងថា យើងត្រូវសំដែងនូវភត្តដូចម្តេចហ្ន៎? ទើបក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ, ទ្រង់ត្រាស់ថា អនុជានាមិ ភិក្ខវេ សលាកាយ វា បដិកាយ វា ឧបនិពន្ធិត្វា ឱមុញ្ចិត្វា ភត្តំ ឧទ្ទិសិតុំ ម្នាលភិក្ខុទាំងឡាយ តថា-គតអនុញ្ញាតនូវការចារិកទុកនាស្លាក[១]ក៏បាន នាក្រដាសឬផែនអ្វីៗ[២] ក៏បាន ហើយស្រាយរួចសំដែងនូវភត្ត ។ សម្មតិដូចបាននិយាយមកនេះ ហៅថា ភត្តុទ្ទេសកសម្មតិ ក្នុងញត្តិទុតិយកម្មកថានេះ ។

សេនាសនគ្គាហាបកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់នូវសេនាសនៈ ។ មានរឿងដូចតទៅនេះ សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តព្រះជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុនាំគ្នាដួសដុល

១ ស្លាកដែលគេធ្វើដោយបន្ទះឈើ ។ ២ វត្ថុទាំងឡាយមានបន្ទះឬស្សីនិងស្លឹកត្នោតជាដើម (អដ្ឋកថា) ។

វិហារ(១)ធំមួយដោយបំណងនឹងនៅចាំវស្សា ។ ពួកឆព្វគ្គិយភិក្ខុបានឃើញដូច្នោះហើយក៏និយាយគ្នាថា ពួកសត្តរសវគ្គិយភិក្ខុនេះជួសជុលវិហារ យើងចាំបណ្តេញភិក្ខុទាំងនោះចេញ, ភិក្ខុខ្លះថាយើងកុំអាលបណ្តេញ ចាំឲ្យគេជួសជុលហើយស្រេចសិនសឹមបណ្តេញ ។ ទើបពួកឆព្វគ្គិយភិក្ខុនិយាយទៅនឹងពួកសត្តរសវគ្គិយភិក្ខុថា លោកទាំងឡាយចៀសចេញ វិហារនេះត្រូវបានយើងទេ ។ ពួកសត្តរសវគ្គិយភិក្ខុតបថា បើត្រូវបានលោកម៉េចក៏មិនប្រាប់យើងពីមុន យើងនឹងជួសជុលវិហារដទៃទៀត? ពួកឆព្វគ្គិយភិក្ខុសួរថា វិហារនេះកែងជាវិហាររបស់សង្ឃមិនមែនឬ? ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា អើ! វិហារនេះជាវិហាររបស់សង្ឃពិតមែនហើយ ។ ពួកឆព្វគ្គិយភិក្ខុនិយាយថា បើវិហាររបស់សង្ឃ លោកត្រូវចេញទៅ ព្រោះវិហារនេះត្រូវបានយើង ។ ពួកសត្តរសវគ្គិយភិក្ខុតបថា វិហារនេះជាវិហារធំ ពួកលោកក៏នៅបាន ពួកយើងក៏នៅបានដែរ ។ ពួកឆព្វគ្គិយភិក្ខុកើតសេចក្តីក្រោធតូចចិត្តឡើង ក៏នាំគ្នាចាប់កអូសទាញចេញអំពីសេនាសនៈ ។ ពួកសត្តរស-វគ្គិយភិក្ខុក៏ទ័លគំនិតទៅជានាំគ្នាយំ ។ ពួកភិក្ខុឯទៀតបានដឹងហើយ

---

១ បរិយាយក្នុងវិន័យថា សេនាសនៈដែលមានបណ្តោយ ១២ បំអាម ទទឹង ៧ បំអាមព្រះសុគតឬតូចជាងនេះ ហៅថា កុដិ. សេនាសនៈដែលធំជាងនេះហៅថា វិហារ, ឯវិហារ-សព្ទ ប្រើជា ២ យ៉ាង គឺជាឈ្មោះនៃអាវាសទាំងមូលមួយយ៉ាង ជាឈ្មោះនៃកុដិធំ ៗ មួយយ៉ាង, ក្នុងទីនេះសំដៅយកកុដិធំ ៗ ។

កំសួរថា ហេតុអ្វីបានជាយំដូច្នោះ? ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា ពួកឆព្វគ្គិយភិក្ខុក្រោធខឹងតូចចិត្ត នាំគ្នាចាប់ទាញយើងអូសចេញអំពីវិហាររបស់សង្ឃ ។ ពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ទ្រង់ជ្រាបសព្វគ្រប់ហើយ ទ្រង់បញ្ញត្តសិក្ខាបទថា យោ បន ភិក្ខុ ភិក្ខុំ កុបិតោ អនត្តមនោ សង្ឃិកា វិហារា និក្កឌ្ឍេយ្យ វា និក្កឌ្ឍាបេយ្យ វា បាចិត្តិយំ ភិក្ខុណាមួយក្រោធខឹងតូចចិត្ត ចាប់ទាញចេញដោយខ្លួនឯងក្ដី ប្រើគេឲ្យចាប់ទាញចេញក្ដី នូវភិក្ខុផងគ្នា ចាកវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។ លុះព្រះអង្គបញ្ញត្តសិក្ខាបទនេះរួចហើយ ទើបទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ សេនាសនំ គាហេតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការប្រគល់នូវសេនាសនៈ ។ ទើបពួកភិក្ខុកើតសេចក្ដីសង្ស័យថា បុគ្គលណាដែលជាអ្នកត្រូវប្រគល់សេនាសនៈ? ក៏ក្រាបទូលព្រះមានព្រះភាគ, ទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ សេនាសនគ្គាហាបកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ គាហិតាគាហិតញ្ច ជានេយ្យ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការសន្មតិនូវភិក្ខុដែលប្រកប

ដោយអង្គ ៤ ឲ្យជាអ្នកប្រគល់នូវសេនាសនៈ គឺ ភិក្ខុណាដែលមិនដល់នូវ
ឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ ១ មិនដល់នូវ
ភយាគតិ១ អាចស្គាល់នូវសេនាសនៈដែលខ្លួនបានប្រគល់ហើយនឹងដែល
ខ្លួនមិនទាន់បានប្រគល់ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវសន្មតយ៉ាងនេះ
សង្ឃត្រូវសូមប្អអង្វរភិក្ខុនោះជាមុន លុះអង្វររួចហើយ ភិក្ខុអ្នកឈ្លាស
ប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ យទិ
សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សេនាសនគ្គាហា-
បកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ
សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សេនាសនគ្គាហាបកំ សម្មន្នតិ
យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ សេនាសន-
គ្គាហាបកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ
ភាសេយ្យ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ សេនាសន
គ្គាហាបកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ
បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្ម
មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ)
ឲ្យជាអ្នកប្រគល់នូវសេនាសនៈ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏
ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ)

ឲ្យជាអ្នកប្រគល់នូវសេនាសនៈ ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវសេនាសនៈ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតហើយ ឲ្យជាអ្នកប្រគល់នូវសេនាសនៈ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ពួកភិក្ខុជាអ្នកប្រគល់នូវសេនាសនៈ ដែលបានសន្មតិអំពីសង្ឃហើយ កើតសេចក្តីសង្ស័យថា ត្រូវប្រគល់សេនាសនៈដូចម្តេចហ្ន៎ ? ទើបក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បឋមំ ភិក្ខូ គណេតុំ ភិក្ខូ គណេត្វា សេយ្យា គណេតុំ សេយ្យា គណេត្វា សេយ្យគ្គេន គាហេតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការរាប់នូវភិក្ខុជាមុន លុះរាប់ភិក្ខុរួចហើយ ត្រូវរាប់កន្លែងដេក លុះរាប់កន្លែងដេករួចហើយ ត្រូវប្រគល់តាមចំនួនកន្លែងដេក ។ ព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុឲ្យជាអ្នកប្រគល់សេនាសនៈយ៉ាងនេះ ដើម្បីចៀសវាងការទាស់ទែងគ្នា ព្រោះសេនាសនៈនោះជាហេតុ, ចំណែកភិក្ខុអ្នកប្រគល់សេនាសនៈដែលបានសន្មតិអំពីសង្ឃហើយ ត្រូវមានអំណាចប្រគល់សេនាសនៈតាម

យោបលរបស់ខ្លួនដែលជ្រះស្រឡះពីអគតិទាំង ៤, ភិក្ខុឯទៀត ១ ក៏ផុត អំពីផ្លូវតក៏ ជាការសុខស្ងប់ឥតមានអំពើបំពានបំពារខុសច្បាប់ ដូចជាពួកឆព្វគ្គិយភិក្ខុនោះឡើយ ។ សម្មតិដូចបាននិយាយមកនេះ ហៅថា សេនាសនគ្គាហាបកសម្មតិ ក្នុងញត្តិទុតិយកម្មកថានេះ ។

**ចីវរប្បដិគ្គាហកសម្មតិ** ការសន្មតិនូវភិក្ខុឲ្យជាអ្នកទទួលចីវរ ។ មានរឿងក្នុងចីវរក្ខន្ធកថា សម័យនោះព្រះបាទបជ្ជោតជាស្ដេចធំក្នុងទីក្រុងឧជ្ជេនី ទ្រង់ប្រឈួនដោយព្រះរោគលឿង, គ្រូពេទ្យជាច្រើនមកព្យាបាលព្រះរោគនោះក៏មិនស្បើយសោះ, គ្រានោះព្រះបាទបជ្ជោតក៏បាត់ព្រះរាជបំរើឲ្យមកក្រាបបង្គំគាល់ព្រះបាទពិម្ពិសារជាស្ដេចធំក្នុងទីក្រុងរាជ-គ្រឹះ, ក្រាបទូលសូមជីវកកោមារភត្យជាគ្រូពេទ្យធំមានកេរ្ដិ៍ឈ្មោះល្បី-ល្បាញទូទៅសព្វទិស ឲ្យទៅព្យាបាលព្រះរោគរបស់ព្រះអង្គ ។ ព្រះបាទពិម្ពិសាររាជក៏ទ្រង់បាត់ប្រើជីវកកោមារភត្យឲ្យទៅព្យាបាលព្រះរោគរបស់ព្រះបាទបជ្ជោតដោយសួស្ដី ។ ជីវកកោមារភត្យក៏បានទៅកាន់ទីក្រុងឧជ្ជេនីតាមព្រះរាជបញ្ញា បានទៅថ្វាយឱសថវិសេសបំពោះព្រះបាទបជ្ជោតហើយ ក៏ត្រឡប់មកកាន់ទីក្រុងរាជគ្រឹះវិញ ។ ព្រះបាទបជ្ជោតទ្រង់បានជាស្បើយព្រះរោគ ដោយឱសថវិសេសរបស់ជីវកកោមារភត្យនោះឯង ។ សម័យនោះ ព្រះបាទបជ្ជោតទ្រង់បានសំពត់ ១ គូ ឈ្មោះសំពត់ សិវេយ្យកៈ ជាសំពត់ល្អលើសលុបក្នុងពិភពលោក ។ មាន

សេចក្តីតំណាលថា សំពត់សិវេយ្យកៈនោះជាសំពត់អពមង្គល គេចោលក្នុងព្រៃស្មសានក្នុងឧត្តរកុរុទ្វីប, មនុស្សទាំងឡាយគេយកសំពត់នោះមករុំមនុស្សស្លាប់ ហើយគេយកទៅចោលក្នុងព្រៃស្មសាន, មានសត្វបក្សី ហត្ថិសោណ្ឌ (សត្វស្លាបមានប្រមាយដូចជាប្រមាយដំរី) បានឃើញសាកសពស្មានថាជាដុំសាច់ ក៏ឆាបនាំយកអំពីឧត្តរកុរុទ្វីបមកដាក់លើភ្នំហិមពាន្ត ចឹកទាញបកយកសំពត់នោះចេញ ហើយស៊ីសាកសពនោះជាអាហារ ។ មានពួកព្រានព្រៃដើរទៅឃើញសំពត់នោះល្អចំឡែក ក៏នាំយកមកថ្វាយព្រះបាទបជ្ជោត ។ ព្រះបាទបជ្ជោតទ្រង់បានសំពត់សិវេយ្យកៈ ១ គូនោះមកហើយ ទ្រង់នឹករលឹកគុណូបការរបស់ជីវកកោមារភត្យ ដែលបានថ្វាយឱសថវិសេសចំពោះព្រះអង្គ ទើបទ្រង់ផ្ញើសំពត់១គូនោះមកជូនជីវកកោមារភត្យ ជាការបូជាតបគុណគ្រូពេទ្យ ។ ជីវកកោមារភត្យបានសំពត់នោះមកហើយ ឃើញថាល្អវិសេសណាស់ មនុស្សក្នុងលោកនេះមិនមាននរណា សមគួរនឹងប្រើប្រាស់សំពត់នេះបានឡើយ មានតែព្រះសម្មាសម្ពុទ្ធនឹងព្រះបាទពិម្ពិសាររាជទើបសមគួរនឹងប្រើប្រាស់បាន ។

សម័យនោះឯង ព្រះមានព្រះភាគទ្រង់ប្រឈួនដោយព្រះរោគទល់ ទ្រង់មានព្រះពុទ្ធបំណងនឹងសោយទូវវិរេចនភេសជ្ជៈ (ថ្នាំបញ្ចុះ) ។ ព្រះអានន្ទក៏និមន្តទៅកាន់សំណាក់ជីវកកោមារភត្យឲ្យដំណឹងអំពីព្រះអង្គទ្រង់

ប្រឈួនដោយព្រះកេតទល់ ទ្រង់មានព្រះពុទ្ធបំណងនឹងសោយវិរេចនភេសជ្ជៈ ។ ជីវកកោមារភច្ចក៏យកចិត្តទុកដាក់ផ្សំឱសថវិសេសសម្រាប់បញ្ចុះហើយយកមកថ្វាយព្រះមានព្រះភាគ, ព្រះអង្គទ្រង់ប្រើប្រាស់ឱសថវិសេសនោះហើយ ទ្រង់បានសេចក្ដីសប្បាយក្នុងព្រះកាយដូចប្រក្រតីដើមវិញ ។ គ្រានោះជីវកកោមារភច្ចនាំយកសំពត់សិវេយ្យកៈ ១ គូនោះចូលទៅក្រាបបង្គំគាល់ព្រះមានព្រះភាគ ហើយសូមពរចំពោះព្រះអង្គ ។ ព្រះអង្គត្រាស់ថា ធម្មតាព្រះតថាគតទាំងឡាយឥតមានពរអ្វីឡើយ ។ ជីវកក្រាបទូលថា ខ្ញុំព្រះអង្គសូមតែពរដែលគួរ ពរដែលឥតទោស ។ ព្រះអង្គត្រាស់ថា អ្នកចូរនិយាយទៅចុះ ។ ជីវកក្រាបទូលថា ភិក្ខុសង្ឃសព្វថ្ងៃនៅប្រើប្រាស់ចីវរបង្សុកូលទាំងអស់, មួយទៀត សំពត់សិវេយ្យកៈ១គូនេះ ព្រះបាទបជ្ជោតបានផ្ញើមកព្រះរាជទានដល់ខ្ញុំព្រះអង្គ ។ សូមថ្វាយចំពោះព្រះបរមគ្រូ សូមទ្រង់ព្រះមេត្តាប្រោសទទួលដោយអនុគ្រោះ, មួយទៀត សូមព្រះអង្គអនុញ្ញាតនូវគហបតិចីវរដល់ភិក្ខុសង្ឃផង ។ ព្រះមានព្រះភាគទ្រង់ព្រះសណ្ដាប់ពាក្យជីវកសព្វគ្រប់ហើយទ្រង់ទទួលនូវសំពត់សិវេយ្យកៈ ១ គូនោះហើយទ្រង់អនុញ្ញាតថា

អនុជានាមិ ភិក្ខវេ គហបតិចីវរំ យោ ឥច្ឆតិ បំសុកូលិកោ ហោតុ យោ ឥច្ឆតិ គហបតិចីវរំ សាទិយតុ ឥតរីតរេន បាហំ ភិក្ខវេ សន្តុដ្ឋឹ វណ្ណេមិ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

នូវគហបតិចីវរ ប៉ុន្តែបើភិក្ខុណាចង់ប្រើប្រាស់បង្សុកូលចីវរ ភិក្ខុនោះចូរជាអ្នកប្រើប្រាស់បង្សុកូលចីវរចុះ ភិក្ខុណាចង់ប្រើប្រាស់គហបតិចីវរ ភិក្ខុនោះចូរត្រេកអរចំពោះគហបតិចីវរចុះ, ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតសរសើរនូវសេចក្ដីសន្ដោស គឺការត្រេកអរតាមបានតាមមាន ដោយបច្ច័យណាមួយ ៗ មនុស្សទាំងឡាយក្នុងទីក្រុងរាជគ្រឹះ បានដឹងថាព្រះ-មានព្រះភាគទ្រង់អនុញ្ញាតគហបតិចីវរហើយ ក៏មានសេចក្ដីត្រេកអររីក-រាយហួសប្រមាណ, ត្រឹមតែទីក្រុងរាជគ្រឹះ១ ក៏កើតចីវរ១ ថ្ងៃ ៗ ចំនួនច្រើនពាន់, មនុស្សក្នុងជនបទដទៃៗ ក៏មានសេចក្ដីត្រេកអរដូច្នោះដែរ ។

សម័យនោះឯង មនុស្សទាំងឡាយជាច្រើនបាននាំយកចីវរមកកាន់អារាម តែគ្មានភិក្ខុដែលជាអ្នកទទួលចីវរ ក៏យកចីវរត្រឡប់ទៅផ្ទះវិញដោយច្រើន ចីវរក៏កើតឡើងតិចតួចស្ដួចស្ដើងទៅវិញដោយលំដាប់ ៗ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយា-គតឹ គច្ឆេយ្យ គហិតាគហិតញ្ច ជានេយ្យ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការសន្មតិភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកទទួលនូវចីវរ គឺភិក្ខុណាមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១

មិនដល់នូវមោហាគតិ ១ មិនដល់នូវភយាគតិ ១ អាចដឹងនូវចីវរដែលខ្លួនបានទទួលហើយនិងចីវរដែលមិនបានទទួល១ ។ ត្រូវសន្មតយ៉ាងនេះ សង្ឃត្រូវសូមឬអង្វរភិក្ខុនោះជាមុន លុះអង្វររួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរប្បដិគ្គាហកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ចីវរប្បដិគ្គាហកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ចីវរប្បដិគ្គាហកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទទួលនូវចីវរ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទទួលនូវចីវរ ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទទួលនូវចីវរ គាប់ចិត្តដល់លោកអ្នកមានអាយុ

អង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកទទួលនូវចីវរហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

សម្មតិដូចបាននិយាយមកនេះ ហៅថា ចីវរប្បដិគ្គាហកសម្មតិ ក្នុងញត្តិទុយតិកម្មកថានេះ ។

ភណ្ឌាគារិកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នករក្សាឃ្លាំង ។ មានរឿងដូចតទៅនេះ សម័យនោះឯង ពួកភិក្ខុជាអ្នកទទួលចីវរ ទទួលរួចហើយទុកត្រង់កន្លែងដែលនោះ ហើយដើរចេញទៅ ចីវរក៏វិនាសខូចបង់ទៅ ។ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ចីវរនិទាហកំ សម្មន្និតុំ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ និទហិតានិទហិតញ្ច ជានេយ្យ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការសន្មតិនូវភិក្ខុប្រកបដោយអង្គ ៥ ឲ្យជាអ្នកទុកដាក់នូវចីវរ គឺភិក្ខុណាមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ១ មិនដល់នូវភយាគតិ១ អាចដឹង

នូវចីវរដែលខ្លួនទុកដាក់ហើយនឹងចីវរដែលមិនទាន់ទុកដាក់ ១ ។ ត្រូវសន្មតយ៉ាងនេះ សង្ឃត្រូវសូមឬអង្វរភិក្ខុនោះជាមុន លុះអង្វររួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរនិទាហកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរនិទា-ហកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ចីវរនិទាហកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នា-មោ) ភិក្ខុ ចីវរនិទាហកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទុកដាក់នូវចីវរ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទុកដាក់នូវចីវរ ការសម្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទុកដាក់នូវចីវរ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់

លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយ ឡើង ៗ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកទុកដាក់នូវចីវរ ហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃ ស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ៗ

សម័យនោះឯង ពួកភិក្ខុជាអ្នកទុកដាក់ចីវរ ទុកក្នុងបណ្ឌបខ្លះ ក្រោមម្លប់ឈើខ្លះ ក្រោមយុរស្បូវខ្លះ កណ្ដាលវាលខ្លះ ត្រូវកណ្ដុរកាត់ខ្លះ កណ្ដៀររោរខ្លះ ៗ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ ភណ្ឌាគារំ សម្មន្និតុំ យំ សង្ឃោ អាកង្ខតិ វិហារំ វា អឌ្ឍយោគំ វា បាសាទំ វា ហម្មិយំ វា គុហំ វា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវការសន្មតិនូវឃ្លាំង ពោះបើសង្ឃស្រឡាញ់សេនាសនៈណាគឺ វិហារ ក្ដី ប្រាសាទមានសណ្ឋានដូចស្លាបត្រុឌក្ដី ប្រាសាទវែងក្ដី ប្រាសាទ មានដំបូលត្រនិលក្ដី គូហាក្ដី ក៏បាន ៗ ត្រូវសន្មតយ៉ាងនេះ ភិក្ខុអ្នក ឈ្លាសប្រតិពលត្រូវផ្ដៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) វិហារំ ភណ្ឌាគារំ សម្មន្នេយ្យ ឯសា ញត្តិ ៗ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) វិហារំ ភណ្ឌាគារំ សម្មន្នតិ យស្សាយស្មតោ

ខមតិ (ឥត្ថន្នាមស្ស) វិហារស្ស ភណ្ឌាគារស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) វិហារោ ភណ្ឌាគារំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវវិហារ (ឈ្មោះនេះ) ឲ្យជាឃ្លាំង នេះហៅថាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវវិហារ (ឈ្មោះនេះ) ឲ្យជាឃ្លាំង ការសន្មតិនូវវិហារ (ឈ្មោះនេះ) ឲ្យជាឃ្លាំង គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមាន-អាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ វិហារ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាឃ្លាំងហើយ ការសន្មតនោះគាប់-ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។*

*ការសន្មតិភិក្ខុឲ្យជាអ្នកទុកដាក់ចីវរនឹងការសន្មតិឃ្លាំងសម្រាប់ដាក់ចីវរនេះ មិនមានមាតិការៀងទុកខាងដើមទេ ប៉ុន្តែបានជាស្រង់មកដាក់ក្នុងទីនេះផង ដើម្បីឲ្យឃើញបុព្វហេតុនៃភណ្ឌាគារិកសម្មតិ ។*

ភណ្ឌាគារិកសម្មតិ *ការសន្មតិនូវភិក្ខុឲ្យជាអ្នករក្សាឃ្លាំងចីវរ ។*

មានសេចក្តីដូចតទៅនេះ សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឃឥតមាន
នរណាមួយថែទាំរក្សាឡើយ ។ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គត្រាស់ថា អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ ភណ្ឌាគារិកំ សម្មន្និតុំ យោ ន ឆន្ទាគតិំ គច្ឆេយ្យ ន ទោសាគតិំ គច្ឆេយ្យ ន មោហាគតិំ គច្ឆេយ្យ ន ភយាគតិំ គច្ឆេយ្យ គុត្តាគុត្តញ្ច ជានេយ្យ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការសន្មតិនូវភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នករក្សាឃ្លាំង គឺភិក្ខុណាមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ ១ មិនដល់នូវភយាគតិ ១ អាចដឹងនូវចីវរដែលខ្ទង់រក្សាហើយនឹងចីវរដែលមិនបានរក្សា ១ ។ សន្មតយ៉ាងនេះ ត្រូវសង្ឃសូមឬអង្វរភិក្ខុនោះជាមុន លុះអង្វររួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភណ្ឌាគារិកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភណ្ឌាគារិកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភណ្ឌាគារិកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ

ភណ្ឌាគារិកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវសន្មតនូវភិក្ខុ (ៈឈ្មោះនេះ) ឲ្យជាអ្នករក្សាឃ្លាំង នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ៈឈ្មោះនេះ) ឲ្យជាអ្នករក្សាឃ្លាំង ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នករក្សាឃ្លាំងគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជានាយឃ្លាំងហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

សម្មតិខាងចុងដូចបាននិយាយមកនេះហៅថា ភណ្ឌាគារិកសម្មតិ ។

ចីវរភាជកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកចីវរ ។ មានរឿងហេតុជាលំដាប់តគ្នាទីងសម្មតិមុនថា កាលបើកើតឃ្លាំងចីវរសព្វគ្រប់ហើយ ចីវរក្នុងឃ្លាំងរបស់សង្ឃនោះ ក៏កាន់តែកើតក្រាស់ក្រែលឡើងជាលំដាប់ ។ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គអនុញ្ញាតថា អនុជានាមិ ភិក្ខវេ សម្មន្និតុំ ចីវរភាជកំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការចែកចីវរដោយមានសង្ឃនៅក្នុងទី

ចំពោះមុខ ។ សម័យនោះឯង សង្ឃទាំងអស់កំពុងចែកចីវរក៏និយាយគ្នាឮសូរស័ព្ទកងរំពងហួសប្រមាណ ។ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់អនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុប្រកបដោយអង្គ៥ ឲ្យជាអ្នកចែកចីវរ គឺ ភិក្ខុជ្រះស្រឡះពីអគតិទាំង ៤ ព្រមទាំងដឹងច្បាស់នូវចីវរដែលខ្លួនបានចែកហើយនឹងចីវរដែលពុំបានចែក ដោយវិធីសូត្រញត្តិទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរភាជកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ចីវរភាជកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ចីវរភាជកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ចីវរភាជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវចីវរ នេះហៅថាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវចីវរ ការសន្មតិនូវភិក្ខុ

(ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវចីវរ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកចែកនូវចីវរហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

យាគុភាជកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកចែកនូវបបរ ។ មានវិធីសូត្រញត្តិទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ យាគុភាជកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ( ឥត្ថន្នាមំ ) ភិក្ខុំ យាគុភាជកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស ) ភិក្ខុនោ យាគុភាជកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ ភិក្ខុ) យាគុភាជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវបបរ នេះ

ហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវបបរ ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវបបរ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកចែកនូវបបរហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបាន-ជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ខជ្ជកភាជកសម្មតិ ការសន្មតិនូវភិក្ខុ ឲ្យជាអ្នកចែកចំណី (បង្អែម) ត្រូវសន្មតដោយវិធីសូត្រញត្តិទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ខជ្ជកភាជកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ខជ្ជកភាជកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ខជ្ជកភាជកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខជ្ជកភាជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ

ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវចំណី នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវចំណី ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកចែកនូវចំណី គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ(ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកចែកនូវចំណីហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

អប្បមត្តកវិស្សជ្ជកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកលះបង់នូវបរិក្ខារពាយរេធបន្ទាប់បន្សំ ។ មានរឿងថា សម័យនោះឯង បរិក្ខារតូចតាចប្អូកយរេធបន្ទាប់បន្សំ កើតឡើងគ្រាស់គ្រែលក្នុងឃ្លាំងរបស់សង្ឃ ។ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ. ព្រះអង្គអនុញ្ញាតឲ្យសង្ឃសន្មតនូវភិក្ខុប្រកបដោយអង្គ ៥ ឲ្យជាអ្នកលះបង់នូវបរិក្ខារពាយរេធ គឺភិក្ខុដែលជ្រះស្រឡះពីអគតិទាំង ៤ ព្រមទាំងដឹងនូវបរិក្ខារដែលខ្លួនលះបង់ ហើយនិងបរិក្ខារដែលពុំទាន់លះបង់ ដោយវិធីសូត្រញត្តិទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស

បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អប្បមត្តកវិស្សជ្ជកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អប្បមត្តកវិស្សជ្ជកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អប្ប-មត្តកវិស្សជ្ជកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ អប្បមត្តកវិស្សជ្ជកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកលះបង់នូវបរិក្ខារកាយរង នេះហៅថាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកលះបង់នូវបរិក្ខារកាយរង ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកលះបង់នូវបរិក្ខារកាយរង គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកលះបង់នូវបរិក្ខារកាយរងហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។*

បរិក្ខារកាយវេនបន្ទាប់បន្សំដែលត្រូវលះបង់បាននោះគឺ សូចិ ម្ជុល, សត្ថកំ កាំបិតតូច, ឧបាហនា ស្បែកជើង, កាយពន្ធនំ វត្ថពន្ធចង្កេះ, អំសវដ្ដកោ យោគបាត្រ, បរិស្សាវនំ សំពត់តម្រងទឹក, ធម្មករកោ ធម្មក្រក, កាសិ សំពត់ខ្វង់វែង, អឌ្ឍកាសិ សំពត់ខ្វង់ខ្លី, មណ្ឌលំ សំពត់កន្សែងធំ, អឌ្ឍមណ្ឌលំ សំពត់កន្សែងតូច, អនុវាតោ អនុវាតបណ្ដោយឬអនុវាតខ្វាង, បរិភណ្ឌំ អនុវាតទទឹងឬអនុវាតពោះ ៗ

ចំណែកភេសជ្ជបរិក្ខារគឺ សប្បិ ទឹកដោះរាវ, តេលំ ប្រេងឬខ្លាញ់, មធុ ទឹកឃ្មុំ, ផាណិតំ ស្ករអំពៅឬស្ករជាអនុលោម; ភេសជ្ជទាំងនេះគួរឲ្យត្រឹមតែល្មមគាន់ម្ដង ប៉ុន្តែបើឲ្យញយ ៗ ក៏បាន ៗ បរិក្ខារកាយវេនទាំងអម្បាលនេះ អប្បមត្តកវិស្សជ្ជកកិច្ច អាចឲ្យផលកិច្ច ដែលត្រូវការ ដោយមិនបាច់ធ្វើអបលោកនកម្មឡើយ ៗ

សាដិយគ្គាហាបកសម្មតិ ការសន្មតិទុកភិក្ខុឲ្យជាអ្នកប្រគល់នូវសំពត់, ដោយញត្តិទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សាដិយគ្គាហាបកំ សម្មន្នេយ្យ ឯសា ញត្តិ ៗ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សាដិយគ្គាហាបកំ សម្មន្នតិ

យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ សាដិយគ្គា-ហាបកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ សាដិយគ្គាហាបកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវសំពត់ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវសំពត់ ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវសំពត់ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកប្រគល់នូវសំពត់ហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបាន-ជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។*

បត្តគ្គាហាបកសម្មតិ *ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រគល់នូវបាត្រៗ មានរឿងក្នុងឩនបញ្ចពន្ធនសិក្ខាបទថា សម័យនោះ ព្រះមានព្រះភាគ*

ទ្រង់គង់នៅក្នុងនិគ្រោធារាមទៀបក្រុងកបិលវត្ថុក្នុងសក្កជនបទ (នេប៉ាល) សម័យនោះឯង មានស្ទូនឆ្នាំងម្នាក់ បវារណាពួកភិក្ខុដោយបាត្រ, ពួកភិក្ខុមិនស្គាល់ប្រមាណក៏ចេះតែនាំគ្នាសូមបាត្រជាច្រើន, ពួកភិក្ខុដែលមានបាត្រតូច ៗ ក៏ត្រឡប់ទៅជាសូមយកបាត្រធំ ៗ, ស្ទូនឆ្នាំងនោះក៏រវល់តែនឹងធ្វើបាត្រប្រគេនភិក្ខុ មិនអាចនឹងធ្វើរបស់សម្រាប់លក់ដូរបានឡើយ ក៏ទៅជាខ្វះខាតខ្លួនឯង ទាំងកូនប្រពន្ធក៏បានសេចក្ដីលំបាក ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ដោយរឿងនោះជាច្រើន ។ ពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាតិចក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ ។ ទ្រង់បញ្ញត្តថា ន ភិក្ខវេ បត្តោ វិញ្ញាបេតព្វោ យោ វិញ្ញាបេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសូមបាត្រគេទេ ភិក្ខុណាសូមគេត្រូវអាបត្តិទុក្កដ ។

សម័យនោះឯង មានភិក្ខុ ១ រូបមានបាត្របែក ភិក្ខុនោះមិនហ៊ានសូមបាត្រគេក៏ដើរបិណ្ឌបាតដោយដៃទទេ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍ដើរបិណ្ឌបាតដដៃទទេ ដូចជាពួកតិរ្ថិយ ។ ពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ , ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ នដ្ឋបត្តស្ស វា ភិន្នបត្តស្ស វា បត្តំ វិញ្ញាបេតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការ

សូមបាត្រដល់ភិក្ខុដែលមានបាត្រវិនាសទៅហើយ ឬភិក្ខុដែលមានបាត្របែកហើយ ។

សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងការណ៍នោះហើយ ខ្លះមានបាត្របែកតែបន្តិច ខ្លះមានបាត្រធ្លុះតែបន្តិច ខ្លះមានបាត្រប្រេះឆាតែបន្តិច ខ្លះមានបាត្រមានស្នាមគំនូសតែបន្តិច ក៏នាំគ្នាសូមបាត្រគេជាច្រើនមិនស្គាល់ប្រមាណ ។ ស្មូនផ្ទាំងនោះរវល់តែធ្វើបាត្រប្រគេនពួកភិក្ខុ មិនអាចធ្វើរបស់សម្រាប់លក់ដូរ ទៅជាខ្វះខាតខ្លួនឯង ទាំងកូនប្រពន្ធក៏បានសេចក្ដីលំបាក ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ដូច្នោះទៀត ។ ពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាតិចក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគដូច្នោះទៀត ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទថា យោ បន ភិក្ខុ ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។ តេន ភិក្ខុនា សោ បត្តោ ភិក្ខុបរិសាយ និស្សជ្ជិតព្វោ ។ យោ ច តស្សា ភិក្ខុបរិសាយ បត្តបរិយន្តោ សោ ច តស្ស ភិក្ខុនោ បទាតព្វោ អយន្តេ ភិក្ខុ បត្តោ យាវ ភេទនាយ ធារេតព្វោតិ ។ អយំ តត្ថ សាមីចិ ។

ភិក្ខុណាមួយមានបាត្រមានចំណងមិនទាន់គ្រប់ប្រាំអន្លើ សូមបាត្រដទៃទៀត បាត្រនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនោះ ត្រូវលះបង់បាត្រនោះដល់ភិក្ខុបរិសទ្យ បាត្រណាដែលជាទី

បំផុតរបស់ភិក្ខុបរិសទ្យនោះ ត្រូវប្រគល់បាត្រនោះដល់ភិក្ខុនោះ ដោយពាក្យថា ម្នាលភិក្ខុ បាត្រនេះជារបស់អ្នក អ្នកត្រូវប្រើប្រាស់ដរាបដល់បែកចុះ ។ នេះជាកិច្ចដ៏សមគួរក្នុងសិក្ខាបទនោះ ។ បាត្រនោះត្រូវលះបង់ដូច្នេះ ភិក្ខុនោះត្រូវចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ។ អង្គុយច្រហោងផ្គងអញ្ជលីឡើងពោលថា អយំ មេ ភន្តេ បត្តោ ឩនបញ្ចពន្ធនេន បត្តេន ចេតាបិតោ និស្សគ្គិយោ, ឥមាហំ សង្ឃស្ស និស្សជ្ជាមិ បពិត្រព្រះសង្ឃដ៏ចំរើន នេះបាត្ររបស់ខ្ញុំ. ខ្ញុំមានបាត្រចាស់មានចំណងមិនទាន់គ្រប់ ៥ អន្លើ, បានសូមគេហើយ ជានិស្ស-គ្គិយ, ខ្ញុំសូមលះបង់នូវបាត្រនេះដល់សង្ឃ ។ ភិក្ខុនោះ លុះលះបង់រួចហើយ ត្រូវសំដែងអាបត្តិចេញ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវទទួលអាបត្តិ ។ លុះសំដែងអាបត្តិរួចហើយ សង្ឃត្រូវសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកប្រគល់បាត្រ គឺភិក្ខុដែលមិនលុះដោយអគតិទាំង៤ ព្រមទាំងដឹងច្បាស់នូវបាត្រដែលភិក្ខុនោះបានទទួលយកហើយ និងបាត្រដែលមិនបានទទួលយក ។ ទ្រង់អនុញ្ញាតឲ្យសង្ឃសន្មតដោយញត្តិ-ទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ បត្តគ្គាហា-បកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ

សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ បត្តគ្គាហាបកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ បត្តគ្គាហាបកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ បត្តគ្គាហាបកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវបាត្រ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវបាត្រ ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រគល់នូវបាត្រ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកប្រគល់នូវបាត្រហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ភិក្ខុដែលបានសម្មតិអំពីសង្ឃហើយត្រូវប្រគល់បាត្រ, វិធីប្រគល់នោះដូច្នេះ ភិក្ខុបរិសទ្យមានចំនួនប៉ុន្មានរូប ត្រូវមានបាត្រមួយៗរាល់រូប ត្រូវអង្គុយជាជួររៀងគ្នា ព្រះថេរៈអង្គុយដើមអាសន៍ ភិក្ខុជាគំរប់ពីរ

អង្គុយបន្ទាប់ព្រះថេរៈ ភិក្ខុឯទៀតៗក៏អង្គុយជាលំដាប់រៀងគ្នាទៅ ភិក្ខុអ្នកប្រព្រឹត្តកន្ទុងអង្គុយចុងអាសន៍បំផុត ភិក្ខុអ្នកប្រគល់បាត្រត្រូវយកបាត្ររបស់ភិក្ខុអ្នកប្រព្រឹត្តកន្ទុងនោះប្រគល់ដល់ព្រះថេរៈ ត្រូវយកបាត្រព្រះថេរៈប្រគល់ដល់ភិក្ខុជាគំរប់ពីរ ត្រូវប្រគល់ជាលំដាប់រហូតដល់ភិក្ខុខ្ចីជាងគេបង្អស់ ប៉ុន្តែមិនត្រូវប្រគល់ឲ្យដល់ភិក្ខុដែលគ្មានបាត្រឡើយ បើភិក្ខុអ្នកប្រគល់បាត្របានប្រគល់ដល់ភិក្ខុណា ភិក្ខុនោះត្រូវតែទទួលខានពុំបាន ដ្បិតមានបញ្ញត្តថា ន ប តស្ស អនុទ្ទយតាយ ន គហេតព្វោ យោ ន គណ្ហេយ្យ អាបត្តិ ទុក្កដស្ស ត្រូវតែទទួលបាត្រនោះខានពុំបាន ដោយសេចក្ដីអាណិតដល់ភិក្ខុអ្នកប្រព្រឹត្តកន្ទុងនោះ ភិក្ខុណាមិនទទួល ត្រូវអាបត្តិទុក្កដ ។ បាត្រដែលនៅសល់ក្រោយគេបំផុតត្រូវប្រគល់ដល់ភិក្ខុអ្នកប្រព្រឹត្តកន្ទុង ប្រាប់ថា បាត្រនេះជារបស់លោកៗប្រើប្រាស់ត្រាតែបែកចុះ ។

អារាមិកបេសកសម្មុតិ ការសន្មតិទូវភិក្ខុឲ្យជាអ្នកប្រើទូវញោមវត្ត ដោយវិធីសូត្រញត្តិទុតិយកម្មវាចាដូច្នេះ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អារាមិកបេសកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អារាមិកបេសកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ

អារាមិកបេសកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ អារាមិកបេសកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើយម្ងតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រើនូវញោមវត្ត នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រើនូវញោមវត្ត ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រើនូវញោមវត្ត គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកប្រើនូវញោមវត្តហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។*

*សាមណេរបេសកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកប្រើនូវសាមណេរ ដោយវិធីសូត្រញត្តិទុតិយកម្មវាចាដូច្នេះ* សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សាមណេរបេសកំ សម្មន្នេយ្យ ឯសា ញត្តិ ។ សុណាតុ

មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សាមណេរបេសកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ សាមណេរបេសកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ សាមណេរបេសកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

*បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រើនូវសាមណេរ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រើនូវសាមណេរ ការសន្មតិនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកប្រើនូវសាមណេរ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុ (ឈ្មោះនេះ) សង្ឃបានសន្មតឲ្យជាអ្នកប្រើនូវសាមណេរហើយ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។*

*ការសន្មតិទាំងឡាយ មានសន្មតនូវសីមាជាដើម ដែលបាននិយាយមកដោយពិស្តារនេះ ហៅថា សម្មតិ ក្នុងញត្តិទុតិយកម្មកថានេះ ។*

ធាន៨ ការឲ្យ ៗ ឲ្យក្នុងទីនេះសំដៅយកកឋិនចីវរទានគឺការឲ្យនូវចីវរកឋិនដោយញត្តិទុតិយកម្មវាចា ដល់ភិក្ខុ ១ រូបដែលគួរក្រាលកឋិនបាន ។ មានរឿងក្នុងកឋិនក្ខន្ធកដូចតទៅនេះ សម័យនោះព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកបាឋេយ្យកភិក្ខុ(១)ប្រមាណ ៣០ រូប ជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គទាំងអស់ ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គទាំងអស់ ជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គទាំងអស់ ជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គទាំងអស់ នាំគ្នាទៅកាន់ក្រុងសាវត្ថី ដើម្បីក្រាបបង្គំគាល់ព្រះមានព្រះភាគ, ដល់ថ្ងៃជិតចូលវស្សា ពុំអាចនឹងទៅចូលវស្សាក្នុងក្រុងសាវត្ថី ក៏នាំគ្នានៅចាំវស្សាត្រឹមក្រុងសាកេតនាពាក់កណ្តាលផ្លូវ ។ ភិក្ខុទាំងនោះនៅចាំវស្សាទាំងមានសេចក្តីអផ្សុកចិត្តថា ព្រះមានព្រះភាគគង់នៅជិតបង្កើយ ចម្ងាយ ៦ យោជន៍ពីនេះសោះ មិនសមបើយើងរាល់គ្នាមិនបានឃើញព្រះអង្គសោះឡើយ ! ភិក្ខុទាំងនោះ លុះចាំវស្សាគ្រប់ ៣ ខែបានបវារណារួចហើយ កំពុងរដូវភ្លៀងមានទឹកដក់នៅច្រើន មានភក់ក៏ច្រើន ទទឹកចីវរស្អាប់ លំបាកខ្លាំងក៏នាំគ្នាសំដៅទៅរកព្រះអង្គក្នុងវត្តជេតពន លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះអង្គទ្រង់ធ្វើ

---

១ អាណាខេត្តបាឋេយ្យនៅក្នុងដែនកោសល ប៉ុន្តែនៅចំណែកទិសខាងលិច, ភិក្ខុនៅក្នុងដែននោះហៅថា បាឋេយ្យកភិក្ខុ ៗ ទាំងនោះជាព្រះរៀមព្រះអនុជ្ជ (បងប្អូន) នៃព្រះបាទកោសល រួមបិតាជាមួយគ្នា បានបួសក្នុងធម្មវិន័យហើយ បានតាមថា ភទ្ទវគ្គិយត្ថេរ ចំនួន ៣០ អង្គ ។ អដ្ឋកថា ។

បដិសណ្ឋារៈសាកសួរសេចក្តីសុខទុក្ខគ្រប់ប្រការ ។ ពួកភិក្ខុក្រាបបង្គំទូលសព្វគ្រប់ថា ខ្ញុំព្រះអង្គទាំងអស់គ្នានៅចាំវស្សានេះព្រមព្រៀងគ្នារីករាយរកគ្នាមិនទាស់ទែងគ្នាទេ មិនលំបាកដោយចង្ហាន់បិណ្ឌបាតទេ តែថាមកចាំវស្សាក្នុងក្រុងសាវត្ថីនេះមិនទាន់ ព្រោះថ្ងៃជិតចូលវស្សាណាស់ទៅហើយ ក៏នាំគ្នាចាំវស្សាក្នុងក្រុងសាកេត កើតមានសេចក្តីអផ្សុកព្រោះហេតុថាព្រះអង្គគង់នៅមិនឆ្ងាយប៉ុន្មាន ប្រមាណ៦យោជន៍ប៉ុណ្ណោះទេម្តេចក៏មិនបានមកក្រាបបង្គំគាល់ឲ្យបានដូចបំណងពីនាយ ? លុះដល់ចាំវស្សាគ្រប់៣ខែបានបវារណារួចហើយ កំពុងរដូវភ្លៀងច្រើន មានទឹកដក់នៅក៏ច្រើន មានភក់ផុងល្បាប់ក៏ក្រៃលនាំគ្នាដើរមកតាមផ្លូវលំបាកពេក ទាំងចីវរក៏ទទឹកអួរអាប់មិនជាបើបីទេ ។ ព្រះមានព្រះភាគទ្រង់យកដំណើរនេះជាហេតុ ទើបទ្រង់ឲ្យប្រជុំភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតកឋិនថា អនុជានាមិ ភិក្ខវេ វស្សំ វុដ្ឋានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការក្រាលនូវកឋិនដល់ភិក្ខុទាំង-ឡាយ ដែលបាននៅចាំវស្សារួចហើយ ។ លំដាប់អំពីនេះទៅទ្រង់អនុញ្ញាតអានិសង្សកឋិនមាន ៥ ប្រការដូចតទៅនេះគឺ:

១-អនាមន្តចារោ ការត្រេចចរចាកអាវាសទៅក្នុងត្រកូលដោយមិនបាច់លាមិនបាច់ប្រាប់ភិក្ខុផងគ្នាបាន (មិនត្រូវអាបត្តិក្នុងចារិត្តសិក្ខាបទ)

២-អសមាទានចារោ ការត្រេចចរទៅកាន់ទីដទៃ ដោយមិនបាច់នាំយកត្រៃចីវរទៅផង នៅប្រាសចាកត្រៃចីវរណាមួយបាន ( មិន

ត្រូវអាបត្តិកន្ទុតិយកឋិនសិក្ខាបទ ឬ ដែលហៅថា ទុតេយ្យសិតសិក្ខាបទ )

៣- គណភោជនំ ឆាន់គណភោជនបាន គឺភោជនទាំង ៥ ដែលភិក្ខុសុំគេបញ្ចេញឈ្មោះ ឬគេនិមន្តបញ្ចេញឈ្មោះភោជនទាំង ៥ នោះ[1] ( មិនត្រូវអាបត្តិកន្ទុគណភោជនសិក្ខាបទ )

៤- យាវទត្ថចីវរំ ទុកទ្រង់ឬប្រើប្រាស់អតិរេកចីវរបានតាមត្រូវការ ( មិនត្រូវអាបត្តិកន្ទុបឋមកឋិនសិក្ខាបទ )

៥- យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ កំណើតចីវរណាដែលមានក្នុងអាវាសនោះ កំណើតចីវរនោះ នឹងមានប្រយោជន៍ដល់ភិក្ខុទាំងនោះដែលបានក្រាលបានអនុមោទនាកឋិន ។

ការក្រាលនូវកឋិននោះ ត្រូវភិក្ខុអ្នកឈ្លាសប្រតិពលផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ឯសា ញត្តិ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ សង្ឃោ ឥមំ កឋិនទុស្សំ ( ឥត្ថន្នាមស្ស) ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស (ឥត្ថន្នាមស្ស) ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស

---

១ ភោជនទាំង ៥ នោះគឺ ឧទនោ បាយ ១ កុម្មាសោ នំ ១ សត្តុ នំសត្វូវ ១ មច្ឆោ ត្រី ១ មំសំ សាច់ ១ ។

នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ កឋិនំ អត្ថរិតុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សំពត់កឋិននេះ កើតឡើងហើយដល់សង្ឃ បើកឋិនកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលនូវកឋិន នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សំពត់កឋិននេះ កើតឡើងហើយដល់សង្ឃ (ឥឡូវ) សង្ឃឲ្យនូវសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលនូវកឋិន ការឲ្យនូវសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលនូវកឋិន គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សំពត់កឋិននេះសង្ឃបានឲ្យដល់ភិក្ខុ (ឈ្មោះនេះ) ហើយដើម្បីក្រាលនូវកឋិន ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។*

*ការឲ្យនូវសំពត់កឋិនដល់ភិក្ខុដែលគួរក្រាលកឋិនបាន ដោយញត្តិទុតិយកម្មវាចា ដូចបាននិយាយមកនេះ ហៅថា ធាន ក្នុងញត្តិទុតិយកម្មកថានេះ ។*

ឧទ្ធារ ការដក ។ ដកនោះសំដៅយក កឋិនុទ្ធារ គឺការដកនូវកឋិនដែលសង្ឃបានក្រាលរួចហើយ ដោយមានហេតុអ្វីមួយដែលគួរនឹងដកបាន សង្ឃព្រមព្រៀងគ្នាដកបាន តាមពុទ្ធានុញ្ញាត ដូចមានរឿងក្នុងសិក្ខាបទទី ១០ នៃនគ្គវគ្គ បាចិត្តិយកណ្ឌ ភិក្ខុនីវិភង្គថា សម័យនោះព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានឧបាសកម្នាក់បានសាងវិហារចំពោះសង្ឃរួចហើយ, ឧបាសកនោះនឹកចង់ប្រគេនអកាលចីវរដល់ឧភតោសង្ឃ[១] ក្នុងការបុណ្យឆ្លងវិហារនោះ ។ សម័យនោះឯង ឧភតោសង្ឃបានក្រាលកឋិនរួចហើយ ។ ទើបឧបាសកនោះ ចូលទៅរកភិក្ខុសង្ឃអង្វរសូមឲ្យភិក្ខុសង្ឃដកកឋិន ដើម្បីបានឱកាសប្រគេនអកាលចីវរឲ្យបានគ្រប់អង្គ ។ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគៗទ្រង់យករឿងនោះជាហេតុ ទើបទ្រង់អនុញ្ញាតថា

---

១ ភិក្ខុសង្ឃ ១ ភិក្ខុនីសង្ឃ ១ ហៅថា ឧភតោសង្ឃ; ភិក្ខុ ឬភិក្ខុនី ដែលបានក្រាលបានអនុមោទនាកឋិនហើយ បានអានិសង្សកឋិនរហូតដល់ថ្ងៃ១៥កើតខែផល្គុន ចីវរកើតឡើងក្នុងកាលជាខេត្តកឋិននេះ ហៅថាកាលចីវរ; បើមិនបានក្រាលកឋិនទេ ចីវរដែលកើតឡើងក្នុងរវាង១១ខែ លើកលែងតែរនោចអស្សុជនឹងខ្នើតកត្តិកចេញ ហៅថាអកាលចីវរ ។ នេះជាប្រយោជន៍សាធារណៈគ្រប់ភិក្ខុឬភិក្ខុនី តាមបំណងរបស់ទាយក; ចំណែកខាងកាលចីវរត្រូវបានចំពោះតែភិក្ខុឬភិក្ខុនី ដែលបានក្រាលបានអនុមោទនាកឋិន; ព្រោះហេតុនោះឧបាសកនោះយល់ឃើញថា បើប្រគេនកាលចីវរទៅ បានប្រយោជន៍ចំពោះតែភិក្ខុឬភិក្ខុនី ដែលមានអានិសង្សកឋិន, ក៏បានសុំឲ្យសង្ឃដកកឋិន ឲ្យគ្មានអានិសង្សកឋិនគ្រប់អង្គទៅ. ដូច្នេះ កាលបើប្រគេនអកាលចីវរទៅ នឹងបានប្រយោជន៍គ្រប់អង្គមិនមានសល់ ។

អនុជានាមិ ភិក្ខវេ កឋិនំ ឧទ្ធរិតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការដកនូវកឋិន ។ ត្រូវដកដូច្នេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ កឋិនំ ឧទ្ធរេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ កឋិនំ ឧទ្ធរតិ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧទ្ធតំ សង្ឃេន កឋិនំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ បើឧទ្ធរណកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីដកនូវកឋិន នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃ ស្ដាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃដកនូវកឋិន ការដកនូវកឋិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ កឋិនសង្ឃបានដកហើយ ការដកនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

លំដាប់នោះ ឧបាសកនោះចូលទៅរកភិក្ខុនីសង្ឃអង្វរសូមឲ្យដកកឋិន ដើម្បីប្រគេនអកាលចីវរ ។

នាងថុល្លនន្ទាភិក្ខុនីហាមឃាត់នូវការដេកកឋិន ដោយមានគំនិតទុបាយចង់បានចីវរចំពោះខ្លួន ព្រមទាំងភិក្ខុនីដែលមានអានិសង្សកឋិនដូចគ្នា មិនចង់ឲ្យប្រយោជន៍ដល់ភិក្ខុនីឯទៀតផង ។ ឧបាសកនោះក៏ពោលទោសតិះដៀលបន្តុះបង្អាប់, ព្រោះរឿងនោះ ភិក្ខុនីទាំងឡាយដឹងហេតុនោះហើយក៏តិតដល់ពួកភិក្ខុៗ ក៏ក្រាបបង្គំទូលព្រះមានព្រះ - ភាគ. ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ហើយទ្រង់បញ្ញត្តសិក្ខាបទថា យា បន ភិក្ខុនី ធម្មិកំ កឋិនុទ្ធារំ បដិពាហេយ្យ បាចិត្តិយំ ភិក្ខុនីណាមួយ ហាមឃាត់នូវការដេកកឋិនដែលប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយ ។

ការដេកកឋិនប្រកបដោយធម៌ ដោយញត្តិទុតិយកម្មវាចាដូចបាននិយាយមកនេះហៅថា ឧទ្ធារ ក្នុងញត្តិទុតិយកម្មវាចានេះ ។

ទេសនា ការសំដែង ។ ការសំដែងនោះសំដៅយក កុដិ-វត្ថុទេសនា ការសំដែងទីដីសង់កុដិ ១ វិហារវត្ថុទេសនា ការសំដែងទីដីសង់វិហារ ១ ។

ការសំដែងទីដីសង់កុដិនោះ មានរឿងក្នុងកុដិការសិក្ខាបទថា សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវា-បស្ថាន នាក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកអាឡវិកភិក្ខុឲ្យគេធ្វើកុដិដែលមានគ្រឿងឧបករណ៍សូមពីគេមកខ្លួនឯង ឥតមានទាយកជា

ម្ចាស់របស់ បំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ នាំឲ្យក្រហើយ ក្របានសម្រេច បេះតែដើរសូមរៃអង្គាសគេញឹកញយពេក គេធុញទ្រាន់ដ៏ធ្ងន់ខ្លាំងណាស់ទៅ គេត្អូញត្អែរដៀលដោយពាក្យមិនគប្បីជាច្រើន ៗ ព្រះមហាកស្សបជ្រាបសេចក្តីនោះហើយក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ហើយ ទ្រង់បញ្ញត្តសិក្ខាបទ

៦ សញ្ញាចិកាយ បន ភិក្ខុនា កុដឹ ការយមានេន អស្សាមិកំ អត្តុទ្ទេសំ បមាណិកា ការេតព្វា តត្រិទំ បមាណំ ទីឃសោ ទ្វាទស វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ សត្តន្តរា ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ តេហិ ភិក្ខូហិ វត្ថុំ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ សារម្ភេ ចេ ភិក្ខុ វត្ថុស្មិំ អបរិក្កមនេ សញ្ញាចិកាយ កុដឹ ការេយ្យ ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ បមាណំ វា អតិក្កាមេយ្យ សង្ឃាទិសេសោ

កាលភិក្ខុឲ្យគេធ្វើកុដិ ដែលមិនមានទាយកជាម្ចាស់របស់ បំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង គប្បីធ្វើឲ្យត្រូវតាមខ្នាត ឯខ្នាតកុដិនោះដូច្នេះគឺ បណ្តោយ ១២ ចំអាម ទទឹង ៧ ចំអាម ដោយចំអាមព្រះសុគត វាស់ខាងក្នុងជញ្ជាំង, ត្រូវនាំភិក្ខុទាំងឡាយមកសំដែងទីដីឲ្យ ភិក្ខុទាំងនោះត្រូវសំដែងទីដី

ដែលមិនមានអន្តរាយ(១) ជាទីដីដែលមានឧបចារ(២), បើភិក្ខុឲ្យគេធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ក្នុងទីដែលប្រកបដោយអន្តរាយ ជាទីដីមិនមានឧបចារ មិនបាននាំពួកភិក្ខុមក ដើម្បីសំដែងទីដីឲ្យក្តី ធ្វើឲ្យកន្លងហួសខ្នាតក្តី ត្រូវអាបត្តិសង្ឃាទិសេស ។

ត្រង់ពាក្យថា ត្រូវនាំភិក្ខុទាំងឡាយមកសំដែងទីដីឲ្យ នោះ សេចក្តីថា ភិក្ខុអ្នកធ្វើកុដិនោះ ត្រូវឲ្យគេជំរះទីដីសង់កុដិនោះឲ្យស្អាត ហើយចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គធៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ៗ អង្គុយច្រហោងផ្គងអញ្ជលីឡើងពោលថា អហំ ភន្តេ សញ្ញាចិកាយ កុដឹ កត្តុកាមោ អស្សាមិកំ អត្តុទ្ទេសំ សោហំ ភន្តេ សង្ឃំ កុដិវត្ថុឱលោកនំ យាចាមិ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវធ្វើកុដិ មិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះសូមនូវការពិនិត្យមើលនូវទីដីសង់កុដិអំពីសង្ឃ ( សូត្រ ៣ ដង ) ។

បើសង្ឃទាំងអស់អាចទៅពិនិត្យមើលទីដីសង់កុដិនោះបាន ក៏ត្រូវទៅពិនិត្យមើលទាំងអស់អង្គ បើមិនអាចទេ ត្រូវសន្មតភិក្ខុណាដែលឈ្លាស

---

១ ទីដីដែលមានសំបុកស្រមោច សំបុកកណ្តៀរជាដើម នឹងទីដែលមានដំណាំ មានសណ្តែកល្ង នឹងស្រូវខ្សាយស្រូវជំណើបជាដើម ហៅថា ទីមានអន្តរាយ ។ ២ ទីជុំវិញកុដិទូលំទូលាយ ល្មមបង្វិលជណ្តើរបាន បង្វិលរទេះបាន ហៅថា ទីមានឧបចារ ។

*អាចស្គាល់ការគួរមិនគួរឲ្យទៅពិនិត្យមើលឲ្យត្រឹមត្រូវ, ត្រូវសន្មតដូច្នេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា* សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សញ្ញាចិកាយ កុដឹ កត្តុកាមោ អស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ កុដិវត្ថុឱលោកនំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច) ភិក្ខូ សម្មន្នេយ្យ (ឥត្ថន្នាមស្ស) ភិក្ខុនោ[1] កុដិវត្ថុំ ឱលោកេតុំ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សញ្ញាចិកាយ កុដឹ កត្តុកាមោ អស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ កុដិវត្ថុឱលោកនំ យាចតិ សង្ឃោ (ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច) ភិក្ខូ សម្មន្នតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ កុដិវត្ថុំ ឱលោកេតុំ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស ច ឥត្ថន្នាមស្ស ច) ភិក្ខូនំ សម្មតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ កុដិវត្ថុំ ឱលោកេតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា សង្ឃេន (ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច) ភិក្ខូ (ឥត្ថន្នាមស្ស) ភិក្ខុនោ កុដិវត្ថុំ ឱលោកេតុំ ខមតិ សង្ឃស្ស

---

១ ត្រូវបញ្ចូលនាមភិក្ខុទាំងនេះ ដោយមាន "ច" ផង ដូចជា ពុទ្ធរក្ខិតញ្ច ធម្មរក្ខិតញ្ច ភិក្ខូ សម្មន្នេយ្យ សង្ឃរក្ខិតស្ស ភិក្ខុនោ ... ។

តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើកុដិដែលមិនមានពាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ដោយការសូមនូវគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ភិក្ខុនោះសូមនូវការពិនិត្យមើលនូវទីដីសង់កុដិអំពីសង្ឃ បើសម្មតិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុទាំងឡាយ (ឈ្មោះនេះ ១ ឈ្មោះនេះ ១) ដើម្បីពិនិត្យមើលនូវទីដីសង់កុដិរបស់ភិក្ខុ (ឈ្មោះនេះ) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ ( ឈ្មោះនេះ ) នេះត្រូវការធ្វើកុដិដែលមិនមានពាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួនដោយការសូមនូវគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ភិក្ខុនោះសូមនូវការពិនិត្យមើលនូវទីដីសង់កុដិអំពីសង្ឃ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុទាំងឡាយ (ឈ្មោះនេះ ១ ឈ្មោះនេះ១) ដើម្បីពិនិត្យមើលនូវទីដីសង់កុដិរបស់ភិក្ខុ ( ឈ្មោះនេះ ) ការសន្មតិនូវភិក្ខុទាំងឡាយ (ឈ្មោះនេះ១ ឈ្មោះនេះ១) ដើម្បីពិនិត្យមើលនូវទីដីសង់កុដិរបស់ភិក្ខុ ( ឈ្មោះនេះ ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុទាំងឡាយ ( ឈ្មោះនេះ១ ឈ្មោះនេះ១) សង្ឃបានសន្មតហើយដើម្បីពិនិត្យមើលនូវទីដីសង្ឃកុដិរបស់ភិក្ខុ ( ឈ្មោះនេះ ) ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម

ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ភិក្ខុទាំងឡាយដែលបានសម្មតិអំពីសង្ឃហើយ ត្រូវទៅក្នុងទីនោះ ពិនិត្យមើលទីដីសង់កុដិឲ្យដឹងថា មានអន្តរាយ ឬមិនមានអន្តរាយ មានឧបចារ ឬមិនមានឧបចារ បើមានអន្តរាយ ទាំងមិនមានឧបចារទេ, ត្រូវឃាត់ថា កុំធ្វើក្នុងទីនេះ, បើមិនមានអន្តរាយទេ ទាំងប្រកបដោយឧប-ចារផង ត្រូវប្រាប់សង្ឃថា គ្មានអន្តរាយទេ ហើយប្រកបដោយឧបចារផង, ភិក្ខុអ្នកធ្វើកុដិនោះត្រូវចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គធៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ៗ អង្គុយច្រហោងផ្គងអញ្ជលីឡើងសូត្រសូមថា អហំ ភន្តេ សញ្ញាបិកាយ កុដឹ កត្តុ-កាមោ អស្សាមិកំ អត្តុទ្ទេសំ សោហំ ភន្តេ សង្ឃំ កុដិ-វត្ថុទេសនំ យាចាមិ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវការធ្វើកុដិ ដែលមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួនដោយការសូមនូវគ្រឿងឧបករណ៍គេមកដោយខ្លួនឯង បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំករុណានោះសូមនូវការសំដែងទីដីសង់កុដិអំពីសង្ឃ (សូត្រ ៣ ដង ) ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សញ្ញាបិកាយ កុដឹ កត្តុកាមោ អស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ កុដិវត្ថុទេសនំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស)

ភិក្ខុនោ កុដឹវត្ថុំ ទេសេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សញ្ញាចិកាយ កុដឹ កត្តុកាមោ អស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ កុដិវត្ថុទេសនំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ កុដឹវត្ថុំ ទេសេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ កុដឹវត្ថុស្ស ទេសនា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទេសិតំ សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ កុដឹវត្ថុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើកុដិ ដែលមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ដោយការសូមនូវគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ភិក្ខុនោះសូមនូវការសំដែងទីដីសង់កុដិអំពីសង្ឃ បើទេសនាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសំដែងនូវទីដីសង់កុដិដល់ភិក្ខុ (ឈ្មោះនេះ) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើកុដិ ដែលមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ដោយការសូមនូវគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ភិក្ខុនោះសូមនូវការសំដែងទីដីសង់កុដិ*

អំពីសង្ឃ ( ឥឡូវ ) សង្ឃសំដែងទីដីសង់កុដិ ដល់ភិក្ខុ ( ឈ្មោះនេះ ) ការសំដែងទីដីសង់កុដិដល់ភិក្ខុ ( ឈ្មោះនេះ ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់-ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ទីដីសង់កុដិសង្ឃបានសំដែង ដល់ភិក្ខុ (ឈ្មោះនេះ) ហើយ ការសំដែងនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

សេចក្តីក្នុងសិក្ខាបទនេះថា ភិក្ខុធ្វើកុដិ សង្ឃមិនបានសំដែងទីដីឲ្យ កុដិនោះធំហួសខ្នាត ទីដីនោះប្រកបដោយអន្តរាយតាំងគ្មានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស ២ ទុក្កដ ២ គឺសង្ឃាទិសេស ១ ព្រោះមិនសំដែងទីដី. សង្ឃាទិសេស ១ ទៀត ព្រោះកុដិនោះធំហួសខ្នាត, ទុក្កដ ១ ព្រោះទីដីប្រកបដោយអន្តរាយ, ទុក្កដ ១ ទៀតព្រោះទីដីចង្អៀតពេក គ្មានឧបចារជុំវិញកុដិ ។ បើសង្ឃបានសំដែងទីដីឲ្យ ប៉ុន្តែធ្វើកុដិធំហួសខ្នាតផង ប្រកបដោយអន្តរាយផង គ្មានឧបចារផង ត្រូវសង្ឃាទិសេស ១ ទុក្កដ២, បើសង្ឃបានសំដែងទីដីឲ្យផង ត្រូវតាមខ្នាតផង តែប្រកបដោយអន្តរាយផង គ្មានឧបចារផង ត្រូវទុក្កដ ២, បើសង្ឃបានសំដែងទីដីឲ្យផង ត្រូវតាមខ្នាតផង គ្មានអន្តរាយផង តែគ្មានឧបចារ ត្រូវទុក្កដ ១, បើសង្ឃបានសំដែងទីដីឲ្យផង ត្រូវតាមខ្នាតផង គ្មានអន្តរាយផង មានឧបចារផង មិនត្រូវអាបត្តិអ្វីឡើយ ។

វិហារវត្ថុទេសនា ការសំដែងនូវទីដីសង់វិហារ ( កុដិធំ ) ៗ មានរឿងក្នុងមហល្លកសិក្ខាបទ ដូចតទៅនេះ សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាមទៀបក្រុងកោសម្ពី ៗ សម័យនោះឯង គហបតីជាឧបដ្ឋាករបស់ឆន្នភិក្ខុ បាននិយាយនឹងឆន្នភិក្ខុថា សូមលោកម្ចាស់រកទីដីសង់វិហារ ខ្ញុំព្រះករុណានឹងសាងវិហារប្រគេនលោកម្ចាស់ ៗ លំដាប់នោះឆន្នភិក្ខុឲ្យគេជំរះទីដីសង់វិហារ ឲ្យគេកាប់ឈើជាទីគោរព ១ ដើម ដែលអ្នកស្រុកអ្នកនិគមអ្នកនគរអ្នកជនបទអ្នកដែនគេធ្លាប់គោរពបូជា ៗ មនុស្សទាំងឡាយពោលទោសតិះដៀលបន្តុះបង្អាប់; ព្រោះរឿងនោះ ពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ. ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទថា មហល្លកំ បន ភិក្ខុនា វិហារំ ការយមានេន សស្សាមិកំ អត្តុទ្ទេសំ ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ តេហិ ភិក្ខូហិ វត្ថុំ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ សារម្ភេ ចេ ភិក្ខុ វត្ថុស្មឹ អបរិក្កមនេ មហល្លកំ វិហារំ ការេយ្យ ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ សង្ឃាទិសេសោ ភិក្ខុកាលឲ្យគេធ្វើនូវវិហារធំ ដែលមានទាយកជាម្ចាស់របស់ បំពោះជាទីនៅរបស់ខ្លួន ត្រូវនាំភិក្ខុទាំងឡាយមកដើម្បីសំដែងទីដីឲ្យ. ភិក្ខុទាំងឡាយនោះត្រូវសំដែងទីដីដែលមិនមានអន្តរាយ ប្រកបដោយឧបចារ. បើភិក្ខុឲ្យគេធ្វើវិហារធំ ក្នុងទីដីដែលមានអន្តរាយ ទាំងមិនមានឧបចារ. ឬមិន

បាននាំភិក្ខុទាំងឡាយមកដើម្បីសំដែងទីដី ត្រូវអាបត្តិសង្ឃាទិសេស ។

ត្រង់ពាក្យថា ត្រូវនាំភិក្ខុទាំងឡាយមកដើម្បីសំដែងទីដីឲ្យ សេចក្តីថា ភិក្ខុអ្នកធ្វើវិហារនោះ ត្រូវឲ្យគេជំរះទីដីសង់វិហារ ហើយចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ៗ អង្គុយច្រហោងផ្គងអញ្ជលីឡើងសូត្រសូមថា អហំ ភន្តេ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោហំ ភន្តេ សង្ឃំ វិហារ-វត្ថុឱលោកនំ យាចាមិ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវការធ្វើវិហារធំ ដែលមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះសូមនូវការពិនិត្យមើលនូវទីដីសង់វិហារអំពីសង្ឃ (សូត្រ៣ដង) ។ បើសង្ឃគ្រប់អង្គអាចពិនិត្យមើលទីដីសង់វិហារនោះបាន ក៏ត្រូវទៅពិនិត្យមើលគ្រប់អង្គ បើមិនអាចទេ ត្រូវសន្មតភិក្ខុទាំងឡាយអ្នកឈ្លាស អាចដឹងនូវទីដីដែលមានអន្តរាយ ឬមិនមានអន្តរាយ មានឧបចារឬមិនមានឧបចារ, ត្រូវសន្មតយ៉ាងនេះ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុឱលោកនំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច) ភិក្ខូ សម្មន្នេយ្យ

(ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ឧល្លោកេតុំ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុ ឧល្លោកនំ យាចតិ សង្ឃោ (ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច) ភិក្ខូ សម្មន្នតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ឧល្លោកេតុំ យស្សា-យស្មតោ ខមតិ (ឥត្ថន្នាមស្ស ច ឥត្ថន្នាមស្ស ច) ភិក្ខូនំ សម្មុតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ឧល្លោកេតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា សង្ឃេន (ឥត្ថន្នា-មោ ច ឥត្ថន្នាមោ ច) ភិក្ខូ (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ឧល្លោកេតុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើវិហារធំ ដែលមានទាយកជាម្ចាស់របស់ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមនូវការពិនិត្យមើលនូវទីដីសង់វិហារអំពីសង្ឃ បើសម្មតិ-កម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុទាំងឡាយ (ឈ្មោះនេះ១ ឈ្មោះនេះ១) ដើម្បីពិនិត្យមើលនូវទីដីសង់វិហាររបស់ភិក្ខុ (ឈ្មោះនេះ) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះ

សង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើវិហារធំ ដែលមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមនូវការពិនិត្យមើលនូវទីដីសង់វិហារ អំពីសង្ឃ (ឥឡូវ) សង្ឃសន្មតនូវភិក្ខុទាំងឡាយ (ឈ្មោះនេះ ១ ឈ្មោះនេះ ១) ដើម្បីពិនិត្យមើលនូវទីដីសង់វិហាររបស់ភិក្ខុ (ឈ្មោះនេះ) ការសន្មតិនូវភិក្ខុទាំងឡាយ (ឈ្មោះនេះ ១ ឈ្មោះនេះ ១) ដើម្បីពិនិត្យមើលនូវទីដីសង់វិហាររបស់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុទាំងឡាយ (ឈ្មោះនេះ១ ឈ្មោះនេះ១) សង្ឃបានសន្មតហើយ ដើម្បីពិនិត្យមើលនូវទីដីសង់វិហាររបស់ភិក្ខុ (ឈ្មោះនេះ) ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ភិក្ខុទាំងឡាយនោះដែលបានសម្មតិអំពីសង្ឃហើយ ត្រូវទៅពិនិត្យមើលឲ្យដឹងថា មានអន្តរាយឬគ្មាន មានឧបចារឬគ្មាន បើមានអន្តរាយថែមទាំងគ្មានឧបចារទៀត ត្រូវឃាត់ថា កុំធ្វើត្រង់កន្លែងនេះ, បើគ្មានអន្តរាយទេ ទាំងឧបចារក៏មានដែរ ត្រូវប្រាប់ដល់សង្ឃ ។

ភិក្ខុអ្នកធ្វើវិហារនោះ ត្រូវចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ១ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង

*សូត្រសូមថា* អហំ ភន្តេ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោហំ ភន្តេ សង្ឃំ វិហារវត្ថុទេសនំ យាចាមិ *បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវការធ្វើវិហារធំ ដែលមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះសូមនូវការសំដែងទីដីសង់វិហារអំពីសង្ឃ (សូត្រ ៣ ដង) ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា*

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុទេសនំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ទេសេយ្យ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ មហល្លកំ វិហារំ កត្តុកាមោ សស្សាមិកំ អត្តុទ្ទេសំ សោ សង្ឃំ វិហារវត្ថុទេសនំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ទេសេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុទេសនា សោ តុណ្ហាស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទេសិតំ សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ វិហារវត្ថុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើវិហារធំ ដែលមានទាយកជាម្ចាស់របស់ បំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមនូវការសំដែងទីដីសង់វិហារអំពីសង្ឃ បើទេសនាគមមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសំដែងនូវទីដីសង់វិហារដល់ភិក្ខុ (ឈ្មោះនេះ) នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះត្រូវការធ្វើវិហារធំ ដែលមានទាយកជាម្ចាស់របស់ បំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមនូវការសំដែងទីដីសង់វិហារអំពីសង្ឃ (ឥឡូវ) សង្ឃសំ-ដែងទីសង់វិហារដល់ភិក្ខុ (ឈ្មោះនេះ) ការសំដែងទីដីសង់វិហារដល់ភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ ទីដីសង់វិហារសង្ឃបានសំដែងហើយ ដល់ភិក្ខុ (ឈ្មោះនេះ) ការសំដែងនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ក្នុងសិក្ខាបទនេះមានសេចក្តីថា ភិក្ខុធ្វើវិហារ សង្ឃមិនបានសំដែងទីដីឲ្យផង ទីដីមានអន្តរាយផង គ្មានឧបចារផង ត្រូវអាបត្តិសង្ឃាទិសេស ១ នឹងទុក្កដ ២ គឺសង្ឃាទិសេសព្រោះគ្មានសំដែងទីដី, ទុក្កដ ១ ព្រោះទីដីមានអន្តរាយ, ទុក្កដ ១ ទៀត ព្រោះគ្មានឧបចារ;

បើមិនបានសំដែងទីដីផង មានអន្តរាយផង តែមានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស ១ ទុក្កដ ១; បើមិនបានសំដែងទីដី តែគ្មានអន្តរាយ គ្មានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស ១ នឹងទុក្កដ ១ ដែរ; បើគ្មានសំដែងទីដីទេ តែគ្មានអន្តរាយផង មានឧបចារផង ត្រូវតែសង្ឃាទិសេស១; បើបានសំដែងទីដី តែមានអន្តរាយផង គ្មានឧបចារផង ត្រូវទុក្កដ២; បើបានសំដែងទីដី តែមានអន្តរាយ មានឧបចារ ត្រូវទុក្កដ ១; បើបានសំដែងទីដីផង គ្មានអន្តរាយផង តែគ្មានឧបចារ ក៏ត្រូវទុក្កដ ១ ដែរ; បើបានសំដែងទីដី គ្មានអន្តរាយផង មានឧបចារផង មិនត្រូវអាបត្តិអ្វីឡើយ ។

កុដិការទេសនា ការសំដែងនូវទីដីសង់កុដិ នឹងវិហារការទេសនា ការសំដែងនូវទីដីសង់វិហារ ដូចបាននិយាយមកនេះ ហៅថា ទេសនា ក្នុងញត្តិទុតិយកម្មកថានេះ ។

កម្មលក្ខណ ក្នុងទីនេះសំដៅយកញត្តិទុតិយកម្មវាចា ២ លើកដែលមានក្នុង តិណវត្ថារកសមថ ។ សេចក្តីថា ភិក្ខុទាំងឡាយកើតវិវាទទាស់ទែងគ្នា បំរុងនឹងបែកគ្នាទៅជាពីរពួក, ព្រះភគវន្តមុនីទ្រង់អនុញ្ញាតឲ្យសង្ឃរម្ងាប់អធិករណ៍នោះដោយ តិណវត្ថារកសមថ ទ្រង់អនុញ្ញាតឲ្យតាំងញត្តិទី ១ ហៅថា សព្វសង្គាហិកាញត្តិ ជាញត្តិរបស់ប្រមូលធ្វើជាមួយគ្នាទាំងពីរពួក; តពីនោះមក ទ្រង់អនុញ្ញាតញត្តិពីរទៀត គឺភិក្ខុមួយពួកធ្វើញត្តិមួយ មួយពួកទៀតធ្វើញត្តិមួយដែរ ត្រូវ

ជាញត្តិ ៣ ឯញត្តិទាំង ៣ នេះបាននិយាយរួចហើយត្រង់កម្មលក្ខណ ក្នុងញត្តិកម្មកថាខាងដើម ចំណែកខាងអានិសង្សនៅមិនទាន់បាននិយាយ ទុកនិយាយជាមួយគ្នាក្នុងទីនេះតែម្តង ។

ឯញត្តិទុតិយកម្មវាចាទាំងពីរនោះនៅជាលំដាប់រៀងគ្នានឹងញត្តិទាំង៣ ខាងដើមនោះដែរ ទ្រង់អនុញ្ញាតឲ្យភិក្ខុ ១ ពួកធ្វើញត្តិទុតិយកម្ម-វាចាថា សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌ-នជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡតាយ វាឡតាយ ភេទាយ សំវត្តេយ្យ យទិ សង្ឃស្ស បត្តកល្លំ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេ-សញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ

ភាសិតបរិក្កន្តំ សចេ មយំ ឥមាហិ អាបត្តីហិ អញ្ញមញ្ញំ ការេស្សាម សិយាបិ តំ អធិករណំ កក្ខឡត្តាយ វាឡ-ត្តាយ ភេទាយ សំវត្តេយ្យ អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេ-សញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេមិ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ យស្សាយស្មតោ ខមតិ អម្ហាកំ ឥមាសំ អាបត្តីនំ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសនា ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទេសិតា អម្ហាកំ ឥមា អាបត្តិយោ សង្ឃមជ្ឈេ តិណវត្ថារកេន ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ *បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ យើងទាំងឡាយ មានការបង្កហេតុ កើតសេចក្តីឈ្លោះគ្នា ដល់នូវវិវាទទាស់ទែងគ្នា បានប្រព្រឹត្តនូវអំពើមិនមែនជារបស់នៃសមណៈជាច្រើន បានពោលដោយវាចា បានព្យាយាមធ្វើដោយកាយ បើយើងទាំងឡាយនឹងញុំាងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ អធិ-*

ករណ៍នោះក៏នៅតែមានដដែល ថែមទាំងប្រព្រឹត្តទៅដើម្បីសេចក្ដីរឹងរូស ដើម្បីសេចក្ដីសាហាវ ដើម្បីបែកគ្នា បើទេសនាកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំគប្បីសំដែងនូវអាបត្តិរបស់លោកអ្នកមានអាយុទាំងឡាយនេះផង នូវអាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្ដាលជំនុំសង្ឃ ដោយ តិណវត្ថារកា ដើម្បីជាប្រយោជន៍ដល់លោកអ្នកមានអាយុទាំងឡាយនេះផង ដើម្បីជាប្រយោជន៍ដល់ខ្លួនខ្ញុំផង លើកលែងតែទោសដែលធ្ងន់ លើកលែងតែទោសដែលទាក់ទងដោយគ្រហស្ថ នេះហៅថា ញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ យើងទាំងឡាយមានការបង្កហេតុ កើតសេចក្ដីឈ្លោះគ្នា ដល់នូវវិវាទទាស់ទែងគ្នា បានប្រព្រឹត្តនូវអំពើមិនមែនជារបស់នៃសមណៈជាច្រើន បានពោលដោយវាចា បានព្យាយាមធ្វើដោយកាយ បើយើងទាំងឡាយនឹងញ៉ាំងគ្នានឹងគ្នាឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ អធិករណ៍នោះក៏នៅតែមានដដែល ថែមទាំងប្រព្រឹត្តទៅដើម្បីសេចក្ដីរឹងរូស ដើម្បីសេចក្ដីសាហាវ ដើម្បីបែកគ្នា (ឥឡូវ) ខ្ញុំសំដែងនូវអាបត្តិរបស់លោកអ្នកមានអាយុទាំងឡាយនេះផង នូវអាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្ដាលជំនុំសង្ឃ ដោយ តិណវត្ថារក ដើម្បីជាប្រយោជន៍ដល់លោកអ្នកមានអាយុទាំងឡាយនេះផង ដើម្បីជាប្រយោជន៍ដល់ខ្លួនខ្ញុំផង លើកលែងតែទោសដែលធ្ងន់ លើកលែងតែទោសដែលទាក់ទងដោយគ្រហស្ថ ការសំដែងនូវអាបត្តិទាំងឡាយនេះ របស់យើងទាំង-

ឡាយ ក្នុងកណ្ដាលជំនុំសង្ឃ ដោយ តិណវត្ថារក លើកលែងតែទោសដែលធ្ងន់ លើកលែងតែទោសដែលពាក់ទងដោយគ្រហស្ថ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ អាបត្តិទាំងឡាយនេះ យើងទាំង-ឡាយបានសំដែងហើយ ក្នុងកណ្ដាលជំនុំសង្ឃ ដោយ តិណវត្ថារក លើកលែងតែទោសដែលធ្ងន់ លើកលែងតែទោសដែលពាក់ទងដោយគ្រហស្ថ ការសំដែងនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបាន-ជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ភិក្ខុ ១ ពួកទៀត បានធ្វើញត្តិទុតិយកម្មវាចា ១ ទៀត ដូចគ្នានឹងញត្តិទុតិយកម្មវាចានេះដែរ ត្រូវជាញត្តិទុតិយកម្មវាចាពីរលើក ។

លំដាប់នោះព្រះមានព្រះភាគទ្រង់ត្រាស់ថា ភិក្ខុទាំងឡាយនោះរួចចាកអាបត្តិទាំងឡាយនោះ មិនរួចតែអាបត្តិ ប៉ារាជិក សង្ឃាទិសេស នឹងអាបត្តិដែលពាក់ទងដោយគ្រហស្ថ នឹងអាបត្តិរបស់ភិក្ខុដែលធ្វើយតបយល់ទាស់ថា សង្ឃកម្មនេះមិនគាប់ចិត្តខ្ញុំទេ នឹងអាបត្តិរបស់ភិក្ខុដែលមិនបានមកក្នុងទីនោះ ។ ចំណែកអដ្ឋកថា អធិប្បាយថា តិណ-វត្ថារកកម្មវាចា ដែលសង្ឃបានធ្វើហើយ កាលបើចប់កម្មវាចាហើយ ពួកភិក្ខុដែលមកប្រជុំគ្នាក្នុងទីនោះ សូម្បីដេកលក់ ឬចូលកាន់សមាបត្តិ ឬមានចិត្តកាយមាយទៅក្នុងអារម្មណ៍ដទៃ ក៏រួចចាកអាបត្តិទាំងអស់គ្នា

សម្បីអាបត្តិដែលត្រូវយូរហើយ គិតតាំងអំពីថ្ងៃឧបសម្បទាមកដល់សព្វថ្ងៃនេះក៏រួចទាំងអស់ វៀរលែងតែអាបត្តិបារាជិកជាដើមដូចបានពោលហើយ ។ នេះហៅថាអានិសង្សនៃគិណវត្តារកកម្មវាចា ។ ក៏ឯកម្មវាចានេះ គិតតាំងអំពីកម្មលក្ខណៈ ដែលបាននិយាយហើយ ក្នុងញត្តិកម្មកថាខាងដើម ដោយកម្មវាចា ៣ លើក មានសព្វសង្គាហិកញ្ញត្តិកម្មវាចាជាដើម រហូតដល់មកកម្មលក្ខណ ក្នុងញត្តិទុតិយកម្មកថានេះ និយាយដោយកម្មវាចាពីរលើក ហៅថា ញត្តិទុតិយកម្មវាចា មានអានិសង្សឲ្យរួចចាកអាបត្តិដូចគ្នា ។

ញត្តិទុតិយកម្មវាចាទាំងពីរលើកដូចបាននិយាយមកនេះ ហៅថា កម្មលក្ខណ ក្នុងញត្តិទុតិយកម្មកថានេះ ។

ចប់ញត្តិទុតិយកម្មកថា

( ញត្តិចតុត្ថកម្មកថា មានក្នុងភាគ ២ )



រោងពុម្ព មិត្តភាព

កម្ពុជា-ជប៉ុន


តម្លៃ : ២២០០ ៛